ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ការចងចាំគឺជាយុត្តិធម៌ ការបំភ្លេច គឺជាបទឧក្រិដ្ឋ
- ព្រៃសហគមន៍សង្ឃរុក្ខវ័ន្ត គឺជាសម្បត្តិធម្មជាតិដ៏មានតម្លៃ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៣០ ខែកុម្ភៈ ឆ្នាំ២០១៩

ស្វែងរកការពិត

លេខ២៣០ ខែកុម្ភៈ ឆ្នាំ២០១៩

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

**សំបុត្រ**

◆ ការចងចាំគឺជាយុត្តិធម៌ ការបំភ្លេចគឺជាបទឧក្រិដ្ឋ ......................១

**ផ្នែកឯកសារ**

◆ ភឿង លើយៈ អនុសេនីយ៍ផ្កាយ២ អនុប្រធានវរសេនាតូច .........៣

**ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ**

◆ ការផ្សះផ្សា និងព្យាបាលរបួសផ្លូវចិត្ត តាមរយៈទស្សនា ............ ៧
◆ ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» រៀបរាប់អំពីការពិត...១៣
◆ អតីតកម្មាភិបាលខ្មែរក្រហម ជនរងគ្រោះ និងអ្នកស្រាវជ្រាវ...... ១៦
◆ ព្រៃសហគមន៍សង្ឃរុក្ខវ័ន្ត គឺជាសម្បត្តិធម្មជាតិដ៏មានតម្លៃ ........ ២០
◆ គេហទំព័រ «ទីចងចាំ» លើកឡើងអំពីប្រវត្តិសាស្ត្រ ................. ២៤
◆ អត្ថន័យនៃល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ចំពោះខ្ញុំ.... ២៩

**ផ្នែកច្បាប់**

◆ អង្គជំនុំជម្រះសាលាដំបូង៖ សេចក្តីសង្ខេបសាលក្រម .............៣១

**វេទិកាពិភាក្សាសាធារណៈ**

◆ ការសម្តែងល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់»......... ៣៦
◆ ការសម្តែងល្ខោនរឿង «ទម្លាយភាពស្ងៀមស្ងាត់» រៀបរាប់ ...... ៤០
◆ ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» គឺជាការសម្តែង........៤៧

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ព័ត៌មានមិនច្បាស់លាស់អំពីឪពុកម្តាយខ្ញុំ នៅតែធ្វើឲ្យខ្ញុំ............៥៤
◆ បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម .............៥៨
◆ អដ្ឋិធាតុ៖ គ្មានអ្វីជាអមតៈ .......................................... ៦០



ដួន ច័ន្ទសុវណ្ណា គឺជាសិស្ស ថតនៅខេត្តតាកែវឆ្នាំ១៩៦៥

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ៣៧៥ ព.មប្រក
ចុះថ្ងៃអង្គារ ៦រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

***ស្នេរលេខនេះ៖*** *ឆាំង យុ, រី លក្ខិណា, ដាត ចាន់សុនិតា, ព្រាំ គិតម៉ាន់, ផេង ពង្សរ៉ាសុី, ចៅ ច័ន្ទសុវណ្ណារិនិត្យ, វ៉ាន់ ថាន់ពៅដារ៉ា, ចាន ប្រាថ្នា, សា ហ្វាទីលី, និង សុភ័ក្ត្រ ភាណា* ***អ្នកនិពន្ធ និងស្រាវជ្រាវ៖*** *ហូ ថុនា, អ៊ុន សុដាវី និង ដារ៉ារដ្ឋ មេត្តា* ***អ្នកបកប្រែ៖*** *អ៊ុន សុដាវី* ***និពន្ធនាយកទូទៅ៖*** *សោម ប៊ុនថន* ***ជំនួយការនិពន្ធនាយក៖*** *ហូ ថុនា* ***ក្រាហ្វិកកុំព្យូទ័រ៖*** *គីម សុវណ្ណដានី* ***គ្រប់គ្រងការចែកផ្សាយ៖*** *ឆេង វ៉េង*

**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# ការចងចាំគឺជាយុត្តិធម៌ ការបំភ្លេចគឺជាបទឧក្រិដ្ឋ

សំណួរ ៖ តើលោកអាចរៀបរាប់ដោយសង្ខេបពីជីវិតប្រចាំថ្ងៃ ដែលលោកត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើការងារបានដែរឬទេ?

ឆាំង យុះ៖ នៅក្នុងឆ្នាំ១៩៧៥ ខ្ញុំមានអាយុ១៨ឆ្នាំ។ ចំពោះការរៀបរាប់អំពីជីវិតរស់នៅប្រចាំថ្ងៃនៅក្នុងរបបខ្មែរក្រហម ពាក្យដែលខ្ញុំនឹកមុនគេ គឺពាក្យ «ឯកោ»។ មនុស្សគ្រប់រូបមើលទៅ ដូចៗគ្នាទាំងអស់ ទាំងការកាត់សក់ ពណ៌សម្បុរ និងការស្លៀកពាក់ ហើយយើងក៏និយាយភាសាតែមួយដូចគ្នាដែរ។ ប៉ុន្តែយើងគ្រប់គ្នារស់នៅពឹងផ្អែកលើខ្លួនឯងទាំងស្រុង។ យើងមិនអាចទុកចិត្តនរណាម្នាក់បានឡើយ។ នៅពេលខ្លះ យើងក៏មិនអាចទុកចិត្តសមាជិកគ្រួសាររបស់យើង ឬមិត្តភក្តិ ជិតស្និទ្ធរបស់យើងផ្ទាល់បានដែរ ព្រោះថាមនុស្សគ្រប់គ្នាត្រូវតែប្រុងប្រយ័ត្នរៀងៗខ្លួន។ ភាពឯកោបានជ្រាបចូលក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង ហើយពិតជាសាកសមទៅនឹងគោលបំណងរបស់ ខ្មែរក្រហមក្នុងការគ្រប់គ្រងប្រជាជនកម្ពុជា។ នៅពេលដែលគោលបំណងកាន់តែសម្រេចច្បាស់លាស់ ជីវិតមនុស្សក៏ត្រូវស្ថិតនៅក្នុងកម្រិតទាបបំផុតដែរ។ ពេលវេលា គឺមិនមានឡើយក្នុងពេលនោះ។ គ្មាននរណាម្នាក់មាននាឡិកាមើលម៉ោងឬនាឡិកាដៃនោះទេ។ ដូច្នេះពេលវេលាត្រូវបានកំណត់ដោយព្រះអាទិត្យរះ ព្រះ-អាទិត្យលិច ឬមាន់រងាវ។ ប៉ុន្តែខ្មែរក្រហមចង់រៀបចំពេលវេលា សម្រាប់ថ្ងៃនីមួយៗ។ ខ្ញុំភ្ញាក់ឡើងនៅពេលព្រះអាទិត្យរះ និងចេញទៅធ្វើការនៅតាមវាលស្រែរហូតដល់ពេលឈប់សម្រាកហូបអាហារថ្ងៃត្រង់លើកទីមួយ ដែលមានរយៈពេលប្រហែល១៥នាទី។ ក្នុងរដូវប្រាំងនៅតំបន់៥ របបអាហារដែលខ្ញុំទទួលបាន សម្រាប់រយៈពេលមួយថ្ងៃ គឺបបររាវ និងទឹក២ស្លាបព្រា ពីព្រោះនៅតំបន់នេះខ្វះខាតទឹកខ្លាំង ណាស់។ សម្លៀកបំពាក់របស់យើងដាច់រហែករយ៉ាយ។ យើងគ្មានស្បែកជើងពាក់ទេ។ ប្រសិនបើយើងចង់បោកសម្អាតសម្លៀកបំពាក់ គឺយើងត្រូវគក់វានៅក្នុងបង្គី។ ពេលវេលាប្រចាំថ្ងៃ ត្រូវទទួលរងគំនាបដោយការបង្ខំឲ្យធ្វើការងារនៅក្នុងស្រែ អមជាមួយនឹងការចាក់ចម្រៀងបដិវត្តន៍ តាមឧបករណ៍បំពងសម្លេង។ នៅពេលល្ងាចបានមកដល់យើងទទួលបានបបរាវម្តងទៀត។ ជារៀងរាល់ល្ងាច យើងគ្រប់គ្នាត្រូវតែសារភាពពីទោសកំហុសដែលយើងបានប្រព្រឹត្តទៅកាន់អង្គប្រជុំ រាប់ចាប់តាំងពីការនឹករឭកដល់ម្តាយ រហូតដល់ការគិតដល់របស់ឆ្ងាញ់ៗដូចជាទឹកក្រូចកូកាកូឡា ឬនំប៉័ង។ ចម្លើយសារភាព គឺជាវិធីសាស្ត្រមួយនៃការគ្រប់គ្រងរបស់ខ្មែរក្រហម។ ប្រសិនបើកម្មាភិបាលដឹកនាំខ្មែរក្រហមចូលចិត្តយើង នោះយើងអាចរួចខ្លួនពីទោសកំហុស។ ប៉ុន្តែប្រសិនបើកម្មាភិបាលនោះមិនពេញចិត្តយើងទេ នោះកំហុសរបស់យើងអាចក្លាយជាបទឧក្រិដ្ឋ ហើយយើងអាចទទួលរងការធ្វើទារុណកម្ម ឬសម្លាប់ចោលនៅក្នុងពេលនោះ។ ជារៀងរាល់យប់ងងឹត និងរាល់ពេលរាត្រីដែលគ្មានព្រះច័ន្ទ យើងនឹកភ្នកតែរឿងរត់គេច ចេញឲ្យឆ្ងាយគេចពីទុក្ខវេទនា និងសេចក្តីស្លាប់។ យើងតែងតែព្យាយាមរត់គេចខ្លួននៅពេលយប់ ទៅតាមស្ថានភាពជាក់ស្តែង។ អ្នកខ្លះរត់គេចខ្លួនបានដោយជោគជ័យ ខណៈពេលដែលអ្នកខ្លះទៀត ត្រូវខ្មែរក្រហមចាប់ខ្លួនមកវិញ។ នាពេលបច្ចុប្បន្ន វាពិតជាពិបាកណាស់ក្នុងការនឹកគិតអំពីជីវិតរស់នៅដែលគ្មានបង្គន់គ្មានច្រាសដុសធ្មេញគ្មានសាប៊ូគ្មានស្បែកជើង ឬសម្ភារផ្សេងៗដែលចាំបាច់ សម្រាប់ការរស់នៅរបស់មនុស្ស។ បងស្រីខ្ញុំគ្មានសម្ភារអនាម័យសម្អាតខ្លួនប្រាណសម្រាប់ស្ត្រីឡើយ ហើយប្រសិនបើអ្នកធ្លាក់ខ្លួនឈឺវិញ អ្នកនឹងប្រឈមមុខនឹងសេចក្តីស្លាប់ដោយជៀសមិនផុត ដោយ

សារតែគ្មានការថែទាំសុខភាព។ ប្រជាជនជាច្រើនបានស្លាប់ ដោយបាក់កម្លាំង និងជម្ងឺដែលបង្ក ដោយអាកាសធាតុភ្លៀង ធ្លាក់ក្នុងរដូវក្តៅ។ នេះគឺជារឿងរ៉ាវជីវិតប្រចាំថ្ងៃដែលបាន កើតឡើងអូសបន្លាយអស់ប្រហែល៤ឆ្នាំ។

សំណួរ៖ តើផលប៉ះពាល់អ្វីខ្លះដែលខ្មែរក្រហមបាន បន្សល់ទុកនាពេលបច្ចុប្បន្ន?

ឆាំង យុ ៖ មានផលប៉ះពាល់ច្រើនណាស់ដែលបាន បន្សល់ទុក ប៉ុន្តែមានតែផលប៉ះពាល់តែមួយគត់ដែលប្រជា ជនកម្ពុជាត្រូវតែចូលរួមដោះស្រាយ នោះគឺសាលាក្តីខ្មែរ ក្រហមដែលបានផ្តល់សារប្រយោជន៍ជាច្រើនដល់ការវិវឌ្ឍន៍ នៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែយើងហាក់ដូចជាមិនពេញចិត្ត ចំពោះតម្លៃដ៏ពិតប្រាកដរបស់សាលាក្តីនេះទាំងស្រុងឡើយ រហូតដល់ពេលវេលាមួយដែលស្ថាប័ន មួយនេះបានបញ្ចប់ ទៅ ហើយយើងនៅមានទស្សនយល់ឃើញមួយ ចំពោះការ ចូលរួមចំណែករបស់សាលាក្តីនេះ។ ការស្វែងយល់ពីដែន កំណត់របស់សាលាក្តី គឺពិតជាមានសារសំខាន់។ ទោះបីជា អ្នករស់រានមានជីវិតមួយចំនួនយល់ឃើញថាសាលាក្តីនេះ គឺជាទម្រង់នៃការព្យាបាលក៏ដោយ ក៏សាលាក្តីខ្មែរក្រហម គឺពិតណាស់មិនមែនជាវេទិកាពិភាក្សាពីដំណើរការនៃការ ព្យាបាលរបួសផ្លូវចិត្ត ឬការផ្សះផ្សាឡើយ ហើយក៏មិនមែន ជាថ្នាក់រៀនប្រវត្តិសាស្ត្រដែរ។ គោលបំណងរបស់សាលាក្តី ខ្មែរក្រហម គឺដើម្បីកាត់ទោសមេដឹកកំពូលខ្មែរក្រហម ឬអ្នក ទទួលខុសត្រូវខ្ពស់បំផុត និងជួយដល់ប្រជាជនកម្ពុជាតាមវិធី អនុញ្ញាតឲ្យអ្នកទាំងនោះឃ្លាំមើល និងចូលរួមក្នុងដំណើរការ របស់សាលាក្តី។ ប្រទេសកម្ពុជាអាចនឹងកើតមានបញ្ហាប្រឈម ច្រើន ថែមទៀតនាពេលបច្ចុប្បន្ន ប្រសិនបើមិនមាន សាលាក្តី ខ្មែរក្រហមទេ។ តាមរយៈដំណើរការកាត់ក្តី និងការវិនិច្ឆ័យ ទោសរបស់សាលាក្តីខ្មែរក្រហម សាលាក្តីនេះបានជួយដល់ ប្រជាជនកម្ពុជាឲ្យក្រឡេកមើលពីអតីតកាលរបស់ខ្លួនតាម វិធីដែលខ្លួនមិនអាចធ្វើដោយខ្លួនឯងបាន។

សំណួរ៖ ចាប់តាំងពីការប្រទេសកម្ពុជាត្រូវបានរំដោះ ចេញពីរបបខ្មែរក្រហមអស់រយៈពេល៤០ឆ្នាំកន្លងមកនេះ តើប្រទេសកម្ពុជាបានជៀសផុតពីអំពើប្រល័យពូជសាសន៍ ហើយ ឬក៏អំពើប្រល័យពូជសាសន៍នៅតែមានឥទ្ធិពលមក លើប្រទេសកម្ពុជាដដែល?

ឆាំង យុ ៖ វាពិតជាមានសារសំខាន់ណាស់ដែលត្រូវ កត់សម្គាល់ថា រឿងរ៉ាវពីអតីតកាលរបស់ប្រជាជនកម្ពុជា នៅ តែជាផ្នែកមួយនៃ«ជីវិតបច្ចុប្បន្ន»របស់ខ្លួន។ ទោះបីជាប្រវត្តិ សាស្ត្រនេះ បានកន្លងផុតទៅអស់រយៈពេល៤០ឆ្នាំហើយក៏ ដោយ ក៏ផ្នែកមួយចំនួននៃប្រវត្តិសាស្ត្រពីអតីតកាល នៅតែ បន្តកើតមានឡើងក្នុងសង្គមបច្ចុប្បន្ន។ មានការលើកឡើងថា ភាពជោគជ័យរបស់ប្រជាជនកម្ពុជាចំពោះការប្រឈមនឹង អតីតកាល គឺជាសមិទ្ធផលមួយដែលគួរឲ្យកត់សម្គាល់។ ផ្នែកសំខាន់ៗ ជាច្រើនកំពុងស្ថិតនៅក្នុងដំណើរការនៃជំហាន បន្ទាប់ទៀត។ យើងមានសន្តិភាពនៅក្នុងប្រទេស ក្រោមរដ្ឋ ធម្មនុញ្ញ និងរដ្ឋាភិបាលតែមួយ ហើយជីវិតប្រជាជនកម្ពុជា ជាច្រើនមានភាពល្អប្រសើរឡើង បើប្រៀបធៀបទៅនឹងរយៈ ពេល៤០ឆ្នាំមុន។ ទោះជាយ៉ាងណាក៏ដោយ ក៏យើងនៅមាន កិច្ចការ ជាច្រើនទៀតដែលត្រូវបំពេញ។ ថ្វីត្បិតតែយើងមាន សន្តិភាពក៏ដោយ ក៏សន្តិភាពនេះជាសន្តិភាពដ៏ផុយស្រួយ មួយ ព្រោះថាយើងនៅបន្តតស៊ូជាមួយឧបសគ្គជាច្រើនទៀត។ យើងត្រូវផ្តល់អាទិភាពលើការអប់រំអំពីប្រវត្តិសាស្ត្រនេះ ជា ពិសេសសម្រាប់ក្មេងៗជំនាន់ក្រោយ ដែលនៅតែបន្តសួរ សំណួរ អំពីរឿងរ៉ាវពីអតីតកាល។ វាមិនមែនជាការលំបាក ទេសម្រាប់សង្គមកម្ពុជា ចំពោះការបំភ្លេចចោលអតីតកាល របស់ខ្លួន។ ដូច្នេះ កត្តាដែលចាំបាច់បំផុតនោះ គឺយើងត្រូវ តែអប់រំក្មេងជំនាន់ក្រោយ ឲ្យយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរ ក្រហម ខណៈពេលដែលយើងកំពុងតែនៅមានប្រជាជន ដែលបានរស់រានមានជីវិតពីសម័យនោះ នៅមានជីវិតនៅ ឡើយនាពេលបច្ចុប្បន្ននេះ។

**ឆាំង យុ**

# ង្វៀង លើយ៖ អនុសេនីយ៍ផ្កាយ២ អនុប្រធានវរសេនាតូចលេខ៨ វរសេនាធំលេខ២៩
# ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខD0៧១៤៨

ខាងក្រោមនេះ គឺជាចម្លើយសារភាពរបស់អ្នកទោសជនជាតិវៀតណាមឈ្មោះ ង្វៀង លើយ ភេទប្រុស មានអាយុ ២៨ឆ្នាំ គឺជាអតីតអនុសេនីយ៍ផ្កាយ២ អនុប្រធានវរសេនាតូចលេខ៨ វរសេនាធំលេខ២៩ យោធភូមិភាគទី៥។ ង្វៀង លើយ ត្រូវកងទ័ពខ្មែរក្រហមព័ទ្ធចាប់ខ្លួនបាននៅនៅសមរភូមិអូរយ៉ាដាវ ខេត្តរតនគិរី នៅពេលដែលក្រុមរបស់ខ្លួនកំពុងវាយលុកចូលក្នុងខេត្តរតនគិរីនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៨។






ខ្ញុំកើតនៅភូមិតិនឡុង ឃុំទិញឡុង ស្រុកសឺនទិញ ខេត្តផាំបិញ ប្រទេសវៀតណាមកណ្តាល។ នៅខែមករា ឆ្នាំ១៩៧៣ ខ្ញុំបានចូលធ្វើជាឈ្លបនៅឃុំទិញឡុង ដែលប្រធានឃុំឈ្មោះ ត្រិន ហូ ហើយប្រធានឈ្លបឃុំឈ្មោះ ដូ បែ។ ខ្ញុំបានយកប្រាក់ចំនួន១៥.០០០ដុង ទៅសូកឲ្យ ត្រិន ហូ ដើម្បីបានឡើងជាអនុប្រធានឈ្លប ឃុំទិញឡុង។ ត្រិន ហូ និង ដូ បែ បានឲ្យកងឈ្លបដើរប្លន់ទ្រព្យសម្បត្តិប្រជាជនមកឲ្យស្ទើរតែរាល់ថ្ងៃ។

នៅក្នុងខែមីនា ឆ្នាំ១៩៧៤ ត្រិន ហូ បានបញ្ជូនខ្ញុំឲ្យមកនៅក្នុងអនុសេនាធំលេខ២ វរសេនាតូចលេខ៨ និងវរសេនាធំលេខ២៩ យោធាភូមិភាគទី៥។ ខ្ញុំបានទៅហាត់បច្ចេកទេសនៅដាណាំងអស់រយៈពេល៩ខែ។ ពេលត្រឡប់មកពីរៀនវិញ ប្រធានវរសេនាតូចឈ្មោះ «គី» បានឲ្យខ្ញុំឡើងជាពលបាលផ្កាយ២។

នៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ វរសេនាធំលេខ២៩ បានមកបោះទីតាំងនៅក្នុងស្រុកឌឹកឡិប ខេត្តដារឡាក់។ ក្រុមទាហាននៅក្នុងវរសេនាធំលេខ២៩ គឺមានចិត្តឃោរឃៅណាស់ ដោយស្ទើរតែរៀងរាល់ថ្ងៃ ទាំងមេទាហាន និងកូនទាហានគិតតែដើរផឹកស៊ី និងលេងស្រី។ ទាហានវរសេនាធំលេខ២៩ បានលួចប្លន់ទ្រព្យសម្បត្តិរបស់ប្រជាជន និងចាប់កូនប្រពន្ធរបស់ប្រជាជនយកមករំលោភតាមអំពើចិត្ត។ ការកាប់សម្លាប់ជនជាតិភាគតិចនៅស្រុកឌឹកឡិបកាន់តែសាហាវព្រៃផ្សៃខ្លាំងណាស់។ ស្ទើរតែប្រចាំថ្ងៃ ក្រុមរបស់ខ្ញុំ បានកាប់សម្លាប់ជនជាតិភាគតិចអស់ចំនួនពី៤ទៅ៥នាក់។ ការកាប់

សម្លាប់បំបាត់ពូជសាសន៍នេះ បានធ្វើឲ្យជនជាតិភាគតិចតស៊ូប្រឆាំងបក្សវៀតណាមខ្លាំងក្លាណាស់។ ជនជាតិភាគតិចនាំគ្នារត់ចូលទៅក្នុងព្រៃដើម្បីបង្កើតទ័ព និងចាំស្កាត់ផ្លូវដើម្បីកាប់សម្លាប់កម្មាភិបាល និងទាហានវៀតណាម ថែមទាំងបានយកអាវុធជាបន្តបន្ទាប់។

នៅក្នុងខែសីហា ឆ្នាំ១៩៧៧ បក្សវៀតណាម បានឲ្យវរសេនាធំរបស់ខ្ញុំ ចេញវាយកម្ចាត់កងទ័ពជនជាតិភាគតិចដែលកាន់កាប់ផ្លូវឌឹកឡិប-បានមេធួត ព្រោះកងទ័ពជនជាតិភាគតិចឆ្លងកាត់ផ្លូវឌឹកឡិប-បានមេធួត នេះជាញឹកញាប់ណាស់ក្នុងមួយខែៗ។ ក្នុងការវាយបើកផ្លូវនេះ ទាហានវរសេនាធំខ្ញុំត្រូវបាត់បង់ជីវិតអស់ប្រមាណពី៤០ទៅ៥០នាក់។ ក្នុងការវាយបើកផ្លូវនេះម្តងៗ ទាហានវរសេនាធំលេខ២៩ត្រូវគ្រាប់ផាប់ច្រើនណាស់។ ក្រុមរបស់ខ្ញុំរអានឹងខ្លាចកងទ័ពជនជាតិភាគតិចនៅ តីងៀង នេះកាន់តែខ្លាំងឡើងៗ។

នៅក្នុងខែតុលា ឆ្នាំ១៩៧៧ បក្សវៀតណាមបានបញ្ជាឲ្យវរសេនាធំខ្ញុំចេញទៅវាយកងទ័ពជនជាតិភាគតិចតាមផ្លូវឌឹកឡិប-បានដន-បានមេធួតទៀត។ ក្នុងកិច្ចប្រតិបត្តិការនេះ វរសេនាធំខ្ញុំ ត្រូវគ្រាប់ស្លាប់អស់រាប់រយនាក់ បោលទាំងខ្មោចនិងអាវុធ។ សព្វថ្ងៃនេះ នៅតំបន់ តីងៀង ទាហានវៀតណាមមិនសូវហ៊ានអើតក្បាលផ្តេសផ្តាសទេ។ ចលនាជនជាតិភាគតិច បានធ្វើជាម្ចាស់ខ្ទង់រាបព្រៃភ្នំហើយ។ ទាហានវៀតណាមគឺឈរជើងនៅតាមតែទីរួមស្រុក និងទីរួមខេត្តនៃតំបន់តីងៀងនេះ។

នៅ ដានរ៉ាង និង ដានធៀត ក៏មានចលនាជនជាតិចាមដែរ។ ចលនានេះចាប់ប្រឆាំងនឹងបក្សវៀតណាមក្នុងឆ្នាំ១៩៧៧ កាន់តែខ្លាំងក្លា។ ជនជាតិចាមនាំគ្នាចូលព្រៃតស៊ូដោយមានអាវុធខ្លះ។ ជនជាតិចាមបានវាយយកកាំភ្លើងពីទាហានវៀតណាមបានជាបន្តបន្ទាប់។ បក្សវៀតណាមកំពុងតែជួបបញ្ហាវិលក្បុងនៅកន្លែងនោះទៀត។

ដើមខែវិច្ឆិកា ឆ្នាំ១៩៧៧ វរសេនីយ៍ផ្កាយ១ឈ្មោះ ដូ ដូវ ដែលជាប្រធានវរសេនាធំលេខ២៩ បានឲ្យដឹងថា បក្សវៀតណាមមានផែនការវាយយកកម្ពុជានៅក្នុងឆ្នាំ១៩៧៧ ដើម្បីបញ្ចូលកម្ពុជាទៅក្នុងសហព័ន្ធឥណ្ឌូចិនរបស់បក្សវៀតណាម។ ដូ ដូវ និយាយថា «បើយើងមិនវាយយកប្រទេសកម្ពុជាទេ ប្រជាជនយើងនៅតែអត់ឃ្លានដូចនេះដដែល។ បក្សយើងមានជំនឿយ៉ាងមាំថា យើងវាយយកប្រទេសកម្ពុជាបានយ៉ាងងាយស្រួល ព្រោះយើងមានទាហានច្រើន មានអាវុធសម្បូរ













បែបទៀតផង»។

នៅចុងខែវិច្ឆិកា ឆ្នាំ១៩៧៧ ដដែល កងទ័ពយោធាភូមិភាគទី៥បានវាយចូលប្រទេសកម្ពុជា។ វរសេនាធំរបស់ខ្ញុំបានវាយចូលប្រទេសកម្ពុជាតាមផ្លូវលេខ១៩ ចំណែកឯកងពលលេខ២បានវាយចូលតាមផ្លូវលេខ១៤ តាមច្រកដាក់ដាំ។ នៅពេលដែលវាយចូលដល់ក្នុងទឹកដីប្រទេសកម្ពុជាភ្លាម កង

ទ័ពកម្ពុជា បានវាយសន្ធាប់គ្រប់មុខសញ្ញាទាំងអស់ ហើយ បានធ្វើឲ្យទាំងវរសេនាធំលេខ២៩ និងកងពលលេខ២ ទៅមុខក៏មិនរួច និងថយក្រោយក៏មិនរួចដែរ។ មេទាហាន និងកូនទាហានវៀតណាមបានស្លាប់ពាសពេញព្រៃ ព្រោះត្រូវគ្រាប់ដាប់ចម្រូង ធ្លាក់រណ្តៅចម្រូង និងត្រូវគ្រាប់ខ្មាំងគ្រប់ទិសទី។ មន្ទីរពេទ្យនៅបានមេធួត គ្មានកន្លែងដាក់អ្នករបួសទេ ហើយថ្នាំក៏អត់ ដោយបានធ្វើឲ្យអ្នករបួសរាប់សិបនាក់ស្លាប់ក្នុងមួយថ្ងៃៗ។

បន្ទាប់មក វរសេនាធំរបស់ខ្ញុំបានមកបោះទ័ពនៅស្រុកឌឹកឡិបវិញ។ បក្សវៀតណាមបន្ថែមទាហានថ្មីឲ្យចំនួន៤០០នាក់ទៀត។ វរសេនីយ៍ផ្កាយ១ ប្រធានវរសេនាធំខ្ញុំបានដំឡើងសក្តិឲ្យខ្ញុំ គឺជាអនុសេនីយ៍ផ្កាយ២ និងថែមទាំងចាត់តាំងជាអនុប្រធានវរសេនាតូចលេខ៨ទៀត។ ទាហានចាស់ និងទាហានថ្មី ភ័យបាក់ស្បាតខ្លាចបក្សវៀតណាមបញ្ជូនឲ្យចូលមកវាយប្រទេសកម្ពុជាទៀត។ ទាហានខ្លះបានរត់ទៅផ្ទះបន្តកន្ទុយគ្នា ដែលបានធ្វើឲ្យក្រុមទាហានក្រពុលមុខដូចផ្លែត្លុត។ ក្រុមទាហានបាននាំគ្នាស៊ីផឹកស្រវឹងឡូឡា ឈ្លោះប្រកែកគ្នា និងកាប់ចាក់គ្នាជារៀងរាល់ថ្ងៃ។ ទាហានទាំងនោះបានចាប់កូនប្រពន្ធប្រជាជនយកមករំលោភ និងបានបាញ់សម្លាប់ប្រជាជន ពិសេសជនជាតិភាគតិចយ៉ាងសាហាវព្រៃផ្សៃបំផុត។ ទាហានបានលួចទ្រព្យសម្បត្តិរបស់ប្រជាជនគ្មានសល់អ្វីឡើយ។ ទាំងប្រជាជននិងជនជាតិភាគតិចនៅ ឌឹកឡិប បានតស៊ូប្រឆាំងនឹងទាហានរបស់បក្សវៀតណាមយ៉ាងខ្លាំងក្លាណាស់។ ប្រជាជនបាននាំគ្នាធ្វើបាតុកម្មប្រឆាំង និងថែមទាំងលបកាប់ទាហានវៀតណាមយកអាវុធស្ទើរតែរាល់ថ្ងៃ។ ប្រជាជននាំគ្នារត់ចូលព្រៃ ដោយបែងចែកគ្នាជាក្រុមតូចៗ ដើម្បីវាយឆ្មក់យកកាំភ្លើងពីទាហានវៀតណាមជាបន្តបន្ទាប់។

នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៨ បក្សវៀតណាមផ្លាស់ឈ្មោះ ដូ ដូវ ចេញដោយដាក់វរសេនីយ៍ផ្កាយ១ឈ្មោះ ងៀង ឡិប មកធ្វើប្រធានវរសេនាធំលេខ២៩វិញ។ មកដល់ភ្លាម ងៀង ឡិប បានអួតសរសើរពីជំនួយយោធារបស់សូវៀតដូចជា យន្តហោះ រថក្រោះ កាំភ្លើងធំ កប៉ាល់ចម្បាំង គ្រាប់រំសេវ និងគ្រាប់កាំភ្លើងធំមានផ្សែងពុល។ ក្រោយមក ងៀង ឡិប បានធ្វើឲ្យដំណឹងបែកធ្លាយថា នៅសេនាធិការយោធាភូមិភាគទី៥ មានសូវៀត១០នាក់ មកក្តាប់ពីលើក្រុមរបស់ខ្លួន។ ក្រុមទាហានសូវៀតទាំងនោះ ក៏បានរៀបផែនការវាយលុកចូលក្នុងប្រទេសកម្ពុជានៅរដូវប្រាំងឆ្នាំ១៩៧៨-១៩៧៩ដែរ។ មិនតែប៉ុណ្ណោះនៅតាមកងពលផ្សេងៗទៀត យើងសង្កេតឃើញថាមានកងទ័ពសូវៀតច្រើនដែរ។ បក្សវៀតណាមវាដើរបោកប្រាស់ប្រជាជន ដោយរកជំនួយឲ្យប្រជាជនរងគ្រោះទឹកលិចមកធ្វើជានុយដើម្បីកេណ្ឌទាហានឲ្យបានច្រើននឹងវាយចូលក្នុងប្រទេសកម្ពុជានៅរដូវប្រាំងខាងមុខនេះ។

នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៨ វរសេនាធំរបស់ខ្ញុំបានទៅត្រៀមទ័ពនៅភ្នំម៉ាងយ៉ាង ក្នុងខេត្តផ្លេគូ។ នៅទីនោះ វរសេនីយ៍ផ្កាយ១ ងៀង ឡិប បានលើកផែនការវាយចូលប្រទេសកម្ពុជា ក្នុងគោលបំណងកាន់កាប់ខេត្តរតនគិរី ដើម្បីធ្វើជាកន្លែងអប់រំទាហានវរសេនាធំ២៩។ ងៀង ឡិប និយាយថាការវាយយកខេត្តរតនគិរី ជាការចាប់ផ្តើមការវាយលុកចូលប្រទេសកម្ពុជារបស់បក្សវៀតណាមនៅខែប្រាំង នៅក្នុង១៩៧៨-១៩៧៩នេះ។ ក្នុងការវាយលុកកម្ពុជាលើកនេះ បក្សវៀតណាម បានឲ្យប្រើគ្រាប់កាំភ្លើងធំមានផ្សែងពុលយ៉ាងច្រើន ដើម្បីយកជ័យជម្នះឲ្យបានដាច់ខាតលើកងទ័ពកម្ពុជា។ តែជាអកុសល វរសេនាធំរបស់ខ្ញុំត្រូវបានយោធាខ្មែរក្រហមព័ទ្ធវាយចាប់បានទាហានខ្លះទាំងរស់ និងទាហានខ្លះទៀតបានស្លាប់នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៨។

**កំណត់ចំណាំ៖** រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខ ស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូចនេះយើងមិនអាចសន្និដ្ឋានបានឡើយថា ចម្លើយរបស់អ្នកទោសវៀតណាម ងៀង លើយ នេះពិតឬយ៉ាងណានោះទេ។

**រី លក្ខិណា**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរគឺ ជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ប្រាំបី ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ ដល់ម៉ោង៥។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង សុង ថាណៃ តាមរយៈទូរសព្ទលេខ៖ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល៖ truththanay.s@dccam.org។












# ការផ្សះផ្សា និងព្យាបាលរបួសផ្លូវចិត្ត តាមរយៈទស្សនាល្ខោននិយាយ

កាលពីរសៀលថ្ងៃពុធ ទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ល្ខោននិយាយ«ទម្ងាយភាពស្ងៀមស្ងាត់» បានសម្តែងលើកទី២ ក្នុងឆ្នាំ២០១៩នេះ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ។

ចំពោះការសម្តែងល្ខោននិយាយ «ទម្ងាយភាពស្ងៀមស្ងាត់» នាពេលនេះ គឺដើម្បីឲ្យប្រជាជនកម្ពុជាគ្រប់វ័យទទួលបានប្រយោជន៍ពីស្នាដៃនេះ តាមរយៈការប្រឈមចំពោះបញ្ហានានា ទាក់ទងនឹងប្រវត្តិសាស្ត្រដ៏សោកសង្រេងដែលបានកើតមានឡើង។ ប្រជាជនកម្ពុជាទទួលបានឱកាសក្នុងការលើកឡើងអំពីបទពិសោធន៍ផ្ទាល់ខ្លួន នៅមុន និងក្រោយពេលនៃការសម្តែងល្ខោននិយាយ។ សកម្មភាពនេះក៏ផ្តល់ជាជំនួយដល់ប្រជាជនកម្ពុជា ក្នុងការស្វែងរកវិធីសាស្ត្រសម្រាប់បំពេញដំណើរការនៃការផ្សះផ្សា និងព្យាបាលរបួសផ្លូវចិត្ត ក៏ដូចជាវិធីសាស្ត្រដទៃទៀត ក្នុងការបន្តដំណើរឆ្ពោះទៅមុខទៀត។ ខាងក្រោមនេះ គឺជាចំណាប់អារម្មណ៍របស់តួសម្តែងក្នុងល្ខោននិយាយ គរុសិស្ស និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដោយលើកឡើងពីអ្វីដែលគាត់យល់ឃើញពីមុន និងក្រោយការសម្តែង និងទស្សនា៖

**តួសម្តែង**

ណោន ភារិទ្ធ អាយុ២៩ឆ្នាំ គឺជាតួសម្តែងឈុតថ្មី ដែលបន្ថែមលើឈុតចំនួន៧ទាក់ទងនឹងកម្មពារ និងដំណើរការស្វែងរកយុត្តិធម៌របស់សាលាក្តីខ្មែរក្រហម ដែលហៀបនឹង



គរុកោសល្យភូមិភាគតាកែវ កំពុងទស្សនាល្ខោននិយាយ ទម្ងាយភាពស្ងៀមស្ងាត់

បញ្ចប់នាពេលអនាគតដ៏ខ្លីខាងមុខៗ ភារិទ្ធ បានលើកឡើងថា «ខ្ញុំគឺជាតួសម្តែងថ្មីទាក់ទងនឹងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ហើយក៏ទើបតែសម្តែងជាលើកទី២ នៅគុកកោ-សល្យភូមិភាគខេត្តតាកែវ នៅក្នុងឆ្នាំ២០១៩នេះ។ លើកទីមួយនៃការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ខ្ញុំពិតជាមានការលំបាក និងមានការភិតភ័យខ្លាំងណាស់ ប៉ុន្តែក្នុងនាមខ្ញុំគឺជាសិល្បករមួយរូប ខ្ញុំត្រូវតែខិតខំព្យាយាមស្វែងប្រសើរឡើងៗ

ភារិទ្ធ បានបន្ថែមថា «សម្រាប់ខ្ញុំដែលជាក្មេងជំនាន់ក្រោយកើតក្រោយរបបខ្មែរក្រហមដួលរលំ វាពិតជាពិបាកយល់ខ្លាំងណាស់អំពីប្រវត្តិសាស្ត្រមួយនេះ។ បន្ទាប់ពីខ្ញុំបានចូលរួមសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នេះ បានធ្វើឲ្យខ្ញុំយល់កាន់តែច្បាស់ និងទទួលបានចំណេះដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការសម្តែងរបស់ខ្ញុំ។ ខ្ញុំក៏


លោកតូ ផង់ ពិន កំពុងរៀបរាប់បទពិសោធន៍ជីវិតក្នុងអំឡុងពេលរបបខ្មែរក្រហម

យល់អំពីសាច់រឿង និងត្រូវព្យាយាមយល់ពីអ្នកដឹកនាំរឿងថាតើអ្នកដឹកនាំត្រូវការឲ្យខ្ញុំធ្វើដូចម្តេចៗ ជាលទ្ធផល ខ្ញុំក៏អាចសម្រេចបានពីការសម្តែងរបស់ខ្ញុំ ទោះបីជាមានកំហុសខុសឆ្គងបន្តិចបន្តួចពីការសម្តែងរបស់ខ្ញុំក៏ដោយៗ វាគឺជាបទ-ពិសោធន៍ដំបូងរបស់ខ្ញុំ ដែលត្រូវតែធ្វើការសិក្សាស្វែងយល់បន្ថែមពីកំហុសឆ្គងទាំងនោះ ដើម្បីយកមកអភិវឌ្ឍន៍នៃការសម្តែងរបស់ខ្ញុំ នៅពេលក្រោយៗតទៅទៀតឲ្យកាន់តែល្អសង្ឃឹមដែរថា តាមរយៈការសម្តែង ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នឹងជួយឆ្លុះបញ្ចាំងអំពីរូបភាពមួយនៃរបបខ្មែរក្រហម ទៅកាន់សាធារណជនអ្នកទស្សនា ជាពិសេសក្មេងៗជំនាន់ក្រោយនឹងទទួលបានចំណេះដឹងពីល្ខោននិយាយនេះ ឲ្យកាន់តែស៊ីជម្រៅជាងមុន»។ ភារិទ្ធ បានបញ្ជាក់ថា «ខ្ញុំពិតជាមានមោទកភាពខ្លាំងណាស់ ចំពោះតួអង្គដែលខ្ញុំកំពុងសម្តែង ព្រោះតួអង្គនេះ ខ្ញុំហាក់បីដូចជាតំណាងឲ្យយុវជនខ្មែរ

ជំនាន់ក្រោយទូទាំងប្រទេស ដែលធ្លាប់តែបានឮពីរបបខ្មែរក្រហមតាមរយៈឪពុកម្តាយនិយាយប្រាប់ ចាស់ទុំ ឬការសិក្សាៗ ពីព្រោះតួអង្គនេះ បានឆ្លុះបញ្ចាំងពីក្មេងជំនាន់ក្រោយកំពុងតែមានការជឿងឆ្ងល់ថា «ហេតុអ្វីបានជារបបខ្មែរក្រហមកើតឡើង» «តើហេតុអ្វីបានជាអ្នករស់រានមានជីវិតនៃរបបខ្មែរក្រហម មិនព្រមនិយាយការពិតទៅកាន់ក្មេងៗជំនាន់ក្រោយឲ្យបានដឹង»។

### អ្នកលេងភ្លេង

អៀង សកុណា អាយុ៣៨ឆ្នាំ គឺជាតួអង្គលេងភ្លេង បានឲ្យដឹងថា «ខ្ញុំបានចូលរួមសម្តែងនៅអម្រឹតាសិល្បៈ អស់រយៈពេលជាង១០ឆ្នាំកន្លងមកហើយ។ មុនការចូលសម្តែង ខ្ញុំក៏ធ្លាប់បានឮពីរបបខ្មែរក្រហមតាមរយៈពុកម្តាយរបស់ខ្ញុំនិយាយប្រាប់ ពីហេតុការណ៍ដែលធ្លាប់បានកើតឡើងនៅក្នុងអំឡុងពេលដែលខ្មែរក្រហមកាន់អំណាច។ ម្តាយខ្ញុំបាន បាត់បង់សាច់ញាតិបងប្អូនអស់ជាច្រើននាក់ រួមទាំងឪពុកម្តាយរបស់គាត់ផងដែរ។ នៅពេលនោះ ខ្ញុំពិតជាមានអារម្មណ៍ទីងសម្បារខ្លាំងណាស់ បន្ទាប់ពីខ្ញុំបានឮដូចនេះ ព្រោះខ្ញុំចង់ឃើញមុខជីដូនជីតា ជាពិសេសមីងមាឬអ៊ំពូមីងរបស់ខ្ញុំ។

ក្រោយមកទៀត ខ្ញុំក៏បានចូលធ្វើការនៅក្នុងអម្រឹតាសិល្បៈ និងបានចូលរួមលេងភ្លេងអំពីរឿងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នេះ បានធ្វើឲ្យខ្ញុំយល់កាន់តែច្រើនឡើងនៃរបបខ្មែរក្រហម តាមរយៈការសម្តែងល្ខោននិយាយរបស់តួអង្គនីមួយៗ ដែលបានបង្ហាញពីរឿងរ៉ាវពិតធ្លាប់បានកើតឡើង។ ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» គឺបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការចូលរួមផ្សះផ្សាជម្លោះរវាងកម្មាភិបាលខ្មែរក្រហម និងជនរងគ្រោះ។ ខ្ញុំក៏សង្ឃឹមផងដែរថា ល្ខោននិយាយនេះ គឺជាផ្នែកមួយជួយដល់ក្មេងជំនាន់ក្រោយក្នុងការត្រិះរិះពិចារណាឲ្យបានច្បាស់ពីប្រវត្តិសាស្ត្ររបស់ខ្លួនដើម្បីជៀសវាងកុំឲ្យកើតមានឡើងប្រវត្តិសាស្ត្រដ៏សាហាវយង់ឃ្នងបែបនេះសារជាថ្មី។ សកុណា បានបញ្ជាក់ថា «ពីមុនមកខ្ញុំក៏ធ្លាប់មានផ្នត់គំនិតស្អប់ខ្ពើមខ្មែរក្រហមដែរ ប៉ុន្តែនៅពេលដែលខ្ញុំបានចូលរួមសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ជាច្រើនលើកច្រើនសារកន្លងមក បានធ្វើឲ្យខ្ញុំផ្លាស់ប្តូរនូវផ្នត់គំនិតរបស់ខ្ញុំ ដោយខ្ញុំយល់ឃើញថា ការគុំគួន និងការចងគំនុំ គឺវាគ្មានលទ្ធផលល្អសម្រាប់នរណាម្នាក់ទេ ប៉ុន្តែយើងក៏មិនត្រូវបំភ្លេចចោលនូវប្រវត្តិសាស្ត្រមួយនេះដែរ ផ្ទុយទៅវិញគឺយើងត្រូវធ្វើការសិក្សាស្វែងយល់ឲ្យបានច្បាស់ដើម្បីចងក្រងរក្សាទុកជាឯកសារប្រវត្តិសាស្ត្រសម្រាប់ក្មេងជំនាន់ក្រោយបានដឹង។ យ៉ាងណាមិញ ក្នុងបរិបទនោះគ្មានប្រជាជនណាម្នាក់ចង់ឲ្យកើតមានហេតុការណ៍បែបនេះកើតឡើងទេ ប៉ុន្តែដោយសារតែរបបនយោបាយ និងបរិបទសង្គម បានប្រែក្លាយមនុស្សទៅជាអាត្មានិយម លេងស្គាល់ឪពុកម្តាយបងប្អូន លេងស្គាល់បុណ្យបាប និងលេងស្គាល់ញាតិមិត្តជាដើម។ ខ្ញុំក៏សង្ឃឹមថា ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នេះ នឹងជួយជំរុញឲ្យប្រជាជនកម្ពុជាដែលរស់រានមានជីវិតពីរបបខ្មែរក្រហម នឹងចែករំលែកអំពីបទពិសោធន៍ជីវិតរបស់ខ្លួនទៅកាន់ក្មេងៗជំនាន់ក្រោយ ឲ្យបានដឹង»។

### គរុសិស្ស

អ៊ូ វ៉ាន់នី អាយុ២១ឆ្នាំ គឺជាគរុសិស្សឆ្នាំទី១ ជំនាន់ទី២៩ ឯកទេសប្រវត្តិភូមិ នៃគរុកោសល្យភូមិភាគខេត្តតាកែវ។ វ៉ាន់នី បានរៀបរាប់ថា «កាលពីមុនខ្ញុំធ្លាប់បានឮរបបខ្មែរក្រហមតាមរយៈចាស់ទុំដែលរស់នៅក្នុងភូមិជាមួយខ្ញុំនិយាយប្រាប់ខ្ញុំថា នៅខែមេសា ឆ្នាំ១៩៧៥ គឺជាពេលវេលាមួយដែលខ្មែរក្រហមបានដឹកនាំប្រទេស។ ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនធ្វើការហួសកម្លាំងទៅតាមតម្រូវការរបស់ខ្លួន ប្រសិនបើមានប្រជាជនមួយណាគេចវេះពីការងារ ឬប្រឆាំងនឹងខ្មែរក្រហមដែលដាក់បញ្ជាមក ប្រជាជននោះនឹងត្រូវបានខ្មែរក្រហមយកទៅរៀនសូត្រ ឬធ្វើទារុណកម្មជាដើម។ មិនតែប៉ុណ្ណោះ វ៉ាន់នី ក៏ធ្លាប់បានយល់ដឹងនៃរបបខ្មែរក្រហមតាមរយៈការសិក្សារបស់ខ្លួនកាលពីរៀននៅវិទ្យាល័យផងដែរ។ វ៉ាន់នី បានបញ្ជាក់ថា «ខ្ញុំធ្លាប់បានអានសៀវភៅប្រវត្តិសាស្ត្រកម្ពុជា

ប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) និងធ្លាប់បានធ្វើការសិក្សាស្រាវជ្រាវឯកសារផ្សេងៗទាក់ទងនឹងរបបខ្មែរក្រហមម្តងម្កាលដែរ។ ដូច្នេះ បានធ្វើឲ្យខ្ញុំយល់ដឹងពីរបបខ្មែរក្រហមតិចតួចដែរ។

ខ្ញុំពិតជាសប្បាយរីករាយខ្លាំងណាស់ ព្រោះបានចូលរួមទស្សនា«ល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់»នៅថ្ងៃនេះ។ ល្ខោននិយាយនេះ បានឆ្លុះបញ្ចាំងពីសកម្មភាពនៃរបបខ្មែរក្រហមតាមរយៈការសម្តែងៗ ពីមួយឈុតទៅមួយឈុត គឺបានឆ្លុះបង្ហាញពីរឿងរ៉ាវពិតរបស់ប្រជាជនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ដែលមើលទៅគួរឲ្យសង្វេគយ៉ាងពន់ពេក។ ខ្ញុំសង្ឃឹមថា ការសម្តែងល្ខោននិយាយនេះ នឹងជួយដល់ក្មេងជំនាន់ក្រោយឲ្យងាកមកចាប់អារម្មណ៍ពីប្រវត្តិសាស្ត្ររបស់ខ្លួនដែលធ្លាប់បានកើតឡើង ហើយត្រូវធ្វើការសិក្សាស្វែងយល់ឲ្យបានច្បាស់អំពីប្រវត្តិសាស្ត្រមួយនេះ។ សម្រាប់ខ្ញុំ នឹងយកចំណេះដឹងដែលទទួលបានពីការទស្សនាល្ខោននិយាយនេះទៅចែករំលែកដល់សិស្សរបស់ខ្ញុំក៏ដូចជាមិត្តភក្តិបងប្អូនអ្នកភូមិរបស់ខ្ញុំផងដែរ។ ខ្ញុំសូមសំណូមពរ ឲ្យមានការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នេះ ប្រព្រឹត្តទៅឆ្នាំបន្ទាប់ៗនៅក្នុងគរុកោសល្យភូមិភាគខេត្តតាកែវ តទៅទៀត។

### ជនរងគ្រោះ និងបទពិសោធន៍ជីវិតដែលធ្លាប់ឆ្លងកាត់ក្នុងរបបខ្មែរក្រហម

ខ្ញុំបាទ ឈ្មោះ ផង់ ពិន អាយុ៦៤ឆ្នាំ មានស្រុកកំណើតនៅភូមិត្រពាំងគូរ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ កាលពីសង្គមចាស់ ខ្ញុំរៀនបានថ្នាក់ទី៧ នៅសាលាបឋមសិក្សាវត្តលាយបូរ។ ខ្ញុំរៀនបាន៥ឆ្នាំ ក៏មានរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ ចេញពីតំណែង ដោយសេនាប្រមុខ លន់ នល់ ក្នុងឆ្នាំ១៩៧០។ ឆ្នាំ១៩៧១ ខ្ញុំមានវ័យ១៦ឆ្នាំ ក៏បានសម្រេចចិត្តបួសជាព្រះសង្ឃនៅវត្តលាយបូរ ក្នុងគោលបំណងគេចវេះពីការបង្ខិតបង្ខំធ្វើជាយោធា។ ខ្ញុំបានគង់នៅវត្តលាយបូរ អស់រយៈពេលមួយព្រះវស្សា ទើបខ្ញុំបានបន្តទៅគង់នៅវត្តស្វាយដង្គំ ស្ថិតក្នុងរាជធានីភ្នំពេញ។ ក្នុងការរត់ភៀសខ្លួននេះ គឺដោយសារតែមានការវាយប្រហារពីសំណាក់កងទ័ពខ្មែរក្រហម និងទាហាន លន់ នល់ កាន់តែខ្លាំងឡើង នៅក្បែរវត្តដែលខ្ញុំស្នាក់អាស្រ័យចាស់។ ក្រោយមក ខ្ញុំក៏បានរៀនភាសាបាលីនៅវត្តកោះ ប៉ុន្តែត្រូវត្រឡប់មកស្នាក់អាស្រ័យនៅវត្តស្វាយដង្គំវិញ។ ជារៀងរាល់ថ្ងៃ ខ្ញុំតែងតែធ្វើដំណើរដោយថ្មើរជើង ឆ្ពោះទៅវត្តកោះដើម្បីរៀនភាសាបាលី រហូតដល់ខ្មែរក្រហមវាយបែកទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុង ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ ដោយភូតកុហកថា «ប្រជាជនដែលរស់នៅទីក្រុងភ្នំពេញ គឺត្រូវចាកចេញពីទីក្រុងក្នុងរយៈពេលមួយសប្តាហ៍»។ ពេលនោះ ខ្ញុំក៏បានចាកចេញដូចនូវអ្វីដែលខ្មែរក្រហមបានប្រាប់ ប៉ុន្តែស្ថិតនៅមិនឆ្ងាយពីទីក្រុងភ្នំពេញទេ។ មួយសប្តាហ៍ក្រោយមក សភាពការណ៍នៅទីក្រុងភ្នំពេញហាក់មើលទៅមិនដូចនូវអ្វីដែលខ្មែរក្រហមបានលើកឡើងឡើយ។ ដូច្នេះ ខ្ញុំក៏បានសម្រេចចិត្តចាកចេញទៅស្រុកកំណើត ស្ថិតក្នុងខេត្តតាកែវ ទាំងខ្លួនពាក់ស្បង់ជីវរ។ បន្ទាប់ពីខ្ញុំបានមកដល់ស្រុកកំណើត បែរជាគ្មានសាច់ញាតិបងប្អូនរបស់ខ្ញុំរស់នៅទីនោះឡើយ ខ្ញុំក៏បានព្យាយាមស្វែងរកបងប្អូនតាមរយៈការសាកសួរអ្នកភូមិដែលរស់នៅក្បែរគ្នា រហូតដល់ខ្ញុំបានស្វែងរកសាច់ញាតិឃើញនៅភូមិត្បែងទទឹង ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។ បន្ទាប់ពីខ្ញុំបានជួបបងប្អូនរួចហើយ ស្រាប់តែបងប្អូនរបស់ខ្ញុំបានអញ្ជើញអាចារ្យមកផ្សឹកខ្ញុំ ដើម្បីឲ្យខ្ញុំធ្វើជាប្រជាជនធម្មតាវិញ។ កន្លះខែក្រោយមក ខ្មែរក្រហមបានចាប់ផ្តើមរៀបចំភូមិឃុំសារឡើងវិញ ព្រមទាំងបានបញ្ជូនខ្ញុំ ក៏ដូចជាអ្នកភូមិផ្សេងទៀតឲ្យចូលមករស់នៅក្នុងភូមិត្រពាំងគូរ ដែលជាស្រុកកំណើតរបស់ខ្ញុំ។ ក្រោយមក ខ្មែរក្រហមបានចាត់តាំងខ្ញុំ ឲ្យទៅដឹកអំបិលនៅសេះស ស្ថិតនៅក្នុងខេត្តកែប ដែលមានសមាជិកក្រុម៥នាក់ ដោយប្រើរយៈពេលមួយសប្តាហ៍ក្នុងការធ្វើដំណើរ

ទៅមកៗ រហូតដល់ដើមឆ្នាំ១៩៧៦ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យចូលក្នុងកងយុទ្ធជន ដែលមានសមាជិកចំនួន៥០០នាក់ៗ កាលនោះ ខ្ញុំ ក៏ដូចជាប្រជាជនស្ទើរតែទូទាំងខេត្តតាកែវ ដែលត្រូវបានខ្មែរក្រហមចាត់តាំងឲ្យជីកប្រឡាយត្រាំកក់ ដែលមានមាត់លើ៣០ម៉ែត្រ ជម្រៅបីម៉ែត្រទៅបីម៉ែត្រកន្លះៗ ការងារជីកប្រឡាយនេះ ពិតជាមានការលំបាកខ្លាំងណាស់ ព្រោះវាជាររដូវប្រាំង ធ្វើឲ្យដីរឹងប្រេះក្រហែងពិបាកក្នុងការកាប់គាស់ជាដើមៗ មិនតែប៉ុណ្ណោះ ខ្ញុំមិនដែលទទួលបានរបបអាហារហូបគ្រាន់ម្តងណាឡើយៗ ទោះបីជាមានការលំបាកយ៉ាងនេះក្តី ខ្ញុំ និងប្រជាជនដទៃទៀតមិនហ៊ានប្រកែកតវ៉ាជាមួយខ្មែរក្រហមដែរ ព្រោះខ្ញុំយល់ថា ការតវ៉ានេះច្បាស់ជាមិនមានលទ្ធផលល្អសម្រាប់ខ្ញុំទេៗ

រហូតដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យនៅក្រុមដាំដំណាំ និងបន្លែ ដែលមានសមាជិកក្រុមប្អូនទៅប្រាំនាក់ៗ កាលនោះ ខ្ញុំបានដាំដំណាំ និងបន្លែជាច្រើនប្រភេទរួមមាន៖ ត្រប់ ននោង ប៉េងប៉ោះ ដំឡូងមី ដំឡូងជ្វា ជាដើមៗ នៅពេលដែលខ្ញុំឃ្លានម្តងៗ ខ្ញុំតែងតែលួចត្រប់ និងននោងយកមកហូបជាញឹកញាប់ៗ ផ្ទុយទៅវិញ ប្រសិនបើខ្មែរក្រហមតាមទាន់ ខ្ញុំក៏មិនអាចគេចផុតពីសេចក្តីស្លាប់ដែរ ពីព្រោះតែការស្រេកឃ្លានបានធ្វើឲ្យខ្ញុំលេងនឹកគិតដល់ពីសេចក្តីស្លាប់ទៀតហើយៗ មានគ្រាមួយ ខ្មែរក្រហមបានចែកខោអាវឲ្យប្រជាជនម្នាក់មួយកំផ្លេរៗ ដែលជាចំណែកទទួលបានក្នុងមួយឆ្នាំៗៗ ពេលនោះ ខ្មែរក្រហមបានធ្វេសប្រហែសភ្លេចកត់ឈ្មោះអ្នកដែលទទួលបានខោអាវ បណ្តាលឲ្យខោអាវបាត់អស់មួយកំផ្លេរៗ ស្រាប់តែពេលនោះ ខ្មែរក្រហមបានចោទប្រកាន់ខ្ញុំថា គឺជាអ្នកលួចខោអាវនោះ ហើយខ្ញុំក៏មិនបានប្រកែកតវ៉ាជាមួយខ្មែរក្រហមឡើយ ព្រោះខ្ញុំគិតថា វាគ្មានប្រសិទ្ធភាពក្នុងការតវ៉ាទេៗ ប៉ុន្មានថ្ងៃក្រោយមក ខ្ញុំក៏ត្រូវបាន



សិល្បករ ណោន ភារិទ្ធ កំពុងហាត់សមសម្តែងល្ខោននិយាយ ទម្លាយភាពស្ងៀមស្ងាត់

សេនាជនមកដល់កន្លែងធ្វើការ ហើយបម្រុងនឹងចាប់ខ្លួនខ្ញុំយកទៅ ប៉ុន្តែជាកុសលខ្មែរក្រហមដែលកត់ឈ្មោះបាននឹកឃើញវិញថា ខោអាវដែលបាត់នោះ គឺគាត់បានយកទៅឲ្យប្រជាជនផ្សេងទៀត។ ដោយសារតែការធ្វេសប្រហែសរបស់ខ្មែរក្រហម ធ្វើឲ្យខ្ញុំស្ទើរតែគ្មានជីវិតរស់រហូតមកដល់សព្វថ្ងៃនេះ។ ខ្ញុំបានធ្វើការដំណាំ និងបន្លែ រហូតដល់ខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។ បន្ទាប់ពីខ្មែរក្រហមដួលរលំ ខ្ញុំមិនបានទៅរស់នៅឆ្ងាយពីស្រុកកំណើតដែរ ព្រោះសព្វថ្ងៃនេះ ខ្ញុំមានទីលំនៅរស់នៅក្នុងក្រុងដូនកែវ ខេត្តតាកែវ។

ជំនាន់ក្រោយ។ បន្ទាប់ពីខ្ញុំបានទស្សនារួចហើយខ្ញុំគិតថា ល្ខោននិយាយនេះ គឺពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ក្មេងជំនាន់ក្រោយ ព្រោះវាបានឆ្លុះបង្ហាញពីរូបភាពមួយនៃរបបខ្មែរក្រហមតាមរយៈស្តែងចេញពីរឿងពិតនៃរបបនោះ។ ទោះជាយ៉ាងណាក៏ដោយ ការចូលរួមទស្សនា ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នេះ គឺវាមានអារម្មណ៍ខុសប្លែកពីអ្វីដែលខ្ញុំធ្លាប់បានមើលខ្សែភាពយន្តដែលខ្មែរក្រហមធ្លាប់បានចាក់បញ្ចាំងនៅអំឡុងពេលដែលខ្លួនកាន់អំណាច។ កាលនោះ ខ្មែរក្រហមបានចាក់បញ្ចាំងខ្សែភាពយន្តមានចំណងជើង



ទស្សនិកជនកំពុងទស្សនាល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់

កាលពីប៉ុន្មានថ្ងៃកន្លងមកនេះ ខ្ញុំបានឮដំណឹងថា មានការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងាត់» ដែលជាសាច់រឿងល្ខោនដែលបានដកស្រង់ចេញពីរឿងរ៉ាវពិតរបស់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហម តាមរយៈការស្រាវជ្រាវ និងសម្ភាសន៍ជាមួយជនរងគ្រោះ និងជនដៃដល់នៅតាមភូមិឃុំនានាក្នុងប្រទេសកម្ពុជា។ ខ្ញុំពិតជាមានអារម្មណ៍ត្រេកអរណាស់ ព្រោះខ្ញុំចង់ដឹងថា តើការសម្តែងនេះវាបានឆ្លុះបញ្ចាំងអ្វីខ្លះពីរបបខ្មែរក្រហម និងបានជួយអ្វីខ្លះដល់ក្មេង

ថា «យុទ្ធមិត្តសាយ» និង «វីរភាពរបស់តាចាយ»។ ខ្សែភាពយន្តទាំងពីរនេះ គឺវាគ្រាន់តែជាខ្សែភាពដែលជួយដល់គោលនយោបាយខ្មែរក្រហមតែប៉ុណ្ណោះ។ ទោះបីជាខ្ញុំមិនចង់មើលក៏ខ្ញុំមិនអាចគេចវេះបានដែរ ព្រោះវាគឺជាការចាត់តាំងរបស់អង្គការ។ ប៉ុន្តែ ការចូលរួមទស្សនា ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នេះ គឺជាការចូលរួម និងទទួលស្គាល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហមដែលធ្លាប់បានកើតឡើង។

*ហូ ថុនា*

# ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» រៀបរាប់អំពីការពិតក្នុងសម័យខ្មែរក្រហម

នៅវេលាម៉ោង៣ះ៣០នាទី រសៀលថ្ងៃពុធ ទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ល្ខោននិយាយដែលមានចំណងជើងថា «ទម្លាយភាពស្ងៀមស្ងាត់» បានសម្តែងជាថ្មីម្តងទៀតនៅសាលប្រជុំនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ។ អ្នកចូលរួមទស្សនាល្ខោននោះ រួមមាន លោកជំទាវ ទន់ សាអ៊ឹម អនុរដ្ឋលេខាក្រសួងអប់រំ យុវជន និងកីឡា លោក ង៉ែត សូដា នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ព្រមទាំងសិស្សានុសិស្ស គរុសិស្ស គ្រូបង្រៀន មន្ត្រីរាជការ ប្រជាជន និងភ្ញៀវបរទេស ប្រមាណជាង៥០០នាក់។

ការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» គឺជាការជំរុញឲ្យមានការយល់ដឹងបន្ថែមពីប្រវត្តិសាស្ត្រសម័យខ្មែរក្រហម ការផ្សះផ្សា ការព្យាបាលរបួសផ្លូវចិត្ត រួមទាំងការដោះស្រាយនូវបញ្ហាប្រឈមនានា ទាក់ទងនឹងប្រវត្តិសាស្ត្រដ៏សោកសង្រេង ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩)។ ក្រោយពីការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» អ្នកទស្សនាក៏មានឱកាសពិភាក្សា លើកឡើងអំពីបទពិសោធន៍ជីវិតផ្ទាល់ខ្លួន និងបង្ហាញពីចំណាប់អារម្មណ៍ប្រាប់ ដល់អ្នកចូលរួម។

ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» គឺជាសាច់រឿងល្ខោន ដែលដកស្រង់ចេញពីរឿងរ៉ាវពិតរបស់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហម តាមរយៈការស្រាវជ្រាវ និងសម្ភាសន៍ជាមួយជនរងគ្រោះ និងជនដៃដល់នៅតាមភូមិឃុំនានាក្នុងប្រទេសកម្ពុជា។

ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ធ្លាប់បានសម្តែងនៅតាមបណ្តាភូមិឃុំមួយចំនួននៅក្នុងប្រទេសកម្ពុជា តាំងពីឆ្នាំ២០០៨ រហូតមកដល់ពេលបច្ចុប្បន្ន។ បើគិតមកដល់សព្វថ្ងៃ ប្រវត្តិនៃការកកើតល្ខោននិយាយនេះ មានអាយុកាល១០ឆ្នាំមកហើយ។ នៅក្នុងឆ្នាំ២០១៨ ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ត្រូវបានធ្វើបច្ចុប្បន្នភាពឡើងវិញ ដោយដាក់បញ្ចូលឈុតថ្មីមួយទៀត ដែលទាក់ទងនឹងដំណើរការស្វែងរកយុត្តិធម៌របស់សាលាក្តីខ្មែរក្រហម និងកម្មពារទៅតាមធម៌ព្រះពុទ្ធ។ ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» គឺបានសម្តែងឡើងជាមួយសាច់រឿងចំនួន៨ឈុត ដែលឈុតនីមួយៗបានឆ្លុះបញ្ចាំងអំពីភាពសោកសង្រេងនៃការបែកបាក់ ការបាត់បង់មនុស្សដែលខ្លួនស្រឡាញ់ ភាពមិនទុកចិត្តគ្នា គំនុំគំគួនដែលពិបាកក្នុងការអភ័យទោស និងការពិភាក្សាវែកញែករវាងមនុស្សពីរជំនាន់ខុសគ្នា។ ទន្ទឹមនឹងការរៀបរាប់ពីទុក្ខសោកវេទនារបស់ប្រជាជននៅក្នុងរបបខ្មែរក្រហម ក៏មានការច្រៀងចម្រៀងមនោសញ្ចេតនា ការរាំរបាំ និងរឿងនិទានដែរ។ សាច់រឿងនេះត្រូវបានសម្តែងដោយតួសម្តែងចំនួន៥នាក់ អ្នកច្រៀង១នាក់ និងអ្នករាំ១នាក់។

បន្ទាប់ពីការសម្តែងនេះអ្នកចូលរួមទស្សនាបានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោមៈ

១) ប៉ាង អ៊ិន អាយុ៧១ឆ្នាំ បច្ចុប្បន្នជាប្រធានភូមិអូរស្វាយចេក សង្កាត់រការក្នុង ក្រុងដូនកែវ ខេត្តតាកែវ បានមានប្រសាសន៍ ល្ខោនទម្លាយភាពពិតគឺសម្តែងចេញពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដែលគាត់ធ្លាប់បានឆ្លងកាត់ ហើយពាក្យសម្តីទាំងឡាយ ដែលប្រើប្រាស់នៅក្នុងល្ខោន

និយាយនេះ គឺជាពាក្យដែលគាត់ធ្លាប់បានស្តាប់ឮរាល់ថ្ងៃនៅក្នុងរបបខ្មែរក្រហម ដូចជាពាក្យ «អង្គការ» ឬ «សមមិត្ត» ជាដើម។ អ៊ិន បានឲ្យដឹងថា ល្ខោននេះនឹងធ្វើឲ្យមានការចងចាំពីរបបមួយ (របបខ្មែរក្រហម) ដែលបានបង្ខំឲ្យប្រជាជនធ្វើការធ្ងន់ធ្ងរ និងប្រព្រឹត្តអំពើឃោរឃៅមកលើប្រជាជន។ អ៊ិន បានរៀបរាប់ថា នៅក្នុងរបបខ្មែរក្រហមខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើការនៅក្នុងសហករណ៍ នៅឃុំលាយបូរ ស្រុកត្រាំកក់ តំបន់១៣ ភូមិភាគនិរតី ដោយខ្ញុំធ្វើការងារភ្ជួររាស់ កាប់គាស់គល់ឈើដើម្បីរានដីដាំដំណាំ រកត្រីសម្រាប់ផ្គត់ផ្គង់សហករណ៍ និងត្រួតពិនិត្យមើលទំនប់ទឹក។

អ៊ិន បានឲ្យដឹងថា នៅក្នុងរបបខ្មែរក្រហមក៏មានការសម្តែងល្ខោនដែរនៅក្នុងតំបន់របស់គាត់ ដូចជា ការសម្តែងល្ខោននៅទំបន់ស្វាគូ ដែលល្ខោនភាគច្រើននិយាយអំពីការតស៊ូ ការលះបង់ និងការខិតខំប្រឹងប្រែងធ្វើការរបស់ប្រជាជន។ ប៉ុន្តែទោះបីយ៉ាងក៏ដោយ ក៏គាត់មិនដែលបានចូលរួមទស្សនាការសម្តែងល្ខោនទាំងនោះដែរ។ អ្នកដែលអាចទៅទស្សនាការសម្តែងល្ខោនបាន លុះត្រាតែអ្នកនោះមានការអញ្ជើញពីថ្នាក់លើ និងអ្នកដែលមានតួនាទីនៅក្នុងបដិវត្តន៍ ដូចជា ប្រធានក្រុម ប្រធានកងពិសេស ប្រធានសហករណ៍ ប្រធានភូមិ និងប្រធានឃុំជាដើម។ ខ្ញុំបានឮសាច់រឿងល្ខោននោះតាមរយៈអ្នកដែលបានទៅចូលរួមទស្សនានិយាយប្រាប់ បន្ទាប់ពីត្រឡប់មកដល់សហករណ៍វិញ។ ចំណែកខ្ញុំបានត្រឹមតែស្តាប់ចម្រៀងបដិវត្តន៍ខ្មែរក្រហម ដែលតែងតែចាក់នៅតាមការដ្ឋានការងារប៉ុណ្ណោះ ហើយចម្រៀងភាគច្រើនដំរុញទឹកចិត្តប្រជាជនឲ្យខិតខំប្រឹងប្រែងធ្វើការដើម្បីបម្រើអង្គការបដិវត្តន៍។

២) អ៊ូ វ៉ាន់នី អាយុ២១ឆ្នាំ គឺជាគរុសិស្សឆ្នាំទី១ ជំនាន់ទី២៩ ឯកទេសប្រវត្តិភូមិ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ។ វ៉ាន់នី បានរៀបរាប់ថា «កាលពីមុនខ្ញុំធ្លាប់បានឮរបបខ្មែរក្រហមតាមរយៈចាស់ទុំដែលរស់នៅក្នុងភូមិជាមួយខ្ញុំនិយាយប្រាប់ខ្ញុំថា នៅខែមេសា ឆ្នាំ១៩៧៥ គឺជាពេលវេលាមួយដែលខ្មែរក្រហមបានដឹកនាំប្រទេស។ ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនធ្វើការហួសកម្លាំងទៅតាមផែនការរបស់ខ្លួន ប្រសិនបើមានប្រជាជនណាគេចវេះពីការងារ ឬប្រឆាំងនឹងបញ្ជា ប្រជាជននោះនឹងត្រូវបានខ្មែរក្រហមយកទៅរៀនសូត្រ ឬធ្វើទារុណកម្ម។ វ៉ាន់នី ក៏ធ្លាប់បានដឹងពីរបបខ្មែរក្រហមតាមរយៈការសិក្សារបស់ខ្លួនកាលពីរៀននៅវិទ្យាល័យដែរ។ វ៉ាន់នី បានបញ្ជាក់ថា «ខ្ញុំធ្លាប់បានអានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) និងធ្លាប់បានធ្វើការសិក្សាស្រាវជ្រាវឯកសារផ្សេងៗទាក់ទងនឹងរបបខ្មែរក្រហមម្តងម្កាលដែរ។

ខ្ញុំពិតជាសប្បាយរីករាយខ្លាំងណាស់ ដែលបានចូលរួមទស្សនាល្ខោននិយាយ«ទម្លាយភាពស្ងៀមស្ងាត់» នៅថ្ងៃនេះ។ ល្ខោននិយាយនេះ បានឆ្លុះបញ្ចាំងពីសកម្មភាពនៃរបបខ្មែរក្រហមតាមរយៈការសម្តែង។ ពីមួយឈុតទៅមួយឈុត គឺបានឆ្លុះបង្ហាញពីរឿងរ៉ាវពិតរបស់ប្រជាជនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ដែលមើលទៅគួរឲ្យសង្វេគយ៉ាងពន់ពេក។ ខ្ញុំសង្ឃឹមថា ការសម្តែងល្ខោននិយាយនេះ នឹងជួយដល់ក្មេងជំនាន់ក្រោយឲ្យងាកមកចាប់អារម្មណ៍ពីប្រវត្តិសាស្ត្ររបស់ខ្លួនដែលធ្លាប់បានកើតឡើង ហើយត្រូវធ្វើការសិក្សាស្វែងយល់ឲ្យបានច្បាស់អំពីប្រវត្តិសាស្ត្រមួយនេះ។ សម្រាប់ខ្ញុំនឹងយកចំណេះដឹងដែលទទួលបានពីការទស្សនាល្ខោននិយាយនេះ ទៅចែករំលែកជាមួយសិស្សរបស់ខ្ញុំ ក៏ដូចជាមិត្តភក្តិបងប្អូន អ្នកភូមិរបស់ខ្ញុំផងដែរ។ ខ្ញុំសូមសំណូមពរឲ្យមានការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នៅឆ្នាំបន្ទាប់ៗទៀតនៅក្នុងសាលាគរុកោសល្យភូមិភាគខេត្តតាកែវ។

៣) ឈ្មោះ រី សុកេត្តា គរុសិស្សជំនាន់ទី១ ឯកទេសភូមិ-ប្រវត្តិវិទ្យា នៃគរុសិស្សភូមិភាគខេត្តតាកែវដែលបានចូលរួមទស្សនាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ដែរ បានមានប្រសាសន៍ថា ខ្ញុំពិតជាអារម្មណ៍សប្បាយរីករាយ ដែលបានទស្សនាល្ខោននេះនិងកោតសរសើរអំពីការច្នៃប្រឌិត

និងការបង្កើតល្ខោននិយាយបែបថ្មីដែលបានបញ្ចូលនូវរឿងរ៉ាវរបស់ប្រជាជន និងប្រវត្តិសាស្ត្របង្ហាញដល់ក្មេងជំនាន់ក្រោយៗ

៤) នង ប៊ុនធឿន ភេទប្រុស អាយុ៤២ឆ្នាំ គ្រូបង្រៀនផ្នែកសិល្បៈនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ បានមានប្រសាសន៍ថា ខ្ញុំមានភាពសប្បាយរីករាយណាស់ នៅពេលបានទស្សនាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ដែលបានបង្ហាញអំពីការផ្សះផ្សារវាងជនរងគ្រោះ និងជនដៃដល់នៅក្នុងសម័យខ្មែរក្រហមឲ្យមានការយោគយល់អធ្យាស្រ័យគ្នាដើម្បីឲ្យមានសុខសន្តិភាពនៅក្នុងសង្គមជាតិទាំងមូលៗ ជាពិសេសតាមរយៈឈុតឆាកនៃការសម្តែងបានជួយកូនខ្មែរជំនាន់ក្រោយបានយល់អំពីប្រវត្តិសាស្ត្រនៃទុក្ខលំបាកវេទនារបស់ប្រជាជនខ្មែរនៅក្នុងសម័យខ្មែរក្រហម និងចេះរួបរួមសាមគ្គី អត់ឱន ស្រឡាញ់ មានចិត្តមេត្តា ដើម្បីជៀសផុតពីកំហុសប្រវត្តិសាស្ត្រដែលបានកើតឡើងកន្លងមកៗ តាមរយៈល្ខោននិយាយនេះ បានធ្វើឲ្យខ្ញុំនឹកឃើញដល់ឪពុករបស់ខ្ញុំដែលត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ប៉ុន្តែខ្ញុំយល់ថាមានតែការអត់ធ្មត់ចេះយោគយល់អធ្យាស្រ័យគ្នាប៉ុណ្ណោះ ទើបអាចធ្វើឲ្យខ្ញុំ គ្រួសាររបស់ខ្ញុំ និងប្រជាជនខ្មែរទូទាំងប្រទេសអាចរួមរស់ជាមួយគ្នាបានដោយភាពសុខសាន្តៗ ខ្ញុំសូមសំណូមពរឲ្យមានការរៀបចំកម្មវិធីសម្តែងល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់នេះនៅតាមទីតាំងផ្សេងៗទៀតដើម្បីឲ្យអ្នកជំនាន់ក្រោយបានដឹងអំពីរបបខ្មែរក្រហមៗ

*ក្រុមសរសេរទស្សនាវដ្តីស្វែងរកការពិត*



*តួអង្គស្វាកំពុងសម្តែងល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់*

# មជ្ឈមណ្ឌលឯកសារកម្ពុជា អតីតកម្មាភិបាលខ្មែរក្រហម ជនរងគ្រោះ និងអ្នកស្រាវជ្រាវ ចែករំលែកប្រវត្តិសាស្ត្រខ្មែរក្រហមដល់និស្សិតបរទេស

និស្សិតបរទេសចំនួន១៧នាក់ មកពីសាកលវិទ្យាល័យ Texas A&M International University បានធ្វើដំណើរទស្សនកិច្ចមកប្រទេសកម្ពុជា ក្នុងគោលបំណងមកទស្សនាសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងវិធីសាស្ត្រនៃការស្វែងរកសន្តិភាព ការផ្សះផ្សា និងការអភិវឌ្ឍន៍ប្រទេសកម្ពុជាសារឡើងវិញ នៅលើទឹកដីដែលធ្លាប់កើតមានអំពើហិង្សា និងការកាប់សម្លាប់យ៉ាងសាហាវឃោរឃៅ ក្នុងអំឡុងពេលនៃរបបខ្មែរក្រហម។

នៅក្នុងវិចិត្រសាលសិល្បៈសហសម័យនៃវិទ្យាស្ថានស្ទីកវីតនាថ្ងៃទី៣ ខែមករា ឆ្នាំ២០១៨ លោក ហ៊ឹម ហ៊ុយ អាយុ៦៣ឆ្នាំ គឺជាអតីតកម្មាភិបាលខ្មែរក្រហមដែលមានតួនាទីជាអ្នកយាមមន្ទីរសន្តិសុខស-២១ មានសេចក្តីក្លាហានចូលមកអង្គុយលើកៅអីឈើ១ស្ថិតនៅចំពីមុខនិស្សិតបរទេសជាច្រើននាក់ និងបានរៀបរាប់ពីដំណើរជីវិត និងរឿងរ៉ាវជាច្រើនដែលបានកើតឡើងចំពោះរូបគាត់និងក្រុមគ្រួសារ។ លោក ហ៊ឹម ហ៊ុយ ធ្លាប់បានរៀបរាប់អំពីបទពិសោធន៍ជីវិត


និស្សិតបរទេសថតរូបជុំគ្នានៅមុខវិចិត្រសាលសិល្បៈសហសម័យ នៃវិទ្យាស្ថានស្ទីកវីត

និងការងារដែលគាត់បានធ្វើនៅក្នុងរបបខ្មែរក្រហមជាច្រើន ដងកន្លងមកហើយទៅកាន់សាធារណជន អ្នកជិតខាង ក្រុមគ្រួសារ អ្នកកាសែត សិស្សនិស្សិតខ្មែរ និងបរទេសជាច្រើន នាក់មកពីប្រទេសផ្សេងៗដែលចង់ដឹងពីរឿងរ៉ាវរបស់គាត់ និងប្រវត្តិសាស្ត្រខ្មែរក្រហម។ លោក ហ៊ីម ហ៊ុយ ក៏ត្រូវបាន សាលាក្តីខ្មែរក្រហមកោះហៅឲ្យឡើងធ្វើជាសាក្សីនៅក្នុងសំណុំ រឿង០០១ ដែលមានជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរសន្តិសុខស-២១ ដែលទទួលខុសត្រូវលើ ការសម្លាប់អ្នកទោសប្រមាណជិតពីរម៉ឺននាក់នៅ (ឌុច ត្រូវ បានតុលាការកំពូលផ្តន្ទាទោសឲ្យជាប់គុកអស់មួយជីវិត នៅ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២)។

នៅក្នុងទឹកមុខក្រៀមក្រំ លោក ហ៊ីម ហ៊ុយ បាននិយាយ ថា «វាគឺជាប្រវត្តិសាស្ត្រដ៏អាក្រក់បំផុត ដែលបានធ្វើឲ្យបាត់ បង់ជីវិតមនុស្សអស់ជាងពីរលាននាក់ និងបន្សល់ទុកសុបិន ដ៏សែនអាក្រក់ពេញមួយជីវិតចំពោះអ្នកដែលធ្លាប់បានឆ្លង កាត់។ គាត់បានបន្តថា «ទោះបីជាខ្ញុំធ្លាប់ធ្វើការងារឲ្យខ្មែរ ក្រហម ប៉ុន្តែខ្ញុំមិនដែលខ្មាសអៀនក្នុងការនិយាយរឿងរ៉ាវ ទាំងអស់ទៅកាន់អ្នកដទៃទេ ព្រោះខ្ញុំយល់ឃើញថា ការលាក់ បាំងអំពីប្រវត្តិសាស្ត្រដ៏សែនសង្វេគនេះ គឺជារឿងរ៉ាវមួយដ៏ គ្រោះថ្នាក់បំផុត និងអាចបន្តឲ្យប្រវត្តិសាស្ត្រដ៏សែនគ្រោត គ្រាតនេះកើតឡើងម្តងទៀត។ ខ្ញុំគិតថាប្រវត្តិសាស្ត្រខ្មែរក្រហម គឺជារឿងអាទិភាពមួយដែលថ្នាក់ដឹកនាំ សិស្ស និស្សិត អ្នក ស្រាវជ្រាវ និងពិភពលោកទាំងមូល ត្រូវតែដឹង និងសិក្សា ស្រាវជ្រាវឲ្យបានស៊ីជម្រៅ។ ការស្វែងយល់ពីកំហុសអតីត កាល គឺជាចំណែកមួយជួយទប់ស្កាត់ការកើតឡើងវិញនៃ អំពើប្រល័យពូជសាសន៍»។ លោក ហ៊ីម ហ៊ុយ ក៏មិនស្ទាក់ ស្ទើរក្នុងការឆ្លើយតបទៅនឹងសំណួរជាច្រើនរបស់និស្សិត បរទេសដូចខាងក្រោម ៖

១) *តើលោកធ្លាប់បានទទួលប្រាក់ខែ ឬការឧបត្ថម្ភនៅ អំឡុងពេលដែលលោកបំពេញការងារឲ្យមេដឹកនាំ ខ្មែរក្រហមដែរឬទេ?*

២) *តើលោកធ្លាប់ទៅគុកទួលស្លែងដែរឬទេ បន្ទាប់ពីរ បបខ្មែរក្រហមបានដួលរលំ? ប្រសិនបើលោកធ្លាប់ ទៅទីនោះ តើលោកមានអារម្មណ៍យ៉ាងណាដែរ?*

៣) *តើលោកគិតថា លោកគឺជាជនរងគ្រោះនៅក្នុង សម័យខ្មែរក្រហមដែរឬទេ?*

៤) *តើនៅពេលដែលរបបខ្មែរក្រហមដួលរលំ តើលោក ធ្លាប់គិតថាចង់ចូលរួមតស៊ូជាមួយខ្មែរក្រហមទៀត ដែរឬទេ?*

៥) *តើលោកសម្រេចចិត្តចូលធ្វើជាកម្មាភិបាលខ្មែរ ក្រហមដោយសារអ្វី?*

៦) *នៅក្នុងអំឡុងពេលដែលលោកធ្វើការងារឲ្យខ្មែរ ក្រហម តើក្រុមគ្រួសាររបស់លោកបានទទួលការ ការពារជាពិសេសដែរឬទេ?*

៧) *តើលោកធ្លាប់និយាយរឿងរ៉ាវរបស់លោកប្រាប់ ក្រុមគ្រួសារដែរឬទេ?*

៨) *តើមានកត្តាអ្វីដែលបានជំរុញឲ្យលោកចូលធ្វើការ នៅមន្ទីរសន្តិសុខស-២១?*

៩) *នៅពេលដែលលោកដឹងថាខ្មែរក្រហមរំដោះបានទី ក្រុងភ្នំពេញ តើលោកមានអារម្មណ៍យ៉ាងណាដែរ?*

១០) *តើលោកបានធ្វើអ្វីខ្លះនៅក្នុងរបបខ្មែរក្រហម?*

១១) *តើលោកមានទំនាក់ទំនងដូចម្តេចជាមួយយោធាខ្មែរ ក្រហម និងអ្នកធ្វើការជាមួយគ្នានៅពេលនោះ?*

១២) *នៅពេលដែលលោកដឹកមនុស្សយកទៅកាន់វាល ពិឃាដជើងឯក តើលោកបានដឹងព័ត៌មានអ្វីខ្លះពីទី កន្លែងនោះ?*

១៣) *នៅក្នុងរបបខ្មែរក្រហម តើអ្វីដែលធ្វើឲ្យលោកខ្លាច ជាងគេ?*

១៤) *បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ តើលោកធ្លាប់ បានជួបអតីតកម្មាភិបាលខ្មែរក្រហមផ្សេងទៀត ដែរឬទេ? ប្រសិនបើបានជួប តើលោកមានទំនាក់ ទំនងបែបណាដែរ?*

១៥) នៅពេលដែលលោកបានឃើញខ្មែរក្រហមសម្លាប់មនុស្ស តើលោកគិតដូចម្តេចដែរ?

លោក ជុំ ម៉ី គឺជាជនរងគ្រោះនៃរបបខ្មែរក្រហម ដែលធ្លាប់បានឃុំឃាំង និងទទួលរងការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរនៅមន្ទីរសន្តិសុខស-២១ បានចូលរួមចែករំលែកបទពិសោធន៍របស់គាត់នៅក្នុងរបបខ្មែរក្រហមទៅកាន់និស្សិតបរទេស នៅក្នុងវិចិត្រសាលសិល្បៈសហសម័យនៃវិទ្យាស្ថានស៊្វីករីតដែរ។ លោក ជុំ ម៉ី បាននិយាយទៅកាន់និស្សិតបរទេសទាំងអស់ថា ក្នុងនាមគាត់គឺជាជនរងគ្រោះម្នាក់នៅក្នុងរបបខ្មែរក្រហម គាត់មានអារម្មណ៍សប្បាយចិត្តណាស់នៅពេលដែលគាត់បាននិយាយរឿងក្នុងចិត្តរបស់គាត់ទៅកាន់អ្នកដ៏ទៃដែលតែងតែឲ្យតម្លៃទៅលើជនរងគ្រោះដូចរូបគាត់ និងជាពិសេសគាត់សូមថ្លែងអំណរគុណទៅកាន់និស្សិតជនបរទេសមកពីសាកលវិទ្យាល័យ Texas A&M International University ដែលចង់ស្តាប់ និងស្វែងយល់អំពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់គាត់ និងប្រវត្តិសាស្ត្រដ៏ជូរចត់របស់ប្រទេសកម្ពុជា។ លោក ជុំ ម៉ី បានប្រាប់និស្សិតបរទេសទាំងអស់ថា «ខ្ញុំបានចូលរួមបំភ្លឺរឿងរ៉ាវដែលបានកើតឡើងចំពោះរូបខ្ញុំនៅក្នុងសាលាក្តីខ្មែរក្រហម ក្នុងគោលបំណងដាក់ទោសដល់មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ទាំងអស់ដែលបានដឹកនាំប្រទេសទៅរកភាពវិនាសអន្តរាយ»។ គាត់ក៏បានបន្ថែមថា ក្រៅពីការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺមានតែការអធ្យាស្រ័យគ្នាទៅវិញទៅមកទើបអាចឲ្យប្រទេសកម្ពុជារក្សាបាននូវសន្តិភាព និងភាពរីកចម្រើននាពេលអនាគត។ គាត់សង្ឃឹមថា សៀវភៅមួយក្បាលដែលបានសរសេរអំពីសាច់រឿងរបស់គាត់នៅក្នុងរបបខ្មែរក្រហម គឺជាសារមួយសម្រាប់ក្មេងៗជំនាន់ក្រោយ សិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រនៅក្នុងប្រទេសកម្ពុជា ថែមទាំងអាចចូលរួមចំណែកក្នុងការទប់ស្កាត់ការកើតឡើងនៃអំពើប្រល័យពូជសាសន៍នាពេលអនាគត។ ខាងក្រោមនេះគឺជាសំណួររបស់និស្សិតបរទេសបានសួរទៅកាន់លោក ជុំ ម៉ី ៖

១) តើលោកមានអារម្មណ៍ដូចម្តេចដែរនៅពេលដែល ប៉ុល ពត មិនត្រូវបាននាំយកមកកាត់ទោសតាមផ្លូវច្បាប់នៅសាលាក្តីខ្មែរក្រហម?

២) បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ តើលោកបានត្រឡប់មកទស្សនាទួលស្លែងវិញនៅពេលណា?

៣) តើមានកត្តាអ្វីខ្លះបានជំរុញឲ្យលោកទៅចូលរួមបំភ្លឺនៅសាលាក្តីខ្មែរក្រហម?

៤) នៅពេលដែលលោកបានឃើញអតីតកម្មាភិបាលខ្មែរក្រហម តើលោកមានអារម្មណ៍ដូចម្តេចដែរ?

៥) តើលោកអាចអធ្យាស្រ័យឲ្យខ្មែរក្រហមដែរឬទេ?

៦) តើលោកធ្លាប់ស្គាល់ ហ៊ឹម ហ៊ុយ ដែរឬទេ? តើលោកបានដឹងថា ឌុច បានបង្ខំឲ្យលោក ហ៊ឹម ហ៊ុយ ធ្វើការងារផ្សេងៗនៅទីនោះដែរឬទេ?

ក្រោមកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាកលវិទ្យាល័យ Texas A&M International University និស្សិតបរទេសទាំងអស់ក៏បានមកធ្វើការសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការស្វាគមន៍ពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជានិងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា។

លោក រស់ សំពៅ និងលោក ម៉ម សុផាត បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្ហាញអំពីឯកសារដែលមាននៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជា របៀបនៃការប្រមែប្រមូលឯកសារ ប្រភេទឯកសារ ការថែរក្សាឯកសារ ការរៀបចំទុកដាក់ឯកសារ ការប្រើប្រាស់ឯកសារ និងបញ្ហាប្រឈមចំពោះការប្រមែប្រមូលឯកសារ។ បន្ទាប់មក លោក អ៊ូច មករា បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានបញ្ចាំងខ្សែភាពយន្តឯកសារខ្លីៗចំនួនពីរគឺ ១)ឪពុករបស់ខ្ញុំនៅឋានសួគ៌ និង ២)ការឃោសនារបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៨។ បន្ថែមលើនេះ លោកស្រី សូ ហ្វារីណា បានធ្វើបទបង្ហាញទៅកាន់និស្សិតបរទេសទាំងអស់អំពី «បទពិសោធន៍របស់សហគមន៍ចាមនៅក្នុងរបបខ្មែរក្រហមនិងអំពើប្រល័យពូជសាសន៍

ប្រឆាំងនឹងជនជាតិចាម»។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានចូលរួមចែករំលែកបទពិសោធន៍របស់គាត់ក្នុងនាមជាជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម និងជាជនភៀសខ្លួនខ្មែរម្នាក់ទៅកាន់រដ្ឋតិចសាសនៃសហរដ្ឋអាមេរិក។ បន្ថែមពីនោះ លោកបានរៀបរាប់អំពីបេសកម្មរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលផ្តោតសំខាន់ទៅលើ ការចងចាំ និងយុត្តិធម៌។ លោកបាននិយាយថា «ប្រវត្តិសាស្ត្រខ្មែរក្រហម បានធ្វើឲ្យសង្គមខ្មែរជួបប្រទះនឹងភាពស្មុគស្មាញជាច្រើនរវាងជនរងគ្រោះ និងជនដៃដល់រហូតដល់សព្វថ្ងៃនេះ»។

បន្ទាប់ពីបានសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និស្សិតបរទេសទាំងអស់ បានទៅទស្សនាកោដនៅក្នុងវត្តលង្កា ដែលបានរកឃើញបន្ទាប់ពីសង្គ្រាម និងគ្មានសាច់ញាតិ។ ក្រៅពីនោះ ក្រុមនិស្សិត បានចូលរួមទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច ៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់អែនរ៉ូល» នៅក្នុងវិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស៊ីករីត គឺជាខ្សែភាពយន្តមួយដែលបានឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រពាក់ព័ន្ធនឹងភាពសម្បូរបែបនៃបទចម្រៀង និងតន្ត្រីខ្មែរ នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ និងឆ្នាំ១៩៧០ និងជាតន្ត្រីមួយដ៏ពេញនិយមក្នុងសម័យកាលនោះ។ ភាពយន្តឯកសារ «កុំស្មានបងភ្លេច» មិនត្រឹមបង្ហាញពីការរីកចម្រើនសិល្បៈបែបបស្ចិមប្រទេសនាសម័យនោះទេ ប៉ុន្តែក៏បានបង្ហាញពីសោកនាដកម្ម ភាពវន្ធត់តក់ស្លុតដែលខ្មែរក្រហមបានប្រព្រឹត្តទៅលើសិល្បករ និងប្រជាជនខ្មែរស្លូតត្រង់។ ដូចទៅនឹងទាហាន និងមន្ត្រីរដ្ឋការនៅក្នុងសង្គមចាស់ សិល្បៈក៏ជាគោលដៅបោសសម្អាតរបស់ក្រុមខ្មែរក្រហមដែរ។

**អ៊ុន សុដាវី**



និស្សិតបរទេសកំពុងទស្សនាខ្សែភាពយន្តឯកសារ កុំស្មានបងភ្លេច

# ព្រៃសហគមន៍សង្ឃរុក្ខវ័ន្ត គឺជាសម្បត្តិធម្មជាតិដ៏មានតម្លៃ

ព្រៃសហគមន៍សង្ឃរុក្ខវ័ន្តមានទំហំសរុប ៣០,២៥៦ ហិកតា លាតសន្ធឹងក្នុងស្រុកចំនួនបី រួមមាន ស្រុកសំរោង ស្រុកចុងកាល់ និងស្រុកអន្លង់វែង។ ព្រៃនេះត្រូវបានចាត់ចូលជាព្រៃដែលទទួលបានការពារតាមរយៈអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា។

ព្រះតេជគុណ ប៊ុន សាលួត ដែលជាមេគុណខេត្តឧត្តរមានជ័យ មានសង្ឃដីកាថា «តំបន់ព្រៃសហគមន៍សង្ឃរុក្ខវ័ន្ត គឺជាព្រៃសេសសល់ចុងក្រោយនៃខេត្តឧត្តរមានជ័យ»។ ព្រះអង្គមានសង្ឃដីកាបន្ថែមថា ពីមុនតំបន់ព្រៃសង្ឃរុក្ខវ័ន្ត ត្រូវបានទន្ទ្រាន និងការកាប់លក់ទៅឲ្យឈ្មួញ ធ្វើឲ្យព្រៃឈើនៅតំបន់នេះចាប់ផ្តើមរេចរឹលបន្តិចម្តងៗ ហើយជម្រកសត្វព្រៃក៏បានបាត់បង់ជាបណ្តើរៗដែរ។ ដូច្នេះព្រះអង្គក៏ស្ម័គ្រចិត្តចូលបម្រើការងារថែរក្សាព្រៃនេះ និងបានបំពេញឯកសារទៅស្ថាប័នពាក់ព័ន្ធ ក្រសួង និងរដ្ឋាភិបាល ដើម្បីសុំសិទ្ធិការ



ព្រះតេជគុណ ប៊ុន សាលួត អ្នកអភិរក្សព្រៃសហគមន៍រុក្ខវ័ន្ត



ពារ ថែរក្សា និងអភិរក្សតំបន់ព្រៃសហគមន៍នេះ ចាប់តាំងពីឆ្នាំ២០០១ មក។ ព្រះអង្គបង្កើតកម្មវិធីផ្សេងៗតាមបែបសាសនា រួមមាន ការរៀបចំពិធីបុណ្យទាន ការបំបួសដើមឈើ ដើម្បីអប់រំ និងណែនាំប្រជាជនក្នុងសហគមន៍អំពីសារសំខាន់នៃព្រៃឈើ។ សព្វថ្ងៃ ព្រះអង្គសង់ទីស្នាក់ការចំនួន៧កន្លែងសម្រាប់ឃ្លាំមើលព្រៃឈើ ដោយទីស្នាក់ការនីមួយៗមានកម្លាំងយាមល្បាតចំនួន៣-៤នាក់ រួមមានទាំងព្រះសង្ឃ។

ទោះបីជាជួបបញ្ហាប្រឈមទាក់ទងនឹងការបំពេញការងារកន្លងមក ក៏ព្រះអង្គមិនដែលមានចិត្តរុញរា ឬចង់បញ្ឈប់សកម្មភាពរបស់ព្រះអង្គដែរ ព្រោះព្រះអង្គស្រឡាញ់ធម្មជាតិ និងចង់អភិរក្សតំបន់សហគមន៍ព្រៃសង្ឃរុក្ខវ័ន្តឲ្យក្លាយទៅជាតំបន់ទេសចរណ៍ចម្រុះដែលអាចទាក់ទាញភ្ញៀវទេសចរណ៍មកពីគ្រប់ទីកន្លែងឲ្យចូលមកដើរកម្សាន្តនៅក្នុងព្រៃនេះ។ ជិត ២០ឆ្នាំកន្លងមកនេះ ព្រះអង្គបានខិតខំអភិរក្សតំបន់សហគមន៍ព្រៃសង្ឃរុក្ខវ័ន្តនេះ ហើយជាលទ្ធផល សហគមន៍ព្រៃសង្ឃរុក្ខវ័ន្តក៏បានផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋដែលរស់នៅ និងអាស្រ័យផលពីអនុផលព្រៃឈើក្នុងតំបន់នេះចំនួន៩ភូមិ ស្មើនឹងជិតមួយរយគ្រួសារ។ ជាពិសេស តំបន់សហគមន៍ព្រៃសង្ឃរុក្ខវ័ន្តនេះ ក៏បានផ្តល់ជាទីជម្រកដល់សត្វព្រៃជាច្រើនសន្ធឹកសន្ធាប់ដែរ។ ព្រះអង្គសង្ឃឹមថា ប្រជាជន



ដើមស្រឡៅនៅក្នុងតំបន់សហគមន៍ព្រៃសង្ឃរុក្ខវ័ន្ត

កម្ពុជានឹងមានការយល់ដឹងច្រើនអំពីសារសំខាន់នៃព្រៃឈើ ព្រោះព្រៃឈើនិងមនុស្សត្រូវតែមានទំនាក់ទំនងនិងអាស្រ័យផលគ្នាទៅវិញទៅមក។ ព្រៃសហគមន៍សង្ឃរុក្ខវ័ន្តនឹងត្រូវបានការពារ និងថែរក្សាដោយយកចិត្តទុកដាក់ដើម្បីរក្សាទុកជាសម្បត្តិធម្មជាតិសម្រាប់កូនចៅជំនាន់ក្រោយ។

កាលពីមុន ព្រៃសហគមន៍សង្ឃរុក្ខវ័ន្ត ក៏ធ្លាប់ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមខ្មែរក្រហមដែរ។ យោធា កម្មាភិបាលខ្មែរក្រហម និងប្រជាជនដែលរត់គេចខ្លួនពីការវាយប្រហារពីសំណាក់កងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នៅឆ្នាំ១៩៧៩ បានរត់មកប្រមូលផ្តុំគ្នានិងរស់នៅក្នុងព្រៃនេះ។ ខ្មែរក្រហមបានកេណ្ឌប្រជាជនរាប់ម៉ឺននាក់ចូលមករស់នៅក្នុងព្រៃនេះ និងនៅលើជួរភ្នំដងរែក (លាតសន្ធឹងពីខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ) ឲ្យចូលជាយោធាដើម្បីវាយប្រយុទ្ធតទល់នឹងរដ្ឋាភិបាល។ តំបន់នេះមានទីតាំងភូមិសាស្ត្រល្អសម្រាប់ក្រុមខ្មែរក្រហមលាក់ខ្លួន ព្រោះសម្បូណ៌ទៅដោយព្រៃឈើក្រាស់ៗ និងជួរភ្នំវែងអន្លាយ។ នៅអំឡុងពេលនោះ ខ្មែរក្រហមក៏បានកាប់ឈើពីក្នុងព្រៃនេះដើម្បីយកមកសាងសង់ផ្ទះសម្រាប់យោធា សង់មូលដ្ឋានទ័ព ស្ពាន និងហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀត។ ក្រោយមក យោធាខ្មែរក្រហមបានចាប់ផ្តើមកាប់ព្រៃឈើកាន់តែច្រើនក្នុងគោលបំណងដោះដូរស្បៀងគ្រឿងឧបភោគ និងសម្ភារប្រើប្រាស់ ជាមួយឈ្មួញថៃ ដែលបណ្តាលឲ្យព្រៃឈើជាច្រើននៅតាមព្រំដែនកម្ពុជា-ថៃរួមមានស្រុកអន្លង់វែង ស្រុកសំរោង និងស្រុកចុងកាល់ បាត់បង់ជាបន្តបន្ទាប់។

ក្រោយមក ដោយសារតម្រូវការឈើ និងការជួញដូរឈើកាន់តែច្រើនឡើងធ្វើឲ្យព្រៃនៅក្នុងតំបន់ព្រៃសហគមន៍នេះទទួលរងគ្រោះកាន់តែខ្លាំងតាមរយៈការកាប់រំលំ ទោះបីមានវិធានការការពារជាបន្តបន្ទាប់ពីអាជ្ញាធរ និងរដ្ឋាភិបាលក៏ដោយ។

ព្រៃឈើបានផ្តល់ផលប្រយោជន៍ជាច្រើនដល់មនុស្ស និងជម្រកសត្វព្រៃ។ ព្រៃឈើមានតួនាទីយ៉ាងសំខាន់ក្នុងការជួយថែរក្សាដំណើរការប្រព័ន្ធអេកូឡូស៊ី និងជួយកាត់បន្ថយឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ដូចជា ទឹកជំនន់ ខ្យល់ព្យុះ និងស្រូបយកឧស្ម័នកាបូនិចពីបរិយាកាស។ ព្រៃឈើ គឺជាសម្បត្តិធម្មជាតិដ៏មានតម្លៃ ដែលទំនាក់ទំនងជាមួយនឹងការរស់នៅប្រចាំថ្ងៃរបស់មនុស្ស និងសត្វ ដូច្នេះ ទាមទារឲ្យមានការចូលរួម ការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយវិចារណញ្ញាណ ដើម្បីធានានូវតុល្យភាពបរិស្ថាន ព្រមទាំងផ្តល់ឱកាសដល់កូនចៅជំនាន់ក្រោយទទួលបានផលប្រយោជន៍ពីធនធានទាំងអស់នេះ។ ព្រៃឈើបានរក្សាលំនឹងបរិស្ថានធម្មជាតិ និងសម្រស់ស្រស់បំព្រងពណ៌បៃតង ព្រមទាំងបានបម្រើដល់វិស័យទេសចរណ៍ផងដែរ។

ហូ ផុនា

## ដំណឹងស្វែងរកពូ

នាងខ្ញុំឈ្មោះ ឡូរ៉ា សាន។ ម្តាយរបស់នាងខ្ញុំឈ្មោះ សាន ង៉ែត មកពីខេត្តកំពង់ចាម។ គាត់មានបងស្រីម្នាក់ដែលបានជួបគ្នានៅមុនពេលបងស្រីរបស់គាត់បានស្លាប់ទៅ។ ប៉ុន្តែ ម្តាយនាងខ្ញុំនៅតែមានចម្ងល់អំពីប្អូនរបស់គាត់ម្នាក់ ដែលខ្ញុំមិនដឹងប្រកបតាមភាសាអង់គ្លេសយ៉ាងណានោះទេ គ្រាន់តែដឹងថាអាចជាឈ្មោះ សារុន ឬ សារឿន និងត្រកូល ង៉ែត។ ព័ត៌មានមួយទៀត ដែលអាចជួយបង្ហាញអត្តសញ្ញាណរបស់គាត់ គឺគាត់បានត្រឡប់មករៀននៅវិទ្យាល័យពោធិ៍វាល មួយរយៈ។ ម្តាយរបស់ខ្ញុំបាននិយាយថា មកដល់បច្ចុប្បន្ន ពូរបស់ខ្ញុំមានអាយុជាង៥០ឆ្នាំហើយ។ ប៉ុន្តែមានរឿងមួយ គឺម្តាយខ្ញុំបានប្រាប់ខ្ញុំថា ពូរបស់ខ្ញុំអាចត្រូវបាននាំទៅប្រទេសថៃ។

ដូច្នេះប្រសិនបើបងប្អូនណាបានស្គាល់ពូរបស់ខ្ញុំ សូមទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ទូរសព្ទលេខ ០២៣ ២១១ ៨៧៥។

សូមអរគុណ!

# ដំណឹងជ្រើសរើសនិស្សិតស្ម័គ្រចិត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសនិស្សិតស្ម័គ្រចិត្តចំនួន០៥រូប (អ្នកសរសេរអត្ថបទ ២រូប អ្នកបកប្រែ ២រូប និងក្រាហ្វិកកុំព្យូទ័រ ១រូប) ក្នុងចំណោមនិស្សិតសាកលវិទ្យាល័យនានាឲ្យមកបម្រើការងារចាប់ពីខែមេសា ឆ្នាំ២០១៩ ដល់ខែឧសភា ឆ្នាំ២០១៩ ហើយអាចបន្តទៅតាមគុណភាពការងារ។

១) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការបកប្រែអត្ថបទពីភាសាអង់គ្លេសមកជាភាសាខ្មែរ ឬពីភាសាខ្មែរទៅភាសាអង់គ្លេស។ អត្ថបទដែលនឹងត្រូវបកប្រែគឺអត្ថបទខ្លីនិងវែង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ ច្បាប់ និងអត្ថបទពិភាក្សានានា សរសេរដោយមេធាវី សាស្ត្រាចារ្យ អ្នកស្រាវជ្រាវបរទេស ឬសរសេរ ដោយប្រជាជនកម្ពុជា។

២) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការសរសេរអត្ថបទ សម្រាប់បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តី «ស្វែងរកការពិត» និងគេហទំព័រ http://www.khmerrougehistory.org

៣) អ្នកក្រាហ្វិកកុំព្យូទ័រ ឬរចនាទស្សនាវដ្តី តម្រូវឲ្យចេះប្រើប្រាស់កម្មវិធី InDesign និងកម្មវិធីផ្សេងៗទៀត ដែលទាក់ទងនឹងការរចនាទស្សនាវដ្តី។

ក្នុងអំឡុងពេលធ្វើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និស្សិតស្ម័គ្រចិត្តទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យចូលរួមវគ្គបណ្តុះបណ្តាល និងបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានា ដែលជាដៃគូសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជា ព្រះរាជាណាចក្រថៃ ហ្វីលីពីន ហុងកុង ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ជាដើម។

**លក្ខខណ្ឌសម្រាប់និស្សិតដែលអាចដាក់ពាក្យបាន មានដូចខាងក្រោម ៖**

១) និស្សិតកំពុងសិក្សាតាមសាកលវិទ្យាល័យរដ្ឋ និងឯកជននានា ដែលអាចប្រើប្រាស់ភាសាអង់គ្លេស។

២) មានអត្តចរិតថ្លៃថ្នូរ ម៉ឺងម៉ាត់ ព្យាយាម និងមានទំនួលខុសត្រូវចំពោះការងារ។

៣) មានចំណាប់អារម្មណ៍ផ្នែកការងារប្រវត្តិសាស្ត្រ ច្បាប់ និងសារព័ត៌មាន។

និស្សិតដែលមានលក្ខណៈសម្បត្តិដូចខាងលើ ហើយមានចំណាប់អារម្មណ៍នឹងការងារស្ម័គ្រចិត្តនេះ សូមផ្ញើពាក្យសុំបម្រើការងារមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង៥ល្ងាច។

**សូមភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖**

១) លិខិតសុំធ្វើការងារ ១ច្បាប់ (Cover Letter) ដោយបញ្ជាក់អំពីទឹកចិត្តផ្ទាល់ខ្លួនចំពោះការងារឲ្យបានច្បាស់លាស់ និងក្បោះក្បាយ ដែលសរសេរដោយសាម៉ីខ្លួន។

២) ប្រវត្តិរូបសង្ខេប ១ច្បាប់ (Resume)។

សូមផ្ញើមកកាន់អាសយដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬ អ៊ីម៉ែល៖ truthbunthorn.s@dccam.org។ ប្រសិនបើមានចម្ងល់ សូមទូរសព្ទមកលេខ៖ ០២៣ ២១៨ ០០៩ ឬ ០១២ ៩៩៦ ៧៥០។

**សូមអរគុណ!**

# គេហទំព័រ «ទីចងចាំ» លើកឡើងអំពីប្រវត្តិសាស្ត្រ ការពិភាក្សា និងការផ្សះផ្សាក្នុងសង្គម

ការទទួលបាននូវព័ត៌មានថ្មីទាក់ទងនឹងសង្គម និងការអប់រំ គឺជាតម្រូវការចាំបាច់បំផុតសម្រាប់ប្រជាជនកម្ពុជា។ ព័ត៌មានថ្មីៗទាំងនេះក៏ជួយដល់ផ្នត់គំនិត និងការអភិវឌ្ឍន៍សង្គមជាតិដែរ។ ការផ្តល់ជូននូវព័ត៌មានទៅកាន់សាធារណជន មានមធ្យោបាយច្រើនយ៉ាង ដូចជា ទូរទស្សន៍ វិទ្យុ កាសែត និងទស្សនាវដ្តីដែលត្រូវបានចាត់ទុកថាជាផ្នែកមួយនៃប្រភពព័ត៌មាន។ មកដល់សតវត្សរ៍ទី២១នេះមានការរីកចម្រើនយ៉ាងខ្លាំងគួរឲ្យកត់សម្គាល់នៃប្រព័ន្ធបច្ចេកវិទ្យា ជាពិសេសប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមអ៊ីនធឺណែត។

បច្ចេកវិទ្យាព័ត៌មានតាមអ៊ីនធឺណែតបានផ្តល់សារសំខាន់ និងធ្វើឲ្យមានភាពងាយស្រួលដល់សាធារណជន ដែលចង់សិក្សាស្វែងយល់អំពីហេតុការណ៍វិវឌ្ឍន៍របស់សង្គមថ្មីៗ រួមទាំងព្រឹត្តិការណ៍ដែលបានកើតឡើង ក្នុងពេលអតីតកាល។ ដោយយល់ឃើញអំពីសារសំខាន់នៃបច្ចេកវិទ្យាព័ត៌មាន ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា បង្កើតកម្មវិធីទូរសព្ទ និងគេហទំព័រមួយដែលមានឈ្មោះថា «ទីចងចាំ» ឬ Mapping Memories Cambodia។ សាធារណជន និងអ្នកសិក្សាស្រាវជ្រាវអាចចូលមើលគេហទំព័រនេះតាមរយៈប្រព័ន្ធអ៊ីនធឺណែត ឬអាចទាញយកកម្មវិធីនេះពី (App or play store) មកដាក់នៅលើទូរស័ព្ទដើម្បីអាន។

គេហទំព័រ «ទីចងចាំ» ឬ Mapping Memories Cambodia និងកម្មវិធី (App or play store) នៅលើទូរស័ព្ទត្រូវបានសម្ពោធឲ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៩នៅក្នុងបរិវេណនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ



ពិធីសម្ពោធកម្មវិធីទូរសព្ទ និងគេហទំព័រ «ទីចងចាំ»

*ដោយមានការចូលរួមជាគណៈអធិបតីពីលោក សោម រតនា សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, លោក ស្រី ដូលា អ៊ីស អ្នកសម្របសម្រួលកម្មវិធីសន្តិភាពស៊ីវិល យុត្តិធម៌ និងការផ្សះផ្សានៅក្នុងបរិបទនៃសាលាក្តីខ្មែរក្រហម, លោកស្រី សូ ហ្វារីណា នាយករងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ភ្ញៀវកិត្តិយស សាស្ត្រាចារ្យ សិស្ស និងនិស្សិត ប្រមាណជា២៥០នាក់។ កម្មវិធីទូរសព្ទដៃ និងគេហទំព័រ «ទីចងចាំ» បានផ្តល់ជូននូវភាពងាយស្រួលដល់សាធារណជន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ រួមទាំងភ្ញៀវទេសចរណ៍អាចកំណត់ទីតាំងប្រវត្តិសាស្ត្រនៅក្នុងរបបខ្មែរក្រហម។ នៅក្នុងគេហទំព័រនេះក៏មានវីដេអូ បង្ហាញអំពីរឿងរ៉ាវអតីតកាលដែលទាក់ទងនឹងសកម្មភាពជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជន នៅក្នុងរបបខ្មែរក្រហមពីសំណាក់អ្នករស់រានមានជីវិត។*

*នៅក្នុងឱកាសនៃការសម្ពោធគេហទំព័រ «ទីចងចាំ» ក៏មានការរៀបចំសម្តែងរបាំផ្កាស្លា ក្រោមចំណងជើងថា«អន្លង់ជីវិត»។ របាំនេះនិយាយអំពីការរៀបការដោយបង្ខំរបស់ប្រជាជនកម្ពុជាដែលរស់នៅក្នុងរបបខ្មែរក្រហម។ ក្រៅពីនេះក៏មានការដាក់តាំងពិព័រណ៍រូបថតអំពីទិដ្ឋភាពក្នុងរបបខ្មែរក្រហម និងគំនូរស្តីពីជីវិតប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាក្នុងរបបខ្មែរក្រហម។ បន្ទាប់មក ក្រុមនិស្សិតនៃដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ ក៏បានចាក់បញ្ចាំងខ្សែភាពយន្តឯកសារខ្លីៗទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ រួមមាន ៖ «អាងត្រពាំងថ្មរ» គឺជាខ្សែភាពយន្តឯកសារដែលបានបង្ហាញអំពីទុក្ខលំបាកវេទនារបស់ប្រជាជនកម្ពុជា ដែលត្រូវបានខ្មែរក្រហមបញ្ជាឲ្យធ្វើការងារដោយបង្ខំ ទាំងថ្ងៃទាំងយប់ដើម្បីលើកទំនប់ដ៏ធំមួយនៅក្នុងអំឡុងឆ្នាំ១៩៧៦ ដើម្បីបម្រើវិស័យកសិកម្ម។ ក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ*



*ការសម្តែងរបាំនៅក្នុងពិធីសម្ពោធកម្មវិធីទូរសព្ទ និងគេហទំព័រ «ទីចងចាំ»*

១៩៧៩ «អាងត្រពាំងថ្ម» បានក្លាយជាកន្លែងចាប់អារម្មណ៍សម្រាប់មើលប្រភេទសត្វបក្សី ជាជាងទីកន្លែងចងចាំនៃប្រវត្តិសាស្ត្រដ៏ជូរចត់។ ខ្សែភាពយន្តឯកសារបន្ទាប់មានចំណងជើងថា «កោះតាង» ដែលជាអតីតមូលដ្ឋានកងទ័ពជើងទឹករបស់កម្ពុជា។ បន្ទាប់ពីយោធាខ្មែរក្រហមទទួលបានជ័យជម្នះលើកងទ័ព លន់ នល់ នៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានបញ្ជូនយោធារបស់ខ្លួនឲ្យទៅឈរជើងនៅកោះតាងដើម្បីយាមល្បាតដែនសមុទ្រកម្ពុជា។ អំឡុងពេលនោះ យោធាខ្មែរក្រហមក៏បានប្រទះឃើញកប៉ាល់ម៉ាយ៉ាហ្គេរបស់សហរដ្ឋអាមេរិកនៅទីនោះ ជាហេតុបង្កឲ្យមានការប៉ះទង្គិចគ្នា និងបណ្តាលឲ្យយោធាទាំងសងខាងស្លាប់រាប់រយនាក់។ ចំណែកខ្សែភាពយន្តឯកសារមានឈ្មោះថា «រឮក» និយាយអំពីបុរសម្នាក់ឈ្មោះ សយ សែន គឺជាអ្នកដែលរស់រានមានជីវិតពីគុកក្រាំងតាចាន់។ សែន តែងនឹករឭកដល់បុរសម្នាក់ឈ្មោះ ឆេន គឺជាអ្នកជួយជីវិតរបស់គាត់ឲ្យរួចផុតពីការសម្លាប់ពីសំណាក់យោធាខ្មែរក្រហម។ ភាពយន្តឯកសារមួយទៀតមានឈ្មោះ «សមរភូមិក្នុងប្រាសាទ»។ ក្រុមនិស្សិតដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ បានលើកយកប្រាសាទបេងមាលា គឺជាតំបន់ប្រយុទ្ធខ្លាំងក្លាក្នុងចំណោមតំបន់ប្រាសាទផ្សេងៗក្នុងខេត្តសៀមរាប ក្នុងសម័យខ្មែរក្រហម។ សង្គ្រាមនេះបានបន្តរហូតដល់ឆ្នាំ១៩៩៧ ទើបបានបញ្ចប់ទាំងស្រុង។ សង្គ្រាមបានបង្កឲ្យប្រាសាទបេងមាលារងការខូចខាតយ៉ាងដំណំ គួរជាទីស្តាយស្រណោះក្រៃលែង។ ចំណែកភាពយន្តឯកសារដែលបានចាក់បញ្ចាំងចុងក្រោយនៅក្នុងថ្ងៃសម្ពោធកម្មវិធីទូរសព្ទ និងគេហទំព័រ «ទីចងចាំ» គឺមានឈ្មោះ «ព្រំដីដែលបាត់ទៅ»។ ភាពយន្តឯកសារនេះបានបង្ហាញអំពីព្រំប្រទល់ដីនៃសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង (អតីតមន្ទីរសន្តិសុខស-២១) ដែលមានទំហំរួមតូចជាងទំហំដីនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ ភាពយន្តឯកសារទាំងនេះជាស្នាដៃផលិតរបស់ក្រុមនិស្សិតនៃដេប៉ាតឺម៉ង់ ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ ដែលបានចុះធ្វើការសិក្សាស្រាវជ្រាវនៅតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា ដើម្បីថតជាខ្សែភាពយន្តឯកសារ។

បើតាមលោក អ៊ុង ប៊ុនអ៊ី ប្រធានស្តីទីដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍បានឲ្យដឹងថា ៖ ការខិតខំប្រឹងប្រែងបង្កើតកម្មវិធីតាមទូរសព្ទដៃ និងគេហទំព័រ «ទីចងចាំ» របស់ក្រុមនិស្សិតដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍សម្រាប់សាធារណជន នឹងបង្កឲ្យមានភាពងាយស្រួលក្នុងការអានសិក្សាស្រាវជ្រាវនិងជំរុញឲ្យយុវជនជំនាន់ក្រោយកាន់តែចាប់អារម្មណ៍ទៅលើការសិក្សាប្រវត្តិសាស្ត្រ ក្នុងរបបខ្មែរក្រហម។ ប្រធានបទស្តីអំពីរបបខ្មែរក្រហមត្រូវបានផលិតយ៉ាងយកចិត្តទុកដាក់ហើយត្រូវបានបង្ហាញជាទម្រង់ពហុប្រព័ន្ធផ្សព្វផ្សាយ ដែលអាចប្រើប្រាស់បាននៅក្នុងវេទិកាពីរគឺ ៖ កម្មវិធីទូរសព្ទដៃ និងគេហទំព័រ។ ប្រវត្តិសាស្ត្រខ្មែរក្រហមគឺជាប្រធានបទមួយដែលលេចឡើងម្តងហើយម្តងទៀតសម្រាប់កិច្ចការនិស្សិតរបស់យើង ក្នុងអំឡុងពេលសិក្សារបស់ពួកគេ។ ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍ គិតថា ការបន្តការសន្ទនាអំពីប្រវត្តិសាស្ត្រខ្មែរក្រហមគឺជាការសំខាន់។

បញ្ហាជាច្រើននៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្នមានឫសគល់ចេញពីសោកនាដកម្មដែលបានកើតឡើងនៅរបបខ្មែរក្រហម។ យុវជនជំនាន់ក្រោយត្រូវរៀនពីអតីតកាលរបស់ប្រទេសកម្ពុជាដើម្បីយល់ថាអតីតកាលមានឥទ្ធិពលលើជីវិតរស់នៅ និងសង្គមរបស់ពួកគេនាពេលបច្ចុប្បន្ន។ ការសន្ទនាគឺជាឧបករណ៍ដ៏សំខាន់មួយដល់ការរៀនសូត្ររបស់សាធារណជន និងការផ្សះផ្សាអតីតកាលជាមួយបច្ចុប្បន្ន។

យើងជឿថាការទទួលបានព័ត៌មាន និងរឿងរ៉ាវប្រវត្តិសាស្ត្រខ្មែរក្រហម គឺជាយន្តការចម្បងបំផុតមួយជំរុញឲ្យមានការជជែកពិភាក្សាគ្នាអំពីអតីតកាលរបស់កម្ពុជា។ ដើម្បីចែករំលែកព័ត៌មាន យើងបានកត់សម្គាល់ពីសារសំខាន់នៃបច្ចេកវិទ្យា ដែលដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សង្គមនាពេលបច្ចុប្បន្ន។ ដោយសារប្រជាជនកម្ពុជាភាគច្រើនសុទ្ធតែ

មានទូរសព្ទស្មាតហ្វូនដែលភ្ជាប់ប្រព័ន្ធអ៊ីនធឺណែត ការផ្សព្វផ្សាយតាមរយៈកម្មវិធីទូរសព្ទដៃ និងគេហទំព័រ គឺជាឧបករណ៍ដែលសមស្រប និងងាយស្រួលប្រើប្រាស់បំផុតសម្រាប់អ្នកប្រើប្រាស់។

តាមរយៈការចងក្រង និងការផលិតសាច់រឿងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលមានខ្លឹមសារងាយយល់ និងគួរឲ្យចាប់អារម្មណ៍ យើងសង្ឃឹមថានឹងអាចទាក់ទាញយុវជនជំនាន់ក្រោយឱ្យចាប់ផ្តើមសិក្សា និងពិភាក្សាអំពីប្រវត្តិសាស្ត្រដ៏ជូរចត់ដែលប្រទេសយើងបានឆ្លងកាត់។ ការសិក្សាអំពីរបបប្រល័យពូជសាសន៍នេះ នឹងជំរុញឲ្យយុវជនជំនាន់ក្រោយកសាងសង្គមមួយដែលមានសន្តិភាព។

កម្មវិធីទូរសព្ទ និងគេហទំព័រ «ទីចងចាំ» មិនត្រឹមតែលាតត្រដាងអំពីប្រវត្តិសាស្ត្រក្នុងរបបខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានជំរុញឲ្យមានការពិភាក្សា និងការផ្សះផ្សាក្នុងអន្តរជំនាន់ (ប្រជាជនដែលបានឆ្លងកាត់របបខ្មែរក្រហម និងប្រជាជនដែលកើតក្រោយរបបខ្មែរក្រហម) តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដែរ។

បើតាមលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារដែលបានសហការ គាំទ្រ ប្រឹក្សាយោបល់ក្នុងការបង្កើតគម្រោង «ទីចងចាំ» បានមានប្រសាសន៍ថា ៖ ជួនកាលវាអាចមានភាពស្មុគស្មាញដែលមិនចាំបាច់មួយរវាងសកម្មភាពអ្នកស្រុកអ្នកភូមិ និងបច្ចេកវិទ្យា។ សកម្មភាពអ្នកស្រុកអ្នកភូមិកើតចេញពីកម្លាំងរបស់បុគ្គលទាំងឡាយ សហគមន៍ ការសម្រេចចិត្តមួយរួមគ្នា និងអំណាចនៅទីនោះ។ បច្ចេកវិទ្យាមិនត្រូវបានចងភ្ជាប់ទៅនឹងវប្បធម៌ជាក់លាក់ណាមួយ យុទ្ធសាស្ត្ររបស់អង្គការ ឬក៏ការចាត់ចែងអំណាចណាមួយឡើយ។

បច្ចេកវិទ្យាគឺមិនប្រកាន់របបនយោបាយ មិនគិតអំពីកម្រិតសីលធម៌ មិនកំណត់ដោយនិយមន័យហើយតែងតែមានការផ្លាស់ប្តូរជានិច្ច។ មិនត្រឹមតែបុគ្គលម្នាក់ៗនោះទេ ដែលមានភាពរុញរាក្នុងទទួលយកការហូរចូលនៃប្រព័ន្ធបច្ចេកវិទ្យា អង្គការទាំងឡាយណាដែលស្ថិតនៅក្នុងស្ថានភាពលំបាកក៏ជួបប្រទះរឿងបែបនេះដែរ។ វាលំបាកក្នុងការទទួលយកបច្ចេកវិទ្យាដែលមិនធ្លាប់មានពីមុនមកនៅក្នុងបរិបទសង្គមមួយ ដែលទម្លាប់ទៅនឹងកាលៈទេសៈ និងចិត្តគំនិតអភិរក្សនិយមអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយនោះ។ ប៉ុន្តែទោះបីជាមានភាពលំបាកយ៉ាងណាក៏ដោយ ក៏ខ្ញុំជឿជាក់ដែរថា សកម្មភាពអ្នកស្រុកអ្នកភូមិ គឺចាំបាច់ត្រូវការប្រព័ន្ធបច្ចេកវិទ្យាដើម្បីរីកចម្រើន ហើយមិនត្រឹមតែនៅក្នុងប្រទេសកម្ពុជាមួយតែប៉ុណ្ណោះទេ ប៉ុន្តែគឺនៅទូទាំងសកលលោក។

បច្ចេកវិទ្យាគឺជាពិភពលោកថ្មីមួយ ដែលបង្កើតឡើងសម្រាប់មនុស្សជំនាន់ក្រោយនៅក្នុងប្រទេសកម្ពុជា។ បច្ចេកវិទ្យាអាចធ្វើឲ្យអ្នកស្រុកអ្នកភូមិទទួលបាននូវព័ត៌មានថ្មីៗអំពីរបបខ្មែរក្រហម និងសំខាន់បំផុតគឺអាចធ្វើឲ្យគាត់មានសមត្ថភាពក្នុងការធ្លើងឆ្លល់ អំពីកាលៈទេសៈនាពេលបច្ចុប្បន្ន និងធ្វើការប្រៀបធៀបវាជាមួយនឹងអតីតកាលរបស់គាត់។

គម្រោងនេះ គឺជាជំហានដំបូងសម្រាប់កិច្ចខិតខំប្រឹងប្រែងក្នុងការផ្សាភ្ជាប់បុគ្គលទាំងឡាយក្នុងភូមិស្រុកនិងសហគមន៍ជាមួយនឹងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា។ គម្រោងនេះគឺមិនត្រឹមតែជាឧបករណ៍ដ៏សំខាន់ក្នុងការរៀនសូត្រអំពីរឿងរ៉ាវរបស់បុគ្គលនិងប្រវត្តិសាស្ត្ររួមមួយតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ឲ្យមានការពិភាក្សាលើសំណួរសំខាន់ៗដែលទាក់ទងទៅនឹងការអភិវឌ្ឍន៍សង្គមកម្ពុជាក្រោយពីជម្លោះ។

តើការអត់ឃ្លាន ពលកម្មដោយបង្ខំ ឃាតកម្ម និងអំពើសាហាវឃោរឃៅបានធ្វើឲ្យសង្គម និងបុគ្គលដែលបានរស់រានមានជីវិតមានការផ្លាស់ប្តូរយ៉ាងដូចម្តេចខ្លះ?

តើយើងអាចរៀនសូត្របានអ្វីខ្លះចេញពីការបំផ្លិចបំផ្លាញប្រទេសជាតិ សហគមន៍ និងបុគ្គលម្នាក់ៗ?

តើអតីតកាលអាចបង្ហាញអ្វីខ្លះអំពីការតស៊ូរបស់យើងជាមួយនឹងបញ្ហានាពេលបច្ចុប្បន្ននេះ និងបញ្ហាប្រឈមនាពេលអនាគត?

តើជនរងគ្រោះគួរត្រូវបានយើងទាំងអស់គ្នាចងចាំយ៉ាងដូចម្តេច ហើយតើយើងអាចប្រាប់រឿងរ៉ាវរបស់ជនរងគ្រោះទៅដល់មនុស្សជំនាន់ក្រោយជាច្រើននាក់ដែលមិនធ្លាប់ឆ្លងកាត់សង្គ្រាម ការអត់ឃ្លាន ឬអំពើឃោរឃៅបានដោយរបៀបណា?

តើយើងអាចប្រើបច្ចេកវិទ្យាដើម្បីចូលរួម និងអភិវឌ្ឍន៍បុគ្គល និងសហគមន៍បានយ៉ាងដូចម្តេច?

តើសង្គមមួយអាចបង្កើតឧត្តមគតិថ្មីបានដែរឬទេ បន្ទាប់ពីមានអំពើប្រល័យពូជសាសន៍ និងអំពើសាហាវឃោរឃៅ?

គម្រោងនេះ គឺជាការចាប់ផ្តើមនៃកិច្ចខិតខំប្រឹងប្រែងដែលត្រូវការការចូលរួមពីសំណាក់ប្រជាជនកម្ពុជានៅតាមភូមិស្រុក និងសហគមន៍អន្តរជាតិដើម្បីទទួលបានជោគជ័យ។ ក្នុងខណៈពេលដែលតុលាការកាត់ទោសខ្មែរក្រហមចាប់ផ្តើមបិទសំណុំរឿងក្តីរបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ការតស៊ូរបស់យើងដើម្បីយល់ និងរៀនសូត្រអំពីរបបខ្មែរក្រហមមិនត្រូវបញ្ចប់ទៅតាមដំណើរការរបស់តុលាការនោះទេ។ យើងមានការទទួលខុសត្រូវចំពោះមនុស្សជំនាន់ក្រោយ។ អនាគតរបស់យើង គឺអាស្រ័យទៅលើការយល់ដឹងអំពីអតីតកាលរបស់ខ្លួន។ ខ្ញុំសូមលើកទឹកចិត្តអ្នកទាំងអស់គ្នាឲ្យគាំទ្រគម្រោងមួយនេះតាមរយៈការចូលរួម និងចែករំលែករបស់អ្នក។ ការរួបរួមគ្នារបស់យើងអាចធ្វើឲ្យមានការផ្លាស់ប្តូរមួយដ៏ល្អបាន។

លោកស្រី ដូលា អ៊ីស អ្នកសម្របសម្រួលកម្មវិធីសន្តិភាពស៊ីវិល យុត្តិធម៌ និងការផ្សះផ្សានៅក្នុងបរិបទនៃសាលាក្តីខ្មែរក្រហមបានឲ្យដឹងថា ៖ ដូចលោក ឆាំង យុ បានលើកឡើងថាបច្ចេកវិទ្យា គឺ «មិនមានលក្ខណៈនយោបាយ, មិនអសីលធម៌ និងមានការផ្លាស់ប្តូរជានិច្ច។ ក្នុងនាមយើងជាសេវាសន្តិភាពស៊ីវិលរបស់កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ ដែលទទួលបានការគាំទ្រពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍អាល្លឺម៉ង់ ប្រើប្រាស់បច្ចេកវិទ្យាសារគមនាគមន៍ នៅពេលដែលវាសមស្របដើម្បីលើកទឹកចិត្តដល់ការផ្សះផ្សា។ ការផ្សះផ្សាអាចកើតមានឡើងនៅពេលដែលជនដែលបានរងទុក្ខ និងជនដែលមើលឃើញពីទុក្ខវេទនា សាច់ញាតិរបស់ពួកគេអាចនិយាយចេញ ហើយសេចក្តីត្រូវការរបស់ពួកគេត្រូវបានដឹងឮ និងបំពេញ។

បច្ចេកវិទ្យាបានផ្លាស់ប្តូរមធ្យោបាយដែលយើងទាក់ទងគ្នាទៅវិញទៅមក៖ ក្នុងន័យម្យ៉ាងបច្ចេកវិទ្យាសារគមនាគមន៍តាមអ៊ីនធឺណែតបើកទូលាយដល់មនុស្សគ្រប់ស្រទាប់នៃសង្គមភ្ជាប់ទំនាក់ទំនងគ្នាទៅវិញទៅមក ក្នុងការរស់នៅប្រចាំថ្ងៃក្នុងរូបភាពក្រៅផ្លូវការ ហើយប្រហែលជាមិនចាំបាច់មានភាពស្និទ្ធស្នាល ឬការប្តេជ្ញារវាងគ្នានោះឡើយ។

ផ្ទុយទៅវិញ មនុស្សដែលចែករំលែកការឈឺចាប់របស់ពួកគេជាមួយអ្នកដទៃ ដែលពួកគេប្រហែលជានឹងមិនដែលស្គាល់គ្នានោះ សាកសមនឹងទទួលបានការទទួលស្គាល់ និងការគោរពពីយើង។ ដើម្បីស្វែងរកតុល្យភាពត្រឹមត្រូវរវាងឱកាសថ្មី និងឧបសគ្គជាច្រើន ជាអ្វីដែលយើងកំពុងធ្វើនៅទីនេះ រួមគ្នាជាមួយដៃគូ មិត្តភក្តិ និងសហគមន៍និម្មិតរបស់យើង។ **ដារ៉ារដ្ឋ មេត្តា និង ដាត ចាន់សុនិតា**



កម្មវិធី និងគេហទំព័រ ទីចងចាំ នៅលើទូរស័ព្ទដៃ

# អត្ថន័យនៃល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ចំពោះខ្ញុំ

នៅពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះអំឡុងខែមេសាឆ្នាំ១៩៧៥ ប្រជាជនកម្ពុជាភាគច្រើន មានក្តីសង្ឃឹមថានឹងទទួលបាននូវសុខសន្តិភាពយ៉ាងពិតប្រាកដ។ ប៉ុន្តែជាអកុសល ប្រទេសកម្ពុជា បានធ្លាក់ចូលក្នុងកណ្តាប់ដៃក្រុមកុម្មុយនីស្តដ៏ឃោរឃៅមួយដែលមនុស្សជាតិស្គាល់ថា របបខ្មែរក្រហម បានដឹកនាំប្រទេសរវាងឆ្នាំ១៩៧៥ដល់១៩៧៩។ ខ្មែរក្រហមបានប្រើប្រាស់អំពើហិង្សាគ្រប់ប្រភេទសម្រាប់ដឹកនាំប្រទេសជាតិឲ្យដល់គោលដៅដែលខ្លួនចង់បាន។ ប្រជាជនបានទទួលរងការធ្វើបាប ការកាប់សម្លាប់ ព្រាត់ប្រាស់ និងបាត់បង់មនុស្សជាទីស្រឡាញ់ជារៀងរហូតដោយសារតែភាពអាត្មានិយមរបស់អ្នកដឹកនាំនៃរបបនេះ។ ទោះបីជារបបខ្មែរក្រហម បានទទួលបរាជ័យនៅក្នុងខែមករា ឆ្នាំ១៩៧៩ ក៏ដោយក៏របបនេះបានបន្សល់ទុកនូវស្នាមរបួសនិងអនុស្សាវរីយ៍ជាច្រើនដល់ប្រជាជនកម្ពុជារហូតដល់សព្វថ្ងៃ ថែមទាំងបានធ្វើឲ្យអ្នករស់រានមានជីវិតភាគច្រើនជួបប្រទះបញ្ហាដូចជា វិបត្តិផ្លូវចិត្ត គំនុំគុំគួន ភាពស្អប់ខ្ពើម ព្រមទាំងបានជះឥទ្ធិពលដល់ក្មេងៗជំនាន់ក្រោយដែរ។ ដោយសារតែផលប៉ះពាល់ទាំងអស់នេះ ទើបធ្វើឲ្យប្រជាជនកម្ពុជា ពិតជាត្រូវការការផ្សះផ្សាជាចាំបាច់ដើម្បីរស់នៅជាមួយគ្នាដោយសន្តិភាព។

ដើម្បីឆ្លើយតបទៅនឹងឥទ្ធិពលនៃបញ្ហាអតីតកាលនៅក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិបានបង្កើតតុលាការខ្មែរក្រហមដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់សម្រាប់ស្វែងរកយុត្តិធម៌ឲ្យប្រជាជនកម្ពុជារួមទាំងស្ថាប័នរដ្ឋ ឯកជន អង្គការសង្គមស៊ីវិលនានា ក៏បានសហការជំរុញដល់ដំណើរការផ្សះផ្សាដែលជាតម្រូវការទាំងអ្នករស់រានមានជីវិតបន្ទាប់ពីរបបខ្មែរក្រហម (ជនរងគ្រោះ) និងទាំងជនដៃដល់។

កាលពីថ្មីៗកន្លងទៅនេះ ខ្ញុំបានចូលរួមទស្សនាការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ស្ថិតនៅវិទ្យាស្ថានជាតិអប់រំក្នុងទីក្រុងភ្នំពេញ។ ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» គឺមិនមែនជាការសម្តែងលើកដំបូងនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែវត្តមាននៃការសម្តែងល្ខោននិយាយនេះម្តងទៀតនៅក្នុងឆ្នាំ២០១៩ បាននាំយកមកនូវទម្រង់ថ្មី គឺជាការបន្ថែមឈុត១ដ៏អស្ចារ្យសម្រាប់យុវវ័យជំនាន់ក្រោយ ដែលអាចស្វែងយល់ទាំងរឿងរ៉ាវអតីតកាលផ្សាភ្ជាប់មកពេលបច្ចុប្បន្ន។ តាមរយៈសិល្បៈល្ខោននិយាយនេះទៀតសោត ក៏បានលើកយកដំណោះស្រាយមួយចំនួន ដើម្បីទទួលបាននូវការផ្សះផ្សាសម្រាប់សង្គមមួយដែលធ្លាប់តែទទួលរងការបែកបាក់ពីអតីតកាលសម្រាប់ពេលវេលាបច្ចុប្បន្ន។ ចំពោះខ្ញុំផ្ទាល់ នេះជាលើកដំបូង ដែលខ្ញុំបានចូលរួមទស្សនារឿងល្ខោននិយាយសម្តែងអំពីប្រវត្តិសាស្ត្រខ្មែរក្រហមបែបនេះ។ ខ្ញុំពិតជាមានការចាប់អារម្មណ៍ខ្លាំងណាស់ ព្រោះសាច់រឿងល្ខោននេះ បានបង្ហាញពីមនោសញ្ចេតនា និងទាញយកអារម្មណ៍របស់ខ្ញុំចូលទៅក្នុងព្រឹត្តិការណ៍ ដែលបានកើតឡើងពីអតីតកាលចំពោះប្រទេសកម្ពុជាព្រមទាំងប្រជាជនកម្ពុជាដែរ។ ល្ខោននេះបានធ្វើឲ្យខ្ញុំយល់ដឹងកាន់តែច្រើនជាងមុនអំពីភាពខុសគ្នានៃទំនាក់ទំនងរបស់មនុស្សនៅក្នុងប្រទេសដែលកំពុងតែជួបបញ្ហា និងប្រទេសដែលស្ថិតក្នុងពេលវេលានៃសន្តិភាពមួយ។

ខ្ញុំគិតថាការសម្តែងល្ខោននេះបានផ្តល់ផលប្រយោជន៍ច្រើនដល់យុវវ័យជំនាន់ក្រោយចំពោះការបន្ថែមការយល់ដឹងមួយកម្រិតទៀតអំពីរឿងរ៉ាវប្រវត្តិសាស្ត្ររបស់ខ្លួន និងបញ្ហាដែលប្រជាជនកំពុងតែប្រឈមមុខសព្វថ្ងៃនេះ។

ក្នុងនាមខ្ញុំ គឺជាយុវវ័យជំនាន់ក្រោយ កើតក្នុងអំឡុងពេលដែលប្រទេសស្ថិតក្នុងសន្តិភាព គឺប្រវត្តិសាស្ត្រហាក់បីដូចជា

ស្ថិតក្នុងក្តីស្រមើស្រមៃតែប៉ុណ្ណោះ។ ទោះបីជា វាត្រឹមតែការស្រមើស្រមៃ ប៉ុន្តែវាបានធ្វើឲ្យខ្ញុំមានអារម្មណ៍តក់ស្លុតយ៉ាងខ្លាំងនៅពេលឮរឿងរ៉ាវទាំងអស់នេះ។ តើប្រជាជនកម្ពុជាដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហមផ្ទាល់ទទួលរងការឈឺចាប់អ្វីខ្លះ។ ខ្ញុំយល់ថា ការផ្សះផ្សាគឺជាកត្តាមួយយ៉ាងសំខាន់សម្រាប់ប្រទេសកម្ពុជាបច្ចុប្បន្ន ប៉ុន្តែវាទាមទារឲ្យមានការលះបង់ជាច្រើន ដូចជាការបោះបង់គំនុំ ការបេះអត់ខិន ការលើកលែងទោស និងការបេះគោរពគ្នាទៅវិញទៅមក។ ការផ្សះផ្សាជាតិ ក៏ចាំបាច់តម្រូវឲ្យមាននូវការស្វែងរកយុត្តិធម៌ និងការពិតដែរ។ យើងមិនត្រូវបំភ្លេចប្រវត្តិសាស្ត្រដ៏ដូចត់នេះទេ ប៉ុន្តែយើងត្រូវខិតខំធ្វើការសិក្សាស្រាវជ្រាវដើម្បីស្វែងរកឫសគល់នៃបញ្ហា និងចូលរួមទប់ស្កាត់ជំពូកខ្មៅងងឹតនេះ វិលមកសារជាថ្មីម្តងទៀត។

ចុងក្រោយ ខ្ញុំ សូមសំណូមពរឲ្យមានការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នេះឲ្យបានច្រើនកន្លែង ដូចជានៅតាមតំបន់ដាច់ស្រយាល តំបន់អតីតតស៊ូចុងក្រោយរបស់ខ្មែរក្រហម និងតាមសាលារៀន ដើម្បីបន្ថែមការយល់ដឹង និងការត្រិះរិះពិចារណាដល់អ្នកដែលបានចូលរួមទស្សនាបន្ថែមទៀត។

ព្រាំ គិតម៉ាន់ និស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច



តួអង្គកំពុងសម្តែងល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់

# អង្គជំនុំជម្រះសាលាដំបូង
# សេចក្តីសង្ខេបសាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

### *១.១. សេចក្តីផ្តើម និងប្រវត្តិសំណុំរឿងដោយសង្ខេប*

*១. ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០២។ សំអាងហេតុដែល មានអានុភាពតាមផ្លូវច្បាប់មានសរសេរនៅក្នុងសាលក្រមពេញលេញជាលាយលក្ខណ៍អក្សរ ដែលនឹងមានជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង នៅពេលវេលាសមស្របខាងមុខ។ ជាបញ្ហាបឋម អង្គជំនុំជម្រះកត់សម្គាល់ថា ក្នុងចំណោមបញ្ហាទាំងឡាយ ភាគីបានលើកឡើងអំពីបញ្ហានានាពាក់ព័ន្ធនឹងការជូនដំណឹងអំពីការចោទប្រកាន់ និងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះ ដោះស្រាយសំណើសុំទាំងអស់នេះដោយលម្អិតនៅក្នុងសាលក្រមពេញលេញជាលាយលក្ខណ៍អក្សរ។*

*២. សំណុំរឿង០០២ ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ នួន ជា និង ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ក្រោយពីសហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ដែលបានបញ្ចប់ការស៊ើបសួរតាមផ្លូវតុលាការដោយប្រើ រយៈពេលអស់ជិត ៣ឆ្នាំ មក នួន ជា និង ខៀវ សំផន ត្រូវបានបញ្ជូនមកជំនុំជម្រះ។ ដំបូងឡើយ សំណុំរឿងនេះមានរួមបញ្ចូលជនជាប់ចោទពីរនាក់ផ្សេងទៀតគឺ អៀង ធីរិទ្ធ និង អៀង សារី។ នៅក្នុងឆ្នាំ២០១១ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង អៀង ធីរិទ្ធ ត្រូវបានផ្អាក ហើយបទចោទប្រកាន់ទាំងឡាយប្រឆាំងនឹងរូបគាត់ត្រូវបានបំបែកចេញពីសំណុំរឿង បន្ទាប់ពីអង្គជំនុំជម្រះរកឃើញថាគាត់មិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការ ដោយសារតែជំងឺវង្វេងវង្វាន់ស្មារតីដែលចេះតែវិវត្តទៅមុខ។ អៀង ធីរិទ្ធ បានទទួលមរណភាពនៅក្នុងឆ្នាំ២០១៥។ អៀង សារី ដែលជាស្វាមីរបស់គាត់បានទទួលមរណភាពពីរឆ្នាំមុន ពោលគឺនៅដើមឆ្នាំ២០១៣។ មរណភាពរបស់ជនជាប់ចោទទាំងពីរនាក់នាំឲ្យរំលត់បណ្តឹងអាជ្ញា*



*ខៀវ សំផន នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*

និងបណ្ដឹងរដ្ឋប្បវេណីទាំងអស់ប្រឆាំងនឹងពួកគាត់នៅចំពោះមុខ អ.វ.ត.ក។

៣. សវនាការបឋមក្នុងសំណុំរឿង០០២ ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១។ នៅខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០២ ទៅជាការជំនុំជម្រះតូចៗមួយចំនួន ដោយសារតែទំហំ និងភាពស្មុគស្មាញនៃដីកាដំណោះស្រាយ ព្រមទាំងបញ្ហាវ័យចាស់ និងសុខភាពរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះសាលាដំបូងបានកម្រិតវិសាលភាពសម្រាប់ការជំនុំជម្រះវគ្គដំបូងនៃសំណុំរឿង០០២ (ដែលចាប់ពីពេលនោះមកត្រូវបានហៅថាជា «សំណុំរឿង០០២/០១») ត្រឹមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានចោទ ប្រកាន់ថា បានប្រព្រឹត្តពាក់ព័ន្ធនឹង៖ ទីមួយ ក្នុងអំឡុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ (ត្រូវបានហៅថាជា «ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១») និងទីពីរក្នុងអំឡុងក្នុងការផ្លាស់ទីលំនៅប្រជាជននៅតាមតំបន់ផ្សេងៗទៀតក្នុងប្រទេសកម្ពុជា ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ រហូតដល់ខែធ្នូ ឆ្នាំ១៩៧៧ (ត្រូវបានហៅថា ជា«ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២») និងចុងក្រោយ ទាក់ទងនឹងការចោទប្រកាន់អំពីការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។ អង្គជំនុំជម្រះបានកម្រិតវិសាលភាពសម្រាប់ជំនុំជម្រះវគ្គទីពីរនៅសំណុំរឿង០០២ (ត្រូវបានហៅថា «សំណុំរឿង០០២/០២») ត្រឹមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅតាមសហករណ៍ តាមការដ្ឋានការងារ តាមមន្ទីរសន្តិសុខនិងទីតាំងសម្លាប់មនុស្សមួយចំនួន (រួមទាំងមន្ទីរសន្តិសុខ-ស២១ និងជើងឯក) ពាក់ព័ន្ធនឹងការកំណត់តាមគោលដៅលើក្រុមមនុស្សជាក់លាក់មួយចំនួន គឺជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ការរៀបអាពាហ៍ពិពាហ៍ និងនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធជាមួយវៀតណាម។ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ អង្គជំនុំជម្រះ បានបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធអង្គហេតុផ្សេងទៀតនៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ដែលមិនត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង០០២/០១ ឬ សំណុំរឿង០០២/០២ នេះ។

៤. នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះបានចាប់ផ្ដើមដំណើរការសវនាការលើអង្គសេចក្ដី នៅក្នុងសំណុំរឿង០០២/០២។ ក្នុងអំឡុងសវនាការលើភស្តុតាងដែលមានរយៈពេល ២៨ខែ អង្គជំនុំជម្រះសាលាដំបូងបានស្ដាប់សក្ខីកម្មរបស់បុគ្គលចំនួន១៨៥នាក់ ដែលរួមមានសាក្សីចំនួន


នួន ជា នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

១១៨នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦៣នាក់ និងអ្នកជំនាញចំនួន៨នាក់។ ឯកសារភ័ស្តុតាងជិត៩.០០០ ឯកសារ ត្រូវបានយកមកពិនិត្យដេញដោល និងទទួលយកដាក់បញ្ចូលទៅក្នុងសំណុំរឿង ដោយសរុបទៅ ឯកសារទាំងបីភាសាជាផ្លូវការមានចំនួនជាង ៨២.០០០ទំព័រ នៅក្នុងសំណុំរឿង០០២/០២តែមួយ។ ដោយសារតែសំណុំរឿង០០២/០១ និង០០២/០២ មានលេខសំណុំរឿងដូចគ្នា ឯកសារភ័ស្តុតាងសរុបរួមមានចំនួនជាង១០.០០០ឯកសារ ដែលមានជាង៣០៤.០០០ទំព័រ។ សវនាការលើភ័ស្តុតាងក្នុងសំណុំរឿង០០២/០២ បានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ បន្ទាប់ពីបានបើកសវនាការអស់រយៈពេលចំនួន២៧៤ថ្ងៃ។ សេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់ការពិភាក្សាដេញដោលត្រូវបានធ្វើឡើងនៅក្នុងខែមិថុនា ឆ្នាំ២០១៧។

## ១.២. ការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ

៥. នៅក្នុងអំឡុងចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ នួន ជា ត្រូវបានចោទប្រកាន់ថា ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមនិងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ជាប្រធានសភាតំណាងប្រជាជន ហើយពេលខ្លះជានាយករដ្ឋមន្ត្រីស្តីទីនៃរាជរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ ខៀវ សំផន ត្រូវបានចោទប្រកាន់ថាមានតួនាទីជាច្រើនក្នុងបក្សកុម្មុយនីស្តកម្ពុជា និងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយធ្លាប់ធ្វើជាប្រធានគណៈប្រធានរដ្ឋផង។ គាត់ក៏ត្រូវបានចោទប្រកាន់ថាជាប្រធានមន្ទីរនយោបាយ៨៧០ និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា។

៦. ជនជាប់ចោទទាំងពីររូបត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តខុក្រិដ្ឋកម្មជាច្រើនប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម។ ជនជាប់ចោទត្រូវបានគេយល់ថាមានគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀត ដូចជា ប៉ុល ពត ជាលេខាបក្សកុម្មុយនីស្តកម្ពុជា សុន សេន ជាប្រធានសេនាធិការ និង រស់ ញឹម ជាលេខាភូមិភាគ ដើម្បីអនុវត្តបដិវត្តន៍សង្គមនិយមឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា តាមរយៈដំណើរការ«មហាលោតផ្លោះ មហាអស្ចារ្យ» និងដើម្បីការពារបក្ស ប្រឆាំងនឹងខ្មាំងតាមគ្រប់មធ្យោបាយដែលចាំបាច់។ ជនជាប់ចោទត្រូវបានចោទប្រកាន់ទៀតថា ដើម្បីសម្រេចគោលបំណងរួមនេះ ជនជាប់ចោទបានរៀបចំបង្កើតនូវគោលនយោបាយចំនួន ៥ រួមជាមួយអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មផ្សេងៗទៀតដែលការអនុវត្តគោលនយោបាយនេះបានបណ្តាលឲ្យ និង/ឬ មានឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០២ ហើយដែលជនជាប់ចោទមានចេតនាប្រព្រឹត្ត។ គោលនយោបាយទាំងនេះរួមមាន (១) ការផ្លាស់ទីលំនៅប្រជាជនម្តងហើយម្តងទៀត ចេញពីទីក្រុង និងទីប្រជុំជនទៅកាន់ទីជនបទ និងពីទីជនបទមួយទៅទីជនបទមួយទៀត (២) ការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ (៣) ការបង្កើត និងដំណើរការរបស់មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស (៤) ការកំណត់គោលដៅលើក្រុមមនុស្សជាក់លាក់មួយចំនួន រួមទាំងជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (រួមទាំងអ្នករដ្ឋការស៊ីវិល និងទាហាន ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ) និង (៥) ការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍។ ជនជាប់ចោទក៏ត្រូវបានចោទប្រកាន់ថែមទៀតថា បានរៀបចំផែនការ បញ្ជា ញុះញង់ ជួយ និងជំរុញ ឲ្យមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបានរៀបរាប់ខាងលើ។ លើសពីនេះទៅទៀត ជនជាប់ចោទក៏ត្រូវបានចោទប្រកាន់ថា ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើផងដែរ។

៧. នាពេលនេះ អង្គជំនុំជម្រះនឹងរៀបរាប់អំពីបទចោទប្រកាន់នានាដែលត្រូវបែងចែកទៅតាមគោលនយោបាយ។ យ៉ាងណាក៏ដោយ ដោយសារតែការផ្លាស់ទីលំនៅប្រជាជន

ត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០២ ពាក់ព័ន្ធតែនឹងការប្រព្រឹត្តចំពោះជនជាតិចាមនោះ គោលនយោបាយនេះ នឹងត្រូវយកមកពិភាក្សាតែលើចំណុចពាក់ព័ន្ធនឹងជនជាតិចាមតែប៉ុណ្ណោះ។ វិសាលភាពនៃបទចោទប្រកាន់នានាដែលទាក់ទងនឹងសំណុំរឿង ០០២/០២ រួមមាន ការចោទប្រកាន់ទៅលើអង្គហេតុនានាពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទ ចំពោះឧក្រិដ្ឋកម្មដូចតទៅនេះ៖

- ពាក់ព័ន្ធនឹងការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ។

- ពាក់ព័ន្ធនឹងការបង្កើត និងដំណើរការរបស់មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ជនជាប់ចោទត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពីអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ។

-ពាក់ព័ន្ធនឹងការកំណត់លើក្រុមគោលដៅដាក់លាក់ជនជាប់ចោទត្រូវបានចោទប្រកាន់ពី៖

ទីមួយ ពាក់ព័ន្ធនឹងជនជាតិចាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត។

ទីពីរ ពាក់ព័ន្ធនឹងជនជាតិវៀតណាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ការនិរទេសជនស៊ីវិលដោយខុសច្បាប់ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត។

ទីបី ពាក់ព័ន្ធនឹងពុទ្ធសាសនិក ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតនិង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា។

ទីបួន ពាក់ព័ន្ធនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (រួមទាំងអ្នករដ្ឋការស៊ីវិលនិងទាហាន) និងក្រុមគ្រួសាររបស់ពួកគេ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

ពាក់ព័ន្ធនឹងការចេញបទបញ្ជា ស្តីពីការរៀបអាពាហ៍ពិពាហ៍ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភបំពានផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

# ដំណឹងជ្រើសរើសអ្នកស្រាវជ្រាវ

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសអ្នកស្រាវជ្រាវដែលគ្រូបង្រៀន ឬអតីតគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យាចំនួន២០នាក់ ឲ្យចូលរួមក្នុងការសរសេរសំណេរ«ប្រវត្តិសាស្ត្រចេញពីភូមិ» ទាក់ទងនឹងព្រឹត្តិការណ៍នៅក្នុងរបបខ្មែរក្រហម ចេញពីភូមិឃុំដែលខ្លួនកំពុង ឬធ្លាប់បំពេញភារកិច្ចជាគ្រូបង្រៀន។ កិច្ចការនេះ ជាកិច្ចការស្ម័គ្រចិត្តនៅក្នុងគម្រោងស្តីអំពី «ប្រវត្តិសាស្ត្រភូមិ» ហើយក៏ជាដំណាក់កាលទី២នៃការអនុវត្តកិច្ចការនេះដែរ។ សំណេររបស់អ្នកស្រាវជ្រាវ នឹងត្រូវបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា រួចប្រគល់ជូនវិញដើម្បីប្រើប្រាស់ជាសម្ភារឧបទ្ទេសក្នុងការបង្រៀន ឬប្រើប្រាស់ផ្ទាល់ខ្លួន។ មជ្ឈមណ្ឌលឯកសារកម្ពុជា ឧបត្ថម្ភជាថវិកាសម្រាប់ការស្រាវជ្រាវនេះ។

   

***លក្ខខណ្ឌជ្រើសរើស***

១) អ្នកស្រាវជ្រាវ ត្រូវតែជាអតីត ឬគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យានៅក្នុងខេត្តព្រៃវែង, ស្វាយរៀង, ត្បូងឃ្មុំ, កណ្តាល (ស្រុកមុខកំពូល, ល្វាឯម និងខ្សាច់កណ្តាល) និងក្រចេះ (ស្រុកឆ្លូង) ដែលមិនជាប់តួនាទីជានាយកឬនាយករងនៃវិទ្យាល័យ ឬការងារដ៏ទៃទៀតដែលខ្លួនកំពុងធ្វើការ។

២) មានចំណេះដឹងអំពីវិធីសាស្ត្រក្នុងការធ្វើកិច្ចការស្រាវជ្រាវដូចជា ការធ្វើបទសម្ភាសន៍ទំនាក់ទំនងជាមួយអ្នកដែលត្រូវសម្ភាសន៍ វិភាគលើទិន្នន័យដើម និងសរសេរ។

៣) មានចំណេះដឹងសមរម្យក្នុងការប្រើប្រាស់កុំព្យូទ័រលើកម្មវិធី Microsoft Word & Excel និងមានកុំព្យូទ័រផ្ទាល់ខ្លួនដើម្បីធ្វើកិច្ចការនេះ។

៤) មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការសម្រេចឲ្យបាននូវសំណេរតាមការកំណត់។

៥) មានភាពច្នៃប្រឌិតចំពោះការប្រើប្រាស់ឧបករណ៍ (ថតសំឡេង និងម៉ាស៊ីនថត) សម្រាប់កិច្ចការស្រាវជ្រាវ។

៦) មានសមត្ថភាពទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន។

***លក្ខខណ្ឌការងារ***

១) ធ្វើកិច្ចការស្រាវជ្រាវដោយមិនឲ្យប៉ះពាល់ដល់ម៉ោងបង្រៀនសិស្សនៅតាមវិទ្យាល័យដែលខ្លួនកំពុងបង្រៀន។

២) ប្រើប្រាស់ពេលវិស្សមកាល ឬពេលទំនេរពីការបង្រៀន ដើម្បីធ្វើកិច្ចការនេះ។

៣) បែងចែកពេលវេលាច្បាស់លាស់ពីដំណើរការប្រព្រឹត្តទៅនៃកិច្ចការស្រាវជ្រាវ រួចផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីការសហការ។ ឧទាហរណ៍៖ បង្ហាញគម្រោងផែនការជាដំណាក់កាលៗដូចជា៖ ប្រមូលធនធានសម្រាប់ ឯកសារយោង, កំណត់គោលដៅសម្រាប់សម្ភាសន៍, ការសម្ភាសន៍, វិភាគទិន្នន័យសម្ភាសន៍ និងសំណេរ។

៤) សរសេរកិច្ចការស្រាវជ្រាវឲ្យបានយ៉ាងហោចណាស់២០ទំព័រ។

៥) ផ្ញើសំណេរ និងកិច្ចសម្ភាសន៍ជាសំឡេងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរក្សាទុក និងងាយស្រួលក្នុងការពិនិត្យផ្ទៀងផ្ទាត់ និងបោះពុម្ព។

ប្រសិនបើលោកគ្រូអ្នកគ្រូ និងប្រិយមិត្តដ៏ទៃទៀតមានការចាប់អារម្មណ៍លើកិច្ចការនេះ សូមដាក់ពាក្យស្នើសុំមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយភ្ជាប់មកជាមួយនូវ ៖ ១) ពាក្យស្នើសុំធ្វើកិច្ចការស្រាវជ្រាវប្រវត្តិភូមិ។ ២) ប្រវត្តិរូបសង្ខេប១ច្បាប់ និង ៣) សេចក្តីអធិប្បាយត្រួសៗពីប្រធានបទដែលចង់សរសេរ តាមអាសយដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬផ្ញើមកកាន់អ៊ីមែល៖ truthrasy.p@dccam.org។ ការទទួលពាក្យផុតកំណត់ត្រឹម ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៨។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា តាមទូរសព្ទ៖ ០១២ ៦៩៦៩៦១ ឬអ៊ីមែល៖ truthrasy.p@dccam.org ។

# ការសម្តែងល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់» ទម្រង់ថ្មី លើកដំបូងក្នុងឆ្នាំ២០១៩

ការសម្តែងលើកដំបូងក្នុងឆ្នាំ២០១៩ នឹងត្រូវធ្វើឡើងនៅសាលវប្បធម៌ សម្តេច ហ៊ុន សែន និងលោកជំទាវ នៃវិទ្យាស្ថានជាតិអប់រំ នាថ្ងៃទី១១ ខែមករា ចាប់ពីវេលាម៉ោង៣រសៀលតទៅ។ ដំណឹងនេះចាត់ទុកជាការអញ្ជើញដល់លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត គរុសិស្ស គរុនិស្សិត អ្នកស្រាវជ្រាវ មន្ត្រីរាជការ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល យាយ តា អ៊ុំ ពូ មីង ចូលរួមទស្សនាល្ខោននេះជាមួយយើងខ្ញុំដោយមិនតម្រូវឲ្យបង់ប្រាក់ឡើយ។

ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ជាសាច់រឿងល្ខោនដែលដកស្រង់ចេញពីរឿងរ៉ាវពិតរបស់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហមតាមរយៈ ការស្រាវជ្រាវ និងសម្ភាសន៍ជាមួយជនរងគ្រោះ និងជនដែលរស់នៅតាមភូមិឃុំនានាក្នុងប្រទេសកម្ពុជា។ អ្នកនិពន្ធជនជាតិហូឡង់២រូបគឺ អ្នកស្រី អាន់ម៉ារី ព្រីនស៍ និងអ្នកស្រី ណាន់ វ៉ាន់ ហ្គូត សហការជាមួយអម្រឹតាសិល្បៈ ដោយមានការជ្រោមជ្រែងលើកិច្ចការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានផលិតល្ខោននេះឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអនុវត្តដំណើរការផ្សះផ្សា និងចាប់ផ្តើមស្តាសង្គមកម្ពុជាដ៏ខ្ទេចខ្ទាំ



តួអង្គកំពុងសម្តែងល្ខោននិយាយ ទម្លាយភាពស្ងៀមស្ងាត់

ឡើងវិញ។ អង្គការអម្រឹតាសិល្បៈ នឹងសម្តែងល្ខោននិយាយ «ទម្ងាយភាពស្ងៀមស្ងាត់»

ល្ខោននិយាយ«ទម្ងាយភាពស្ងៀមស្ងាត់»ត្រូវបានសម្តែងនៅតាមបណ្តាភូមិឃុំមួយចំនួននៅក្នុងប្រទេសកម្ពុជា តាំងពីឆ្នាំ២០០៨ រហូតមកដល់ពេលបច្ចុប្បន្ន។ បើគិតមកដល់សព្វថ្ងៃ ប្រវត្តិនៃការកកើតល្ខោននិយាយនេះ មានអាយុកាល ១០ឆ្នាំគត់។ នៅក្នុងឆ្នាំ២០១៨ ល្ខោននិយាយ «ទម្ងាយភាពស្ងៀមស្ងាត់» ត្រូវបានធ្វើបច្ចុប្បន្នភាព ដោយដាក់បញ្ចូលឈុតថ្មីមួយទៀត ដែលបន្ថែមលើខ្លឹមសារចាស់ទាក់ទងនឹងដំណើរការស្វែងរកយុត្តិធម៌របស់សាលាក្តីខ្មែរក្រហម ដែលហៀបនឹងបញ្ចប់នាពេលអនាគតដ៏ខ្លីខាងមុខ។

ក្នុងរយៈពេល១០ឆ្នាំនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា និងអម្រឹតាសិល្បៈ ដោយមានការសហការយ៉ាងល្អពីក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចកិច្ចការជាច្រើន ហើយកិច្ចការទាំងនេះបានបែងចែកជាពាដំណាក់កាលគឺៈ

ដំណាក់កាលទី១ គឺជាដំណាក់កាលនៃការតែងនិពន្ធ ដោយបានចាប់ផ្តើមនៅក្នុងខែមករា ឆ្នាំ២០០៨ នៅពេលដែលអ្នកនិពន្ធនិងអ្នកសសេរទំនុកល្ខោន អាណាម៉ារី ព្រីនស៍ និង ណាន វ៉ាន់ហ្លួត បានធ្វើការស្រាវជ្រាវអំពីដំណើរការនៃការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា តាមរយៈការអញ្ជើញរបស់អង្គការអម្រឹតាសិល្បៈ និងមានការសម្របសម្រួលក្នុងការចុះទៅសម្ភាសន៍ជាមួយជនរងគ្រោះ និងជនដៃដល់ពីអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

តាមរយៈការស្រាវជ្រាវ និងចុះសម្ភាសន៍ជនរងគ្រោះ និងជនដៃដល់ អ្នកនិពន្ធនិងអ្នកសរសេរទំនុកល្ខោនបានតាក់តែងនូវសាច់រឿងចំនួន៧ រៀបរាប់អំពីជីវភាពប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហម ដែលបង្ហាញឲ្យឃើញពីភាពឈឺចាប់ និងភាពមិនចេះទ្រុឌទ្រោមក្នុងការប្រឈមទៅនឹងបទពិសោធន៍នានាស្ថិតក្រោមរបបខ្មែរក្រហម។

បន្ទាប់ពីការបញ្ចប់ការតែងនិពន្ធ និងហាត់សមការសម្តែងជាច្រើនម៉ោង ការសម្តែងដំបូងបង្អស់ ត្រូវបានធ្វើឡើងនៅក្នុងមជ្ឈមណ្ឌលពិព័រណ៍ជាតិ ក្នុងរាជធានីភ្នំពេញនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៩ គឺក្នុងសប្តាហ៍តែមួយជាមួយនឹងការចាប់ផ្តើមសវនាការជាផ្លូវការរបស់សាលាក្តីខ្មែរក្រហម។ បន្ទាប់ពីបញ្ចប់ការសម្តែងលើកដំបូងនេះ ការសម្តែងជាសាធារណៈលើកក្រោយៗទៀត គឺត្រូវបានបន្តទៅកាន់ខេត្តមួយចំនួននៅប៉ែកខាងត្បូងប្រទេសកម្ពុជា។

តាមរយៈការសម្តែងរបស់តួសម្តែងនៅក្នុងសាច់រឿងទាំង៧ អារម្មណ៍សោកស្តាយ ភ័យខ្លាច ទុក្ខព្រួយ ភ័ន្តច្រឡំ និងក្តីសង្ឃឹម ត្រូវបានបង្ហាញនៅចំពោះមុខទស្សនិកជនទាំងអស់ ដែលនេះសរបញ្ជាក់ឲ្យឃើញពីការព្យាយាមរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម ប្រឈមមុខនឹងរឿងហេតុទាំងឡាយក្នុងរបបខ្មែរក្រហម និងឆ្លុះបញ្ចាំងពីការផ្សះផ្សាជាមួយនឹងអតីតកាលដែលប្រកបដោយបញ្ហា។

នៅក្នុងដំណាក់កាលទី១នេះ ការសម្តែងជាសាធារណៈតាមបណ្តាខេត្តលើកដំបូងបង្អស់ បានប្រព្រឹត្តទៅប្រកបដោយជោគជ័យយ៉ាងធំធេង តាមរយៈការចូលរួមទស្សនាពីប្រជាជន សិស្ស គ្រូបង្រៀន និងប្រជាជននៅក្នុងសហគមន៍ចំនួនប្រមាណ៧ពាន់នាក់ និងការផ្សាភ្ជាប់ពីសាច់រឿងសម្តែងទៅនឹងប្រវត្តិឆ្លងកាត់របបខ្មែរក្រហមរបស់អ្នកទស្សនា។

គោលបំណងរបស់យើង គឺដើម្បីឲ្យប្រជាជនកម្ពុជាគ្រប់វ័យទទួលបានប្រយោជន៍ពីស្នាដៃនេះ តាមរយៈការប្រឈមចំពោះបញ្ហានានាទាក់ទងនឹងប្រវត្តិសាស្ត្រដ៏សោកសង្រេងដែលបានកើតមានឡើង តាមរយៈមជ្ឈដ្ឋានប្រកបដោយសុវត្ថិភាព ភាពច្នៃប្រឌិត និងសេចក្តីភ្ញាក់រឭក។ ប្រជាជនកម្ពុជាទទួលបានឱកាសក្នុងការលើកឡើងអំពីបទពិសោធន៍ផ្ទាល់ខ្លួន នៅមុននិងក្រោយពេលនៃការសម្តែងល្ខោន ដែលមានការសម្របសម្រួលពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ សកម្មភាពនេះក៏ផ្តល់ជាជំនួយដល់ប្រជាជនកម្ពុជាក្នុងការស្វែងរកវិធីសាស្ត្រសម្រាប់បំពេញដំណើរការនៃការផ្សះផ្សា និងព្យាបាលរបួសផ្លូវចិត្ត ក៏ដូចជាវិធីសាស្ត្រដទៃទៀតក្នុងការបន្តដំណើរឆ្ពោះទៅមុខទៀត។

ឆ្លើយតបទៅនឹងប្រតិកម្មដ៏វិជ្ជមាននៅក្នុងដំណាក់កាលទី១ ដំណាក់កាលទី២បានចាប់ផ្តើមឡើងជាមួយនឹងការរៀបចំការសម្តែងជាសាធារណៈនៅក្នុងខេត្តកំពត និងខេត្តតាកែវ នាខែកុម្ភៈ ឆ្នាំ២០១០។ ជាថ្មីម្តងទៀត ប្រជាជនកម្ពុជារាប់ពាន់អ្នកបានចូលទស្សនាការសម្តែងនេះ។ ប្រជាជនជាច្រើនបានចូលរួមនៅក្នុងកិច្ចពិភាក្សានៅក្រោយការសម្តែងបានបញ្ចប់ ដោយបានរៀបរាប់ពីទុក្ខវេទនា ការជ្រើសរើសខុស ឬទង្វើមិនគប្បីរបស់ខ្លួននៅក្នុងអំឡុងពេលនៃរបបប៉ុលពតជាដើម។ ចំណែកឯក្មេងៗជំនាន់ក្រោយ បានលើកឡើងជាសំណួរផ្សេងៗមកកាន់យើងខ្ញុំ។

ការសម្តែងលើកនេះ បានប្រព្រឹត្តទៅស្របពេលជាមួយនឹងការចាប់ផ្តើមសំណុំរឿង០០២ ដែលគឺជាសវនាការលើកទី២របស់សាលាក្តីខ្មែរក្រហម ពាក់ព័ន្ធនឹងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់រានមានជីវិត។ ដោយសារសារសំខាន់នៃសំណុំរឿង០០២ និងការយល់ឃើញអំពីតម្រូវការក្នុងការបញ្ជ្រាបទៅកាន់ប្រជាជនកម្ពុជាដែលរស់នៅបែកខ្ញែកគ្នា (និងប្រជាជនស្ថិតនៅតំបន់ដាច់ស្រយាល) មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្នើឲ្យអ្នកស្រី អាណាម៉ារី ព្រីនស៍ សរសេរជាឯកសារ និងថតល្ខោននេះជាសំឡេង ដើម្បីចាក់ផ្សាយតាមវិទ្យុ។ ការផ្សាយល្ខោននិយាយ ទម្លាយភាពស្ងៀមស្ងាត់ នៅតាមវិទ្យុជារៀងរាល់ថ្ងៃ បានចាប់ផ្តើមនៅក្នុងខែមេសា ឆ្នាំ២០១០ និងបន្តរហូតមក។

ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ទទួលបានផលប្រយោជន៍ ព្រមទាំងចូលរួមចំណែកដល់ភាពចំបាច់ដ៏វិសេសវិសាលក្នុងការបញ្ចប់ភាពស្ងៀមស្ងាត់ ស្របពេលដែលល្ខោននេះក្លាយជាមធ្យោបាយក្នុងការលើកឡើងអំពីកិច្ចពិភាក្សាដើម្បីចាប់ផ្តើមការផ្សះផ្សា។ ទោះបីជាបញ្ហាទាក់ទងនឹងសាលាក្តីខ្មែរក្រហមពុំត្រូវបានលើកឡើងនៅក្នុងល្ខោននេះក្តី ក៏កម្មវិធីនៅមុនពេលនិងក្រោយពេលសម្តែង មានរួមបញ្ចូលពីការពិភាក្សាដោយផ្អែកលើឥទ្ធិពលនៃសាលាក្តីខ្មែរក្រហម ដោយបានលើកឡើងអំពីតួនាទីរបស់សាលាក្តីខ្មែរក្រហម ក្នុងការស្តារជំនឿទុកចិត្តចំពោះប្រព័ន្ធច្បាប់និងយុត្តិធម៌។

ថ្វីបើល្ខោននិយាយរឿង«ទម្លាយភាពស្ងៀមស្ងាត់»ពុំមែនជាការគាត់តែងនិពន្ធដើម្បីស្នើសុំការលើកលែងទោសក្តី ក៏ល្ខោននេះ ត្រូវបានដាក់បញ្ចូលសកម្មភាពរបស់អ្នកដែលប្រព្រឹត្តខុសឆ្គងទៅក្នុងបរិបទមួយនិងបង្ហាញអំពីដំណើរការនិងមូលហេតុដែលកុមារកុមារីនិងយុវជនវ័យក្មេងៗសម្រេចជ្រើសរើសគាំទ្រខ្មែរក្រហម និងការដែលមិនអាចបកក្រឡប់ក្រោយបាននាពេលបន្ទាប់។

ដោយយល់ឃើញថា សាលាក្តីខ្មែរក្រហមបានបន្សល់ទុកនូវមន្ទិលសង្ស័យមួយចំនួន ព្រមទាំងសំណួរថ្មីៗជាច្រើនដែលតម្រូវឲ្យធ្វើការឆ្លើយតបដើម្បីអនុវត្តដំណើរការផ្សះផ្សា និងចាប់ផ្តើមស្តារសង្គមដ៏ខ្ទេចខ្ទាំនេះឡើងវិញ អ្នកនិពន្ធពិតជាចង់សាកល្បងរាល់បញ្ហាចោទឡើងនានាក្នុងការបង្កើតរឿងទម្លាយភាពស្ងៀមស្ងាត់ ក្នុងទម្រង់ថ្មី ដែលធ្វើការឆ្លើយតបច្បាស់លាស់ជាងមុនទៅកាន់សំណួរស្តីពីកម្មផល និងសាលាក្តីខ្មែរក្រហម។ នេះគឺជាដំណាក់កាលទីពាររបស់ខ្លួន ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ២០១៨កន្លងទៅនេះ។

គម្រោងនេះ ដូចគ្នានឹងគម្រោងជាច្រើនទៀតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ដែលដើរតួនាទីជាកម្មវិធីស្តីពីការពិត និងការផ្សះផ្សាក្រៅប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា។ តាមរយៈការធ្វើឲ្យប្រសើរឡើងនូវល្ខោននិយាយ ដើម្បីឆ្លើយតបទៅនឹងសំណួរនានា ដែលបានលើកឡើងអំពីសាលាក្តីខ្មែរក្រហម ក្នុងនោះរួមមានបញ្ហាចម្បងស្តីពីកម្មផលផង មជ្ឈមណ្ឌលឯកសារកម្ពុជា មានបំណងចូលរួមជាមួយទស្សនិកជនទាំងឡាយក្នុងប្រទេសកម្ពុជា ក្នុងការស្វែងរកចម្លើយសម្រាប់សំណួរដ៏ពិបាកដែលបានលើកឡើងអំពីគុណវិបត្តិនៃសាលាក្តីខ្មែរក្រហម និងត្រិះរិះពិចារណាអំពីបែបផែនផ្សេងៗដែលសាលាក្តីខ្មែរក្រហមអាចចូលរួមចំណែកក្នុងដំណើរការនៃការព្យាបាលរបួសផ្លូវចិត្ត និងការផ្សះផ្សានៅកម្ពុជា។

បន្ទាប់ពីការសម្តែងល្ខោននិយាយរឿង «ទម្ងាយភាពស្ងៀមស្ងាត់» នៅសាលវប្បធម៌ សម្តេច ហ៊ុន សែន និងលោកជំទាវនៃវិទ្យាស្ថានជាតិអប់រំ ក្នុងទីក្រុងភ្នំពេញរួចមក មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងអង្គការអម្រឹតាសិល្បៈ នឹងនាំយកការសម្តែងដូចគ្នាទៅកាន់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគនៅតាមបណ្តាខេត្តចំនួន៤ទៀតគឺ ៖ ខេត្តបាត់ដំបង កំពង់ចាម ព្រៃវែង និងតាកែវ ដើម្បីជាការចែករំលែកដល់មនុស្សគ្រប់ជំនាន់ ឲ្យស្វែងយល់ពីបទពិសោធន៍របស់អ្នករស់រានមានជីវិត ដែលត្រូវបានលាតត្រដាងដើម្បីការចងចាំ ការផ្សះផ្សាកសាងសន្តិភាព និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា នាពេលអនាគត។

***ផេង ពង្សរ៉ាស៊ី និង សោម ប៊ុនថន***



អ្នកចូលរួមទស្សនាល្ខោននិយាយ

# ការសម្តែងល្ខោនរឿង «ទម្លាយភាពស្ងៀមស្ងាត់» រៀបរាប់រឿងរ៉ាវក្នុងរបបខ្មែរក្រហមនិងជំរុញឲ្យមានការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា

ជីវិតហាក់បីដូចជាទឹកទន្លេដែលកំពុងតែហូរមិនអាចបញ្ឈប់បាន។ ដូចច្នេះ គ្មាននរណាម្នាក់ ចង់រំឭកពីអតីតកាលដ៏សែនគ្រោតគ្រាត ភាពអាម៉ាស់ និងទង្វើឃោរឃៅដែលខ្លួនបានប្រព្រឹត្តប្រាប់ដល់អ្នកដ៏ទៃទៀតឡើយ។ អ្នកទាំងនោះបានព្យាយាមលាក់បាំងពីអារម្មណ៍ និងបំភ្លេចនូវអ្វីដែលបានកើតឡើងពីអតីតកាលដែលវាគឺជាបញ្ហាដ៏ចម្បងបណ្តាលឲ្យយើងពិបាកស្វែងរកនូវផ្លូវធ្វើដំណើររួមគ្នាឲ្យបានច្បាស់លាស់ទៅអនាគត។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ នៅឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាប្រមាណ៥លាននាក់ភាគច្រើនជាស្ត្រីមេម៉ាយ ក្មេងកំព្រា និងជនពិការ ដែលនៅរស់រានមានជីវិត បានខិតខំតស៊ូកសាងជីវិតថ្មីរបស់ខ្លួនយ៉ាងស្ងប់ស្ងាត់ក្នុងសង្គមដែលទទួលរងនូវភាពខ្ទេចខ្ទាំយ៉ាងធ្ងន់ធ្ងរ។ សង្គ្រាមបានបន្សល់ទុកនូវស្នាមរបួសយ៉ាងជ្រៅ ដែលមិនទាន់សះស្បើយនៅឡើយ ហើយភាពខ្លាចរអា និងការបាត់បង់ទំនុកចិត្ត បានធ្វើឲ្យទាំងជនរងគ្រោះ និងជនដៃ ព្យាយាមបន្តលាក់បាំងប្រវត្តិរបស់ខ្លួន។ ប្រជាជនខ្លះទៀត ក៏មិនចង់រំឭកពីការចងចាំដ៏អាក្រក់របស់ខ្លួននៅក្នុងរបបខ្មែរក្រហមដែរ។ ទាំងនេះ គឺជាជំងឺដ៏កាចសាហាវមួយ ដែលបានញាំញីប្រជាជនកម្ពុជាដោយប្រយោល។

នៅក្នុងប្រទេសកម្ពុជា ការដោះស្រាយវិបត្តិអតីតកាលនៅតែជាបញ្ហាប្រឈមនៅឡើយខណៈពេលដែលភាពស្ងៀមស្ងាត់មិនទាន់បានទម្លាយ។ ការសម្តែងល្ខោន «ទម្លាយភាពស្ងៀមស្ងាត់» គឺជាកាសម្តែងល្ខោនមួយដែលផ្អែកលើរឿងរ៉ាវជីវិតពិតរបស់ជនរងគ្រោះ និងជនដៃដល់ដែលធ្លាប់បានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហម និងកំពុងតែប្រឈមមុខចំពោះការរស់នៅក្នុងសង្គមនាពេលបច្ចុប្បន្ន។ ល្ខោននេះសម្តែងឡើងក្នុងគោលបំណងចូលរួមចំណែកដល់ការពិភាក្សាពីមនុស្សមួយជំនាន់ទៅកាន់មួយជំនាន់ទៀត ការលើកទឹកចិត្តឲ្យមានការពិភាក្សារវាងអតីតកម្មាភិបាលខ្មែរក្រហម និងជនរងគ្រោះនៃរបបខ្មែរក្រហមដែលបានទទួលរងឥទ្ធិពលនៃអំពើប្រល័យពូជសាសន៍។ បន្ថែមលើការផ្សះផ្សា និងការស្វែងរកយុត្តិធម៌តាមរយៈប្រព័ន្ធច្បាប់នៃតុលាការខ្មែរក្រហម ល្ខោននិយាយនេះ គឺជាការងារសិល្បៈមួយផ្នែកដែលបានចូលរួមចំណែកក្នុងការអប់រំ ការស្វែងរកការពិត និងការផ្សះផ្សាក្រៅប្រព័ន្ធច្បាប់ ដោយផ្អែកទៅលើជំនឿសាសនា និងកម្មពៀរ។

ការកកើតឡើងនៃគម្រោងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» គឺបានចាប់ផ្តើមនៅក្នុងខែមករា ឆ្នាំ២០០៨ នៅពេលដែលអ្នកនិពន្ធ និងអ្នកសរសេរទំនុកល្ខោនឈ្មោះ អាន់ម៉ារី ព្រីនស៍ បានធ្វើការសិក្សាស្រាវជ្រាវអំពីដំណើរការនៃការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា។ អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានជួយសម្របសម្រួលការចុះសម្ភាសន៍ជាមួយជនរងគ្រោះ និងជនដៃដល់ដោយអនុញ្ញាតឲ្យមានការប្រើប្រាស់សក្ខីកម្មនិងរៀបចំការបញ្ចាំងខ្សែវីដេអូ ក៏ដូចជាខ្សែភាពយន្តប្រវត្តិសាស្ត្រនានា។

ព្រឹត្តិការណ៍នៃការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ដែលជាការសម្តែងថ្មីរបស់កម្ពុជានៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩នេះ ប្រារព្ធធ្វើឡើងនៅថ្ងៃសុក្រ ទី១១ ខែមករា ឆ្នាំ២០១៩ ក្នុងសាលប្រជុំសម្តេច ហ៊ុន សែន និងលោកជំទាវ នៃវិទ្យាស្ថានជាតិអប់រំ នាវេលាម៉ោង៣.០០ រសៀលដោយផ្តល់ការអនុញ្ញាតឲ្យមានការចូលរួមទស្សនា

ដោយសេរី និងឥតគិតថ្លៃ។ ព្រឹត្តិការណ៍នេះ មានការការចូលរួមពីទស្សនិកជនចំនួនប្រហែល៥០០នាក់ដូចជាតំណាងរបស់ក្រសួងអប់រំ យុវជន និងកីឡា មន្ត្រីស្ថានទូត អង្គការក្រៅរដ្ឋាភិបាលនានាក្នុងព្រះរាជាណាចក្រកម្ពុជា គរុសិស្ស គរុនិស្សិត អ្នកស្រាវជ្រាវ និងជាពិសេសអ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហម។ ការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» គឺមានការសម្តែងនូវសាច់រឿងចំនួន៨ឈុតដែលឈុតនីមួយៗបានឆ្លុះបញ្ចាំងអំពីភាពសោកសង្រេងនៃការបែកបាក់ ការបាត់បង់មនុស្សដែលខ្លួនស្រឡាញ់ ភាពមិនទុកចិត្តគ្នា និងគំនុំគំគួនដែលពិបាកក្នុងការអភ័យទោស ថែមទាំងមានការសម្តែងពីការពិភាក្សាវែកញែករវាងមនុស្សពីរជំនាន់ខុសគ្នា។ ទន្ទឹមនឹងការរៀបរាប់ពីទុក្ខសោកវេទនារបស់ប្រជាជននៅក្នុងរបបខ្មែរក្រហមក៏មានការច្រៀងបទចម្រៀងមនោសញ្ចេតនា ការរាំរបាំ និងរឿងនិទានដែរ។ ខាងក្រោមនេះគឺជាអត្ថន័យនៃឈុតនីមួយៗ៖

***ឈុតទី១៖ រឿងរ៉ាវពីការបែងចែកប្រជាជន***

*ស្ត្រីម្នាក់ក្នុងវ័យ ៦០ឆ្នាំ ប្រឈមមុខនឹងអ្នកភូមិចំពោះទង្វើដែលគាត់បានធ្វើក្នុងកំឡុងពេលនៃរបបខ្មែរក្រហម។ គាត់បានប្រកែកថា «ខ្ញុំគឺជាប្រធានយុវជន។ ខ្ញុំអប់រំយុវជនឲ្យស្រលាញ់ប្រទេសជាតិ»។ គាត់និយាយថា ការពិតដែលគាត់នៅរស់រានមានជីវិត បានបង្ហាញពីភាពគ្មានកំហុសរបស់គាត់។ ស្ត្រីម្នាក់ផ្សេងទៀត ដែលមានអាយុប្រហាក់ប្រហែលនឹងគ្នា ព្យាយាមបញ្ឈប់ការសួរដេញដោលនេះ បើមិនដូច្នេះទេ«ឈាមនៃកាប់សម្លាប់នឹងបន្តមកជំនាន់ក្រោយ»។ នៅពេលនោះអតីតប្រធានយុវជន ព្យាយាមគេចមុខចេញពីបុរសម្នាក់ដែលបានចូលមកចំពីខាងមុខគាត់ដើម្បីសួររកសាកសពរបស់ឪពុកខ្លួន។ បុរសម្នាក់នោះនៅតែឈឺចាប់ចំពោះការពិតដែលគាត់មិនបានវាយប្រហារឃាតករដែលសម្លាប់ឪពុករបស់គាត់វិញនៅពេលដែលរបបខ្មែរក្រហមដួលរលំ៖ ដោយសារការទប់កំហឹងបាន គាត់ប្រហែលជាបានសង្គ្រោះកម្មរបស់គាត់ ប៉ុន្តែគាត់មិនអាចកប់សពឪពុករបស់គាត់ទេ។*

***មរណភាពរបស់ភរិយា***

*«បងស្លាប់ចោលអូន ជីវិតបងសូន្យទាំងឈឺខ្លោចផ្សា ចោលអូនឯកឯងកណ្តាលលោកកា អូនពឹងនរណា នរណាពីពេលនេះទៅ អូនពឹងនរណា នរណាពីពេលនេះទៅ។ ធ្លាប់រួមធ្លាប់រស់ ចិត្តបងតែងស្មោះស្ម័គ្រលើអូនពៅ ពេលនេះបងស្ងៀមឈាមបងហូរនៅ ជិតដាប់សាច់ពៅ ពៅទុក្ខពៅទុក្ខខ្លោចផ្សា ជិតដាប់សាច់ពៅ ពៅទុក្ខពៅទុក្ខខ្លោចផ្សា។ ឲ្យអូនខមារទោស អ្វីអូនធ្វើខុសសុំលើកទោសសា អូនកប់បងហើយណាអ្នកស្នេហា សូមស្រស់រៀមរ៉ា ជីវ៉ាទៅកាន់សុគតិភព សូមស្រស់ជីវ៉ារៀមរ៉ាទៅកាន់សុគតិភព»។ (ចម្រៀង)*

***ឈុតទី២) រឿងរ៉ាវរបស់ស្ត្រី២នាក់ដែលកាលពីក្មេងជីវិតរបស់នាងត្រូវបានបំផ្លាញ***

*ស្ត្រីម្នាក់បានរំឭកពីការស្លាប់របស់ឪពុកគាត់នៅក្នុងមន្ទីរពេទ្យនៅពេលដែលគាត់មានអាយុ១០ឆ្នាំ។ នៅពេលដែលឪពុករបស់គាត់ស្រែកថ្ងូរពីការឈឺចាប់បណ្តាលមកពីជំងឺហើម ហើយម្តាយរបស់គាត់បានសុំអង្វរនារីពេទ្យឲ្យជួយសម្រាលការឈឺចាប់របស់ឪពុកគាត់។ នារីពេទ្យបានស្រែកសម្លុតដាក់ និងចាក់ថ្នាំឲ្យឪពុករបស់គាត់ ហើយឪពុករបស់គាត់បានស្លាប់។ អតីតនារីពេទ្យ ដែលមានអាយុ១៦ឆ្នាំ ត្រូវបានអង្គការយកទៅណែនាំ។ នារីពេទ្យប្រាប់យើងអំពីក្តីសុបិនរបស់គាត់កាលនៅកុមារភាពដែលចង់ក្លាយជាគ្រូពេទ្យ ប៉ុន្តែក្តីសុបិននោះត្រូវបានខ្ទេចខ្ទីនៅពេលដែលគាត់ត្រូវបានបង្ខំឲ្យសម្លាប់មនុស្សជំនួសឲ្យការព្យាបាល។ គាត់សុំការអភ័យទោស ប៉ុន្តែគាត់មិនធ្លាប់ទទួលបានការលើកលែងទោសទេ។ ថ្វីបើយ៉ាងណាក៏ដោយ នារីពេទ្យនោះ បានធូរស្បើយ ព្រោះវា គឺជាលើកទីមួយដែលគាត់ប្រាប់រឿងរ៉ាវរបស់គាត់ដែលគាត់ពិតជាអាម៉ាស់បំផុត។*

***ការចងចាំ***

*ការចងចាំជាច្រើន។ វាចេះតែវិលទៅវិលមក*
*ដូចជាកាំកង់ដែលកំពុងវិលអញ្ចឹង។*
*តែងតែមានលក្ខណៈដូចគ្នាជានិច្ច។ ដូចជាកាំកង់.......*



យោធាខ្មែរក្រហម

*កង់វិលនៅក្នុងក្បាលរបស់ខ្ញុំ។ (ចម្រៀង)*

**ឈុតទី៣) រឿងរ៉ាវអំពើឧក្រិដ្ឋ និងភាពអាម៉ាស់ដែលគ្មានថ្ងៃបញ្ចប់**

ម្ដាយម្នាក់ និងកូនប្រុសរបស់គាត់។ បន្តិចម្ដងៗ កូនប្រុសរបស់គាត់បានទទួលស្គាល់ពីហេតុផលនៃជំងឺផ្លូវចិត្តរបស់ខ្លួន៖ នៅពេលគេចាប់គាត់ដាក់គុកនិងធ្វើទារុណកម្មកាន់តែខ្លាំងឡើងៗ គាត់ចាប់ផ្ដើមឲ្យឈ្មោះអ្នកដែលជាប់ពាក់ព័ន្ធ។ អ្នកចោទប្រកាន់៖ «អ្នកបានប្រាប់ឈ្មោះប្រហែលជា៣០នាក់»។ បើក្នុងចំណោមនោះ ប្រសិនបើមនុស្សម្នាក់ៗនិយាយតែឈ្មោះមនុស្ស៣០ឬក៏៤០នាក់នោះ ក្នុងរយៈពេលតែ១ឆ្នាំឬ២ឆ្នាំ ប្រាកដជាគ្មានសេសសល់ជីវិតមនុស្សទេ។ បុរសនោះ ស្នើសុំការអភ័យទោសពីមនុស្សស្លាប់ទាំងអស់ និងសុំឲ្យបណ្ដេញកម្មអាក្រក់ចេញឲ្យអស់។

*អ៊ូ អៀ-សម្បថ*

*បើខ្ញុំចោលម្សៀត អ៊ើយចោលម្សៀត*

*កុំទុករស់ទៀតនាំធ្ងន់ផែនដី នាំធ្ងន់ផែនដី បំភ្លេចខ្ញុំចុះ*

*ឲ្យលិចតាមថ្ងៃ បើនៅចង្រៃទឹកដីគោកផ្លូក*

*ទឹកដីគោកផ្លូក។ (ចម្រៀង)*

**ឈុតទី៤) រឿងរ៉ាវរបស់និស្សិតម្នាក់ ដែលធ្លាប់ស្រមៃចង់បានពិភពលោកមួយដែលប្រសើរជាងមុន។**

ក្នុងនាមជានិស្សិតម្នាក់ បុរសនេះ ត្រូវបានចាប់ខ្លួន និងធ្វើទារុណកម្មនៅក្នុងរបប លន់ នល់។ បន្ទាប់ពីគាត់ត្រូវបានដោះលែង គាត់បានចូលរួមជាមួយចលនាខ្មែរក្រហមដើម្បីរំដោះប្រទេសឲ្យមានសេរីភាព ដោយបិតបាំងប្រវត្តិនៃការរៀនសូត្រដ៏ខ្ពស់របស់គាត់ ដើម្បីក្លាយជាកងទ័ពដែលស្ដាប់បង្គាប់និងឃោរឃៅ។ បន្ទាប់ពីបដិវត្តន៍ចប់ គាត់ឮថា ឪពុករបស់គាត់ដែលជាកសិករម្នាក់ និងបានជួយគាត់ឲ្យរៀនសូត្រ ត្រូវបានសម្លាប់។

រាល់ពេលដែលគាត់ជួបម្ដាយរបស់គាត់នៅក្នុងភូមិ ម្ដាយរបស់គាត់បានដើរចេញពីគាត់។ ឥឡូវនេះគឺជាលើកដំបូងដែលម្ដាយរបស់គាត់បានបោះបង់ចោលនូវគំនុំគំគួន ដូច្នេះគាត់ក៏បានដើរសំដៅទៅរកម្ដាយដើម្បីសុំការអភ័យទោស។ ម្ដាយរបស់គាត់ព្យាយាមអភ័យទោស ប៉ុន្តែម្ដាយរបស់គាត់ដឹងថា៖ «វានឹងមិនដូចមុនទេ»។

**សំណោកខ្មោចទួញ**

*ឱ!ស្នេហ៍បងអើយ!អើងអឹយៗអន្ទោកអន្ទោល*

*ឲ្យបងទុក្ខតតស្រោកស្រាន្តអំណឹះតទៅៗ*

*ភពបងផ្សេងហើយ ពេលនេះចុងឈើៗ*

*ស្ថានបងរហូតហើយ។*

*ចាំស្ដាប់សំណោក បងតាមខ្យល់ចុះ*

*មើលទុក្ខព្រួយបង តាមមេឃស្រទំ ស្មាបទឹកភ្នែកបងៗ*

*តាមទឹកភ្លៀងឱណាស្នេហ៍ណាៗ*

*ស្នេហ៍សម្លាញ់ចិត្ត! (ចម្រៀង)*

**ឈុតទី៥) រឿងរ៉ាវរបស់ក្មេងស្រីម្នាក់ដែលគាត់ចង់និយាយពាក្យសុំទោស ប៉ុន្តែមិនអាចទៅរួច។**

ពេលនាងនៅក្មេង ដោយសារតែភាពអត់ឃ្លាន នាងបានសម្រេចចិត្តលួចអង្ករដែលនៅសេសសល់ ខណៈពេលដែលសមាជិកគ្រួសាររបស់នាងកំពុងតែដេកលង់លក់។ នៅព្រឹកព្រលឹមប្អូនស្រីរបស់នាងឃើញគម្របពាងបើក។ ម្ដាយរបស់នាងឆ្លើយថា៖«ប្រហែលជាកណ្ដុរបានចូលស៊ីហើយ»។ នាងដឹងថា ម្ដាយរបស់នាងពិតជាដឹងថា នាងជាអ្នកលួចអង្ករ។ ប៉ុន្តែនាងមិនហ៊ានសារភាពទេ ហើយនាងស្អប់ម្ដាយរបស់នាងដែលមិនបានដាក់ទោសនាង។ នៅពេលនាងធំឡើង និងក្លាយទៅជាវេជ្ជបណ្ឌិត នាងនៅតែមានអារម្មណ៍ថានាងមានកំហុសដោយសារតែនាងបានលួចអង្ករសម្រាប់សមាជិកក្រុមគ្រួសាររបស់នាងទាំងមូល។

**បទបំពេ ទឹកចិត្តម្ដាយ**

*ឱ!នេះហើយ ឱចិត្តម្ដាយ ទោះជិតឬឆ្ងាយ*

*គិតមិនសោះសូន្យ អាក្រក់ល្អក៏នៅតែកូន នេះហើយ*

*ជាក្បួន ចងកូនហើយនឹងម្ដាយ។*

*ហាអ៊ើយ!នេះហើយជាក្បួន ចងកូន*

*នឹងម្ដាយ។ (ចម្រៀង)*

**ឈុតទី៦) រឿងរ៉ាវរបស់ក្មេងស្រីម្នាក់ដែលលែងនិយាយស្តីអ្វីទាំងអស់។**

អ្នកជិតខាងបីនាក់ ចងចាំពីមិត្តភក្តិស្រីដ៏ស្រស់ស្អាតកាលពីកុមារភាពរបស់ពួកគេឈ្មោះ «ដា»។

**ទេពអប្សរសម្តែងរបាំស្ថានសួគ៌**

*កេសារំសាយ អណ្តែតសាយភាយ ចាំងពណ៌សុវណ្ណ*
*សម្ផស្សពណ៌ភ្លុក ចក្ខុភាំងភាន់ រេរាំងពើតព័ន្ធ*
*របាំមេអំបៅ។*
*វាយោររំភើប ធម្មជាតិផ្តល់ឲ្យ បៃតងវាលស្មៅ*
*ឥតបីហ្មងសៅ ទ្រង់ទេពកញ្ញា គយគន់យូរទៅ*
*ជាប់នៅនេត្រា។*

នៅក្នុងវ័យ១៣ឆ្នាំ ដា ត្រូវបានយោធាខ្មែរក្រហមចាប់យកចូលទៅក្នុងព្រៃ ទោះបីជាមានការសុំអង្វរពីឪពុកម្តាយរបស់នាងឲ្យយកគាត់ទៅជំនួសក៏ដោយ។ បន្ទាប់ពីយោធាខ្មែរក្រហមបញ្ជូននាងត្រឡប់មកវិញ ដា មិនដែលនិយាយស្តីឬញញឹមម្តងទៀតឡើយ។ មនុស្សម្នានាំគ្នាគេចវេះនិយាយជាមួយ ឬសូម្បីតែសម្លឹងមុខរបស់នាង។ មិត្តភក្តិម្នាក់ក្នុងចំណោមមិត្តភក្តិរបស់នាង បានភ្ញាក់ខ្លួនថា ពួកគេបានធ្វើឲ្យ ដា ក្លាយជាមនុស្សគ្មានរូបរាង។ ដូច្នេះ នាងបានទៅជិត ដា ប៉ុន្តែគ្មានលទ្ធផលអ្វីទេ។ «ខ្ញុំប្រហែលជានិយាយយឺតពេលបន្តិចទៅហើយ ប៉ុន្តែថ្ងៃស្អែកខ្ញុំនឹងព្យាយាមម្តងទៀត»។

**ឈុតទី៧) រឿងរបស់ក្មេងប្រុស និងក្មេងស្រីដែលធ្លាប់ជាមិត្តជិតស្និទ្ធនឹងគ្នា។**

ស្ត្រីម្នាក់ស្គាល់ក្មេងប្រុសម្នាក់ដែលធ្លាប់ជិះឡានជាមួយគ្នានៅអង្គភាពយុវជនរបស់ខ្មែរក្រហម។ នាងសួរក្មេងប្រុសនោះថានៅចងចាំគាត់ដែរឬទេ ហើយហេតុអ្វីបានជាក្មេងប្រុសនោះបាត់បង់ស្នាមញញឹមដ៏ស្រស់ស្អាតរបស់គាត់? បុរសនោះមិនចង់ស្គាល់នាងទេ។ ដើម្បីជួយរំឭកការចងចាំបុរសនោះ នាងបាននិយាយឡើងវិញនូវបទចម្រៀង និងការចូលរួមក្នុងអង្គភាពយុវជនរបស់ខ្លួន៖

**ចម្រៀងអង្គការ**

*យើងខ្ញុំកុមារ ស្រឡាញ់អង្គការឥតមានព្រំដែន*
*ដោយសារអង្គការ យើងខ្ញុំរស់រាន ជីវិតថ្កើងថ្កាន*
*រីករាយអស្ចារ្យ។*
*មុនបដិវត្តន៍ កុមារក្រខ្សត់ រងទុក្ខវេទនា*
*រស់ដូចសត្វធាតុ កំព្រាខ្មោចផ្សា អាក្សត់មហា*
*គ្មានទីកនាដល់។*
*ស្បែកដណ្តប់ផ្តឹង ស្គមស្គាំងកំព្រឹង*
*មហាសែនកន្ទល់ យប់ដេកនឹកនា*



កងចល័តកំពុងរែកដីនៅក្នុងរបប

*ថ្ងៃឡើងខ្វាយខ្វល់ កាយកាកសំណល់*
*ដើរសុំទានគេ។*
*ឥឡូវយើងខ្ញុំ អង្គការឧត្តម ឧបត្ថម្ភគ្រប់គ្នា*
*បំប៉នសុខភាព កម្លាំងខ្លាំងក្លា ឲ្យក្លាយទៅជា*
*សមូហភាព។ (ចម្រៀង)*

បុរសនោះទទួលស្គាល់ថា គាត់ពិតជាសប្បាយរីករាយណាស់នៅពេលនោះ។ ប៉ុន្តែឥឡូវនេះ គាត់ទទួលរងនូវការឈឺចាប់ពីសុបិនដ៏អាក្រក់នេះ។ ដោយសារតែគាត់ជាអ្នករបាំ គាត់វាយក្មេងស្រីម្នាក់រហូតដល់ស្លាប់ព្រោះក្មេងស្រីនោះបានហូបផ្លែឈើរបស់អង្គការ និងរំលោភក្មេងស្រីផ្សេងទៀត។ ស្ត្រីម្នាក់នោះប្រាប់បុរសនោះពីវិធីដែលគាត់បានបំភ្លេចសុបិនអាក្រក់របស់គាត់។ ស្ត្រីម្នាក់នោះ អញ្ជើញគាត់ឲ្យចូលរួមក្នុងដំណើរទស្សនកិច្ចទៅកាន់ទួលស្លែងដើម្បីឧទ្ទិសដល់ជន



ខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩

រងគ្រោះ ហើយកុំលាក់បាំងពីអំពើរបស់ខ្លួន។ បុរសនោះស្ទាក់ស្ទើរ។

*ឈុតទី៨)*

ក្មេងប្រុសម្នាក់ក្រោកឈរក្នុងចំណោមទស្សនិកជន។ គាត់ចង់បញ្ចប់រឿងរ៉ាវនៃមន្ទិលសង្ស័យ ភាពអាម៉ាស់ កំហុសឆ្គង និងភាពភ័យខ្លាច។ គាត់ចង់ឆ្លើយថា ៖ ហេតុអ្វីបានជារឿងរ៉ាវទាំងនេះកើតឡើង ហើយតើគាត់គួរដោះស្រាយវាដោយរបៀបណា? ស្ត្រីម្នាក់ត្រូវបានរំខានដោយការរំលោភបំពានរបស់គាត់។

*ប្រសិនបើទឹកនៅក្នុងអណ្តូងនៅតែថ្លា*

*សូមមេត្តាកុំព្យាយាមធ្វើឲ្យល្អក់។*
*សូមកុំពង្រាយសម្រាមទៅក្នុងទឹក*
*និងកុំចុះងូតនៅក្នុងទឹក។ (ចម្រៀង)*

ក្មេងប្រុសនោះប្រាប់ថា ពេលគាត់នៅកុមារ ឪពុករបស់គាត់ហាមឃាត់មិនឲ្យនិយាយលេង ឬក៏សម្លឹងមើលមិត្តភក្តិជិតខាងរបស់គាត់ទេ ព្រោះមិត្តភក្តិជិតខាងនោះគឺជាកូនប្រុសរបស់ឃាតករម្នាក់ ៖ ឈាមអាក្រក់គឺនៅតែអាក្រក់។ គាត់ពិតជាមិនយល់ពីអត្ថន័យទាំងនេះទេ។ នៅក្នុងការពិភាក្សាយ៉ាងផុសផុលអំពីកម្មផល និងការខកចិត្តចំពោះលទ្ធផលនៃសាលាក្តីខ្មែរក្រហម ស្ត្រីទាំងនោះ បានប្រាប់គាត់អំពីការផ្តន្ទាទោសថា ការអភ័យទោសគឺជារឿងដ៏ប្រសើរសម្រាប់ជនរងគ្រោះ ជាជាងការស្អប់ខ្ពើម និងការសងសឹក។

*ភាពស្អប់ខ្ពើម និងការសងសឹក មិនដែល*
*ទទួលបានអ្វីមកវិញឡើយ។ មិនស្មើនឹងការ*
*ដាក់ពិន្ទុឡើយ។ ភាពស្អប់ខ្ពើម គឺជាដង្កើមដ៏កង្វក់*
*មួយដែលបំផ្លាញអ្នកស្អប់។*
*ភាពស្អប់ខ្ពើមអ្នកដទៃមានន័យថាស្អប់ខ្ពើមខ្លួនឯង។*
*ប្រសិនបើយើងទាំងអស់គ្នារស់នៅជាមួយនឹងការ*
*សងសឹក ពិភពលោកទាំងមូលនឹងក្លាយជាខ្មោងងងឹត។*
*ភាពស្អប់ខ្ពើម ត្រូវការព្យាបាល។ (ចម្រៀង)*

បុរសនោះបានធូរស្បើយ ហើយរហូតមកដល់ឥឡូវនេះ គាត់យល់ពីអ្វីដែលឪពុករបស់គាត់បាននិយាយ៖ «គាត់ត្រូវបានជាប់គាំងនៅក្នុងភាពឈឺចាប់ និងអតីតកាលរបស់គាត់ ប៉ុន្តែខ្ញុំត្រូវតែកែប្រែជីវិតរបស់ខ្ញុំ»។

*សេចក្តីបញ្ចប់*

*«ប្តូរពីទន្លេឈាម ទៅជាទន្លេនៃការផ្សះផ្សា។ ទន្លេនៃ*

*ការទទួលខុសត្រូវ។*

*ប្តូរពីទន្លេឈាម ទៅជាទន្លេនៃការផ្សះផ្សា។ ទន្លេនៃការទទួលខុសត្រូវ»។ (ចម្រៀង)*

ស្រ្តីទាំងនោះប្រាប់ថា ល្ខោនទម្លាយភាពស្ងៀមស្ងាត់ គឺជារឿងរ៉ាវនៃសង្គ្រាម ប៉ុន្តែល្ខោនទម្លាយភាពស្ងៀមស្ងាត់ ក៏ជារឿងស្នេហាផងដែរ។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានសរសេរនៅលើទំព័រអារម្ភកថានៃសៀវភៅល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ថា៖«ភាពស្ងៀមស្ងាត់រយៈពេលវែងមួយបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជាទាក់ទងនឹងជំនាន់ខ្មែរក្រហម។ ទោះបីជាដូច្នេះក្តី នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កិច្ចខិតខំប្រឹងប្រែងដ៏មោះមុត ដើម្បីបញ្ចប់ភាពស្ងៀមស្ងាត់នេះបានធ្វើឡើងតាមទម្រង់វប្បធម៌ផ្លូវច្បាប់ កម្មវិធីចុះផ្សាល់ទៅកាន់មូលដ្ឋាន និងការអប់រំពីអំពើប្រល័យពូជសាសន៍នៅតាមវិទ្យាល័យពូជសាសន៍នៅតាមវិទ្យាល័យក្នុងប្រទេសកម្ពុជា។ ខណៈពេលដែលវិធីសាស្រ្តនីមួយៗពិតជាមានតម្លៃចំពោះការព្យាបាលរបួសផ្លូវចិត្តនៅក្នុងប្រទេសកម្ពុជា ក៏នៅមានតម្រូវការវិធីសាស្រ្តនានាខ្លះទៀតដែលផ្តោតលើធាតុផ្សំផ្នែកអារម្មណ៍និងចិត្តសាស្រ្តនៃការផ្សះផ្សា និងព្យាបាលរបួសផ្លូវចិត្ត។ នេះគឺជាអ្វីដែលសិល្បៈអាចចូលរួមចំណែកយ៉ាងសំខាន់។ ខ្មែរក្រហមបានសម្លាប់សិល្បករជាច្រើននាក់ ប៉ុន្តែខ្មែរក្រហមមិនបានលុបបំបាត់ឈាមជ័រសិល្បៈរបស់ប្រជាជនកម្ពុជាបានឡើយ។ សិល្បៈ គឺជាដួងព្រលឹងរបស់យើង។ ល្ខោននិយាយដូចដែលបានលើកឡើងតាមរយៈចំណងជើង «ទម្លាយភាពស្ងៀមស្ងាត់» គឺមានគោលបំណងទម្លាយភាពស្ងៀមស្ងាត់ នៅក្នុងប្រទេសកម្ពុជា។ ល្ខោននិយាយនេះ ជាការសម្តែងអំពីទុក្ខវេទនា កំហឹង និងឆន្ទៈក្នុងការបន្តទៅមុខរបស់ប្រជាជនកម្ពុជាទោះបីស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ។ ជនរងគ្រោះនៃរបបខ្មែរក្រហម គឺជាបុគ្គលទាំងឡាយដែលបន្តរស់រានមានជីវិតទាំងការរបួសផ្លូវចិត្តនៅក្នុងសង្គមដ៏ខ្ទេចខ្ទាំមួយ ពោលគឺជាមនុស្សដែលពុំមានព្រលឹងឬស្មារតីបន្តដំណើរទៅមុខទៀត។ ខ្ញុំបានរកឃើញព្រលឹងរបស់យើងតាមរយៈការសម្តែងល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់»។ ល្ខោននិយាយនេះ នឹងជួយស្តារកិត្តិសព្ទ និងភាពជាមនុស្ស លើកកម្ពស់សីលធម៌ និងជួយដល់កូនចៅរបស់យើងឲ្យយល់អំពីប្រទេសជាតិរបស់យើងកាន់តែប្រសើរជាងមុន។ ខ្ញុំសង្ឃឹមថា ការសម្តែងនេះ ក៏ដូចជាការសម្តែងនានាក្នុងពេលអនាគតដែរ គឺនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការស្តារសង្គមកម្ពុជាសារជាថ្មី»។

**អ៊ុំន សុដាវី**



យោធាខ្មែរក្រហម

# ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» គឺជាការសម្តែងសិល្បៈរបស់ប្រទេសកម្ពុជាដែលពាំនាំសារនៃការផ្សះផ្សាជាតិ

ការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ធ្លាប់បានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា អស់រយៈពេល១០ឆ្នាំកន្លងមកហើយ ដោយបានផ្តល់ឱកាសដល់ប្រជាជនដែលធ្លាប់បានរស់នៅ និងឆ្លងកាត់របបខ្មែរក្រហម។ ការសម្តែងល្ខោននេះ មិនត្រឹមតែផ្តល់ឱកាសដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដោយសារតែការបង្ខិតបង្ខំឲ្យធ្វើការងារហួសកម្លាំង និងអត់ឃ្លានក្នុងអំឡុងពេលនៃរបបខ្មែរក្រហមតែប៉ុណ្ណោះទេ ប៉ុន្តែការសម្តែងល្ខោននេះ ថែមទាំងបានផ្តល់ឱកាសដល់ប្រជាជនទាំងអស់ដែលបានចូលរួមជាមួយចលនាខ្មែរក្រហមទៀតផង។



តួអង្គកំពុងសម្តែងល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់

សាច់រឿងដែលបានរៀបរាប់ដោយតួអង្គនីមួយៗក្នុងការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ផ្អែកទៅលើរឿងរ៉ាវពិតដែលប្រជាជនបានចែករំលែកដល់អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

នៅពេលនោះ សាលាក្តីខ្មែរក្រហមទើបតែចាប់ផ្តើមបង្កើត ហើយបានចំណាយអស់រយៈពេលជាច្រើនឆ្នាំដើម្បីកាត់ក្តីមេដឹកនាំខ្មែរក្រហម ដូចជា កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលត្រូវបានផ្តន្ទាទោស អំឡុងឆ្នាំ២០១០ ចំណែកឯ នួន ជា និង ខៀវ សំផន ត្រូវបានផ្តន្ទាទោសអំឡុងឆ្នាំ២០១៨។

ក្រោយមក ការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ត្រូវបានចាក់ផ្សាយតាមវិទ្យុនៅក្នុងប្រទេសកម្ពុជា។ ល្ខោននិយាយនេះ ត្រូវបាននាំយកទៅសម្តែងនៅក្នុងប្រទេសរ៉ាន់ដានៅក្នុងឆ្នាំ២០១២ ជាមួយតួអង្គជនជាតិរ៉ាន់ដាចំនួន២នាក់ ចូលរួមសម្តែង បន្ទាប់ពីការប្រារព្ធពិធីបុណ្យរំឭកខួបនៃអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសរ៉ាន់ដា។

ក្នុងឆ្នាំ២០១៩នេះ ការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» គឺកំពុងចាប់ផ្តើមរៀបចំសម្តែងសារជាថ្មីម្តងទៀតនៅក្នុងប្រទេសកម្ពុជា ដែលជាគម្រោងមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការបន្ថែមឈុតឆាកថ្មីមួយ នាំយកលទ្ធផលចុងក្រោយរបស់តុលាការមកបញ្ចូលនៅក្នុងសាច់រឿង។ ការសម្តែងល្ខោននេះ គឺត្រូវបានសម្តែងនៅក្នុងទីក្រុងភ្នំពេញនាថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ និងបន្តសម្តែងនៅតាមបណ្តាខេត្តចំនួន៨ផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បាននិយាយថា «ការសម្តែងល្ខោននេះគឺជាការបំពេញបន្ថែមនៃយុត្តិធម៌ដែលតុលាការខ្មែរក្រហមមិនអាចផ្តល់ឲ្យបាន»។ «តុលាការខ្មែរក្រហម គឺមិនមែនជាវេទិកានៃការព្យាបាល ឬការផ្សះផ្សា និងជាថ្នាក់រៀនប្រវត្តិសាស្រ្តនោះទេ ប៉ុន្តែការសម្តែងល្ខោននេះ គឺជាវេទិកានៃការផ្សះផ្សា ឬថ្នាក់រៀនប្រវត្តិសាស្រ្តនោះឯង។

ការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ពាក់ព័ន្ធនឹងការរៀបរាប់បញ្ហាមួយចំនួននៅក្នុងប្រទេស៖ ជនរងគ្រោះនៃរបបខ្មែរក្រហមដែលជារបបមួយបានបណ្តាលឲ្យប្រជាជនស្លាប់អស់ប្រហែល២លាននាក់ នៅតែបន្តរស់នៅជាមួយអតីតកម្មាភិបាលខ្មែរក្រហម។ លោក ឆាំង យុ បានបន្ថែមថា «តើអ្នកដឹងឬទេ នៅតាមភូមិជាច្រើនដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅលាយឡំជាមួយក្មួរវាងជនរងគ្រោះ និងជនដៃដល់»។

«តើវាកើតឡើងដោយរបៀបណាបានជាខ្មែរសម្លាប់ខ្មែរ» សំណួរដែលតួសម្តែងឈ្មោះ ម៉ម សុខលី បានចោទសួរនៅក្នុងបទចម្រៀងអំឡុងពេលចាប់ផ្តើមការសម្តែង។

«ខ្ញុំពិតជាអាម៉ាស់ណាស់នៅក្នុងជីវិតរបស់ខ្ញុំ» និយាយដោយ ប៉ុក សុវណ្ណា តួអង្គអតីតកម្មាភិបាលពេទ្យនៅក្នុងឃុំមួយ «ខ្ញុំមានសង្ឃឹម គឺក្តីសង្ឃឹមដ៏តិចតួចដែលគេនឹងអត់ទោសឲ្យខ្ញុំ»។ តួតួអង្គឈ្មោះ ឈុន ស៊ីណា បានឆ្លើយតបថា «ខ្ញុំព្យាយាមអភ័យទោស ខ្ញុំចង់អភ័យទោសឲ្យគាត់ខ្លាំងណាស់។ ប៉ុន្តែ យើងមិនគួរបំភ្លេចនូវរឿងរ៉ាវដែលបានកើតឡើងនោះទេ»។

ការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ផ្អែកតាមសាច់រឿងពិត

ចំពោះការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» មានការចូលរួមពីតួសម្តែងចំនួន៥នាក់, អ្នកចម្រៀង១នាក់គឺជាអ្នកច្រៀងរៀបរាប់ពីសាច់រឿង, អ្នករាំរបាំបុរាណខ្មែរ១នាក់ និងអ្នកលេងភ្លេងបុរាណខ្មែរ១នាក់ ដែលអមដោយឧបករណ៍ភ្លេងបុរាណខ្មែរ។ ការសម្តែងល្ខោននិយាយនេះមុនដំបូងមាន ៧សាច់រឿង ដោយផ្អែកទៅលើរឿងរ៉ាវពិតរបស់ប្រជាជន ដែលប្រមូលទិន្នន័យដោយអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចូលរួមសហការជាមួយ អ្នកស្រី អាន់ម៉ារី ព្រីនស៍ ដែលជាអ្នកនិពន្ធ និងដឹកនាំការសម្តែងសាច់រឿងនេះ។ លោក ឆាំង យុ និយាយថា «ឧទាហរណ៍ រឿងរ៉ាវរបស់កុមារដែលជាអតីតយោធាខ្មែរក្រហម ត្រូវបានដកស្រង់ចេញពីសាច់រឿងចំនួន១០០»។ លោកឆាំង យុ ក៏បានបន្ថែមទៀតថា «រឿងរ៉ាវនៃការរំលោភដែលបានរៀបរាប់ឡើងវិញនៅក្នុងការសម្តែងល្ខោននិយាយនេះគឺផ្អែកទៅលើសក្ខីកម្មជាច្រើនដែលបានកើតមានឡើងនៅក្នុងរបបខ្មែរក្រហម។

អ្នកស្រីអាន់ម៉ារីព្រីនស៍បាននិពន្ធល្ខោននិយាយ«ទម្លាយ



ភាពស្ញៀមស្ងាត់»នេះ អស់រយៈពេល១០ឆ្នាំមកហើយ។ អ្នកដឹកនាំល្ខោនជនជាតិហូឡង់នេះ បានជួបជាមួយប្រជាជនមួយចំនួន ដោយមានការជួយសម្របសម្រួលពីបុគ្គលិកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីស្វែងយល់នូវរឿងរ៉ាវរបស់ប្រជាជនទាំងនោះ។ ក្រោយមក គាត់ក៏បានប្រែក្លាយសាច់រឿងរបស់ប្រជាជនទៅជាសាច់រឿងល្ខោនមួយដែលមានចំនួន៧ឈុត។ ទម្រង់ថ្មីនៃល្ខោននិយាយក្នុងឆ្នាំ២០១៩នេះ អ្នកស្រី អាន់ម៉ារី ព្រីនស៍ បានបន្ថែមឈុត១ទៀត ដែលផ្តោតសំខាន់ទៅលើយុវវ័យជំនាន់ក្រោយរបស់ប្រទេសកម្ពុជាសព្វថ្ងៃនេះ។

**អតីតជនរងគ្រោះនិងជនដែលកំពុងរស់នៅជាមួយគ្នា**

ការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ញៀមស្ងាត់» រៀបរាប់ពីការឈឺចាប់របស់អ្នកដែលរស់នៅក្រោមការគ្រប់គ្រងរបស់មេដឹកនាំខ្មែរក្រហម ក្នុងអំឡុងពេលនៃរបបខ្មែរក្រហមចាប់ផ្តើមពីខែមេសា ឆ្នាំ១៩៧៥ និងបានបញ្ចប់ក្នុងខែមករា ឆ្នាំ១៩៧៩។ ការកាត់ក្តីមេដឹកនាំខ្មែរក្រហមមួយចំនួនមិនបានធ្វើឲ្យសេចក្តីឈឺចាប់របស់ជនរងគ្រោះបានធូរស្បើយឡើយ។

តួអង្គបានរៀបរាប់អំពីផលលំបាកដែលប្រជាជនខ្លះកំពុងតែប្រឈមមុខនឹងបញ្ហាព្រោះអ្នកទាំងអស់នោះដឹងថាខ្លួនរបស់គេកំពុងតែរស់នៅជាមួយអ្នកធ្លាប់បានចូលរួមក្នុងចលនាខ្មែរក្រហម ដែលបានសម្លាប់ជីវិតមនុស្សប្រហែល២លាននាក់នៅរវាងខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩។ ការសម្តែងក៏បង្ហាញអំពីភាពអាម៉ាសរបស់អតីតកម្មាភិបាលខ្មែរក្រហមមួយចំនួនដែរ ព្រមទាំងបង្ហាញពីអតីតកម្មាភិបាលខ្មែរក្រហមដ៏ទៃទៀតដែលបានបដិសេធ



ទស្សនិកជនកំពុងទស្សនាល្ខោននិយាយទម្លាយភាពស្ញៀមស្ងាត់

ថាមិនបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយនៅក្នុងរបបខ្មែរក្រហមឡើយ។

នៅក្នុងឈុតដំបូង តួសម្តែងម្នាក់បដិសេធមិនទទួលស្គាល់កំហុស។ តួសម្តែងម្នាក់នោះ និយាយថា «យើងត្រូវបានបញ្ជាពីមេដឹកនាំថ្នាក់លើ»។

ទោះបីជាយ៉ាងណា នៅឈុតបន្ទាប់មកទៀត អតីតនារីពេទ្យខ្មែរក្រហម និយាយពីភាពសោកស្តាយដែលតាមលងបន្ទាចនាងព្រោះនាងមិនត្រឹមតែមិនបានជួយព្យាបាលអ្នកជំងឺប៉ុណ្ណោះទេ ប៉ុន្តែជំនួសឲ្យការសម្លាប់ទៅវិញ។ តួអង្គឈ្មោះ ឈុន ស៊ីណា ប្រាប់នាងថា «ខ្ញុំដឹងថាខ្ញុំគួរតែអភ័យទោស ប៉ុន្តែគាត់សម្លាប់ឪពុករបស់ខ្ញុំ ហើយស្រែកដាក់ម្តាយខ្ញុំទៀត»។

**ការបញ្ចេញមតិរបស់យុវជនចំពោះការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់»នាពេលបច្ចុប្បន្ន**

ឈុតទី៨ គឺជាឈុតថ្មីដែលបានបញ្ចូលក្នុងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» សម្រាប់ការសម្តែងក្នុងឆ្នាំ២០១៩នេះ ដោយបានបន្ថែមការសម្តែងដ៏ពិសេសសម្រាប់យុវជនកម្ពុជាដែលតំណាងឲ្យប្រជាជនកម្ពុជាក្នុងវ័យចន្លោះពី២០ឆ្នាំឬ៣០ឆ្នាំ និងធ្លាប់បានស្គាល់ប្រទេសកម្ពុជាក្នុងពេលវេលានៃសន្តិភាព។

តួអង្គឈ្មោះ ណេន ភារិទ្ធ សួរថា«ហេតុអ្វីពូមីងត្រូវខ្លាច? តើខ្លាចដោយសារអ្វីនិងដោយសារនរណា? ហេតុអ្វីជាកំហុសដោយគ្មានទីបញ្ចប់? ហេតុអ្វីស្ងៀមស្ងាត់?។ ខ្ញុំគោរពពូមីងនិងរឿងរ៉ាវពីអតីតកាលរបស់ពូមីង។ ប៉ុន្តែខ្ញុំមិនចង់ធ្លាក់ចូលទៅក្នុងការចងចាំដ៏អាក្រក់របស់ពូមីងទេ។

បន្ទាប់មកភារិទ្ធបានពន្យល់ថា កាលនៅពីក្មេង ឪពុករបស់គាត់បានហាមឃាត់មិនឲ្យគាត់ទៅលេងជាមួយនឹងអ្នកជិតខាងដែលជាកូនរបស់អតីតកម្មាភិបាលខ្មែរក្រហមទេ។ គាត់និយាយពីឪពុករបស់គាត់ថា «ឪពុករបស់គាត់ត្រូវបាន



ខ្មែរអ៊ីស្លាមកំពុងទស្សនាល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់

ជាប់គាំងនៅក្នុងភាពឈឺចាប់និងអតីតកាលរបស់ខ្លួន»។ ដោយបន្ថែមលើនេះ គាត់មិនបានធ្វើតាមបញ្ជារបស់ឪពុកគាត់ទេ ហើយកូនប្រុសរបស់អ្នកជិតខាងនោះគឺជាមិត្តភក្តិដ៏ល្អបំផុតរបស់គាត់។

តួអង្គឈ្មោះ ប៉ុក សុវណ្ណា និយាយនៅក្នុងឈុតមួយថា «ការស្អប់ដែលគ្មានទីបញ្ចប់ ធ្វើឲ្យក្លាយទៅជាជនរងគ្រោះនៃអំពើស្អប់ ហើយជាញឹកញាប់កើតមាននៅក្នុងគ្រួសារទាំងមូលរបស់យើង។

ការសម្តែងល្ខោននេះ បញ្ចប់ដោយការច្រៀងរបស់ យិន វុត្ថា «សូមឲ្យមនុស្សទាំងអស់រស់នៅក្នុងសុភមង្គល និងសន្តិភាព»។

## តួសម្តែង

ក្រុមអ្នកសម្តែងបាននិយាយថា«ការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់»នៅឆ្នាំ២០១៩នេះគឺសម្តែងដោយតួអង្គដដែល ដែលបានសម្តែងកាលពី១០ឆ្នាំមុន ដោយបានជួបប្រទះបញ្ហាប្រឈមខ្លះៗ។

ខៀវ សុវណ្ណារិទ្ធ អ្នករាំរបាំបុរាណ និងសម្តែងជាតួអង្គសត្វស្វា ដែលជាតួអង្គត្រូវបានគេស្គាល់នៅក្នុងប្រទេសកម្ពុជា យល់ឃើញថាសព្វថ្ងៃនេះវាជួបប្រទះការលំបាកខ្លះៗក្នុងការពណ៌នាអំពីតួអង្គស្វា ពីព្រោះគាត់មានវ័យចំណាស់ជាងមុន ១០ឆ្នាំទៀតហើយ។ គាត់និយាយថា «ពេលខ្លះ ការនិយាយរៀបរាប់ គឺមិនទាន់គ្រប់គ្រាន់សម្រាប់បង្ហាញពីអ្វីដែលបានកើតឡើងនៅក្នុងការសម្តែងនោះទេ»។ គាត់ក៏បន្ថែមទៀតថា «ការសម្តែងរបស់ខ្ញុំគឺត្រូវបង្ហាញដល់ទស្សនិកជនអំពីរូបភាពនៃហេតុការណ៍នីមួយៗដែលកើតឡើង និងពិពណ៌នាដោយតួអង្គប្រុសនិងតួអង្គស្រី»។ នៅក្នុងការសម្តែងលើកដំបូងនៅក្នុងខែមករា ឆ្នាំ២០១៩ នេះ ទស្សនិកជនកម្ពុជា បានភ្ជាប់ទំនាក់ទំនងជាមួយតួអង្គសត្វស្វាបានយ៉ាងរហ័ស ដែលមនុស្សមួយចំនួននិយាយថា តួអង្គសត្វស្វាបានជួយឲ្យគេតាមដានសាច់រឿងនេះ។គាត់បន្ថែមថា«ទោះបីជាយ៉ាងណាក៏ដោយគាត់មានអារម្មណ៍ថាធូរស្បើយបន្ទាប់ពីការសម្តែងឈុតនីមួយៗ»។

តួអង្គស្រីឈ្មោះ ប៉ុក សុវណ្ណា សព្វថ្ងៃមានអាយុ៥៧ឆ្នាំ បាននិយាយថា គាត់ពិតជាបារម្ភណាស់ចំពោះការភ្លេចភ្លាំងនូវឃ្លាដែលគាត់ត្រូវនិយាយ។ គាត់បានរំឭកពីការសម្តែងកាលពីរយៈពេល១០ឆ្នាំមុនថា «ទឹកភ្នែករបស់ខ្ញុំបានស្រក់ចុះមកលើផ្ទៃមុខពីព្រោះសាច់រឿងទាំងអស់នេះបានប្រាប់ពីអ្វីដែលខ្ញុំបានឆ្លងកាត់ក្នុងរបបខ្មែរក្រហម។ ដូចច្នេះ ពេលខ្លះខ្ញុំសម្តែងមិនសូវបានល្អទេ»។

អ្នកស្រី អាន់ម៉ារី ព្រីនស៍ ក៏បាននិយាយដែរថា «អ្នកសម្តែងទាំងអស់អាចសម្តែងតួអង្គរបស់ខ្លួនបានយ៉ាងស្ទាត់ជំនាញនិងល្អប្រសើរជាងមុន»។

## ការឆ្លើយតបពីទស្សនិកជន

ទស្សនិកជនមកចូលរួមក្នុងការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ នេះ មានសិស្សានុសិស្សខ្មែរដែលកំពុងសិក្សានៅថ្នាក់ទី១០ ដល់ទី១២ សិស្សានុសិស្ស និងគរុសិស្សមកពីវិទ្យាស្ថានជាតិអប់រំ ថែមទាំងប្រជាជនដែលរស់នៅ និងរស់រានមានជីវិតពីរបបខ្មែរក្រហមដែរ។

«វ៉ុន សាល សិស្សថ្នាក់ទី១១ មកពីសាលាអន្តរជាតិឡាយហ្គី ស្ថិតក្នុងទីក្រុងភ្នំពេញបាននិយាយថា «ខ្ញុំធ្លាប់បានទស្សនាការសម្តែងល្ខោនស្រដៀងគ្នានេះ ជាច្រើនដងមកហើយ ប៉ុន្តែវាគឺជាលើកដំបូងដែលខ្ញុំបានទស្សនាការសម្តែងដែលពោរពេញទៅដោយភាពច្នៃប្រឌិត។ ជាការពិតណាស់ ល្ខោននេះ បង្ហាញសាច់រឿងខុសៗគ្នាដែលផ្សារភ្ជាប់ពីសាច់រឿងមួយទៅសាច់រឿងមួយទៀតជាជាងរៀបរាប់អំពីសាច់រឿងតែមួយ ឬផ្តោតសំខាន់លើរឿងរ៉ាវរបស់មនុស្សតែម្នាក់ និងបង្កើតឲ្យមានទំនាក់ទំនងគ្នារវាងសម័យបច្ចុប្បន្ន និងអតីតកាល ថាតើអ្នកត្រូវបានទទួលការស្តីបន្ទោសឬក៏អត់ទិន។ ខ្ញុំចង់ឲ្យសិស្សដ៏ទៃទៀតដឹងពីរឿងរ៉ាវទាំងនេះ និងស្វែងយល់ថាវាមិនត្រឹមតែជនរងគ្រោះទេ ប៉ុន្តែមានមនុស្សជាច្រើនទៀតដែលទទួលបានបទពិសោធន៍ទាំងអស់នោះ»។

ខាន ដាន់ស៊ី គរុសិស្សជំនាញអក្សរសាស្ត្រខ្មែរ កំពុង

សិក្សានៅវិទ្យាស្ថានជាតិអប់រំបាននិយាយថា» គាត់ធ្លាប់បានសិក្សាអំពីរបបខ្មែរក្រហមនៅសាលា និងតាមរយៈការចែករំលែកបទពិសោធន៍ពីម្តាយឪពុករបស់គាត់ ដែលទទួលរងនូវការឈឺចាប់យ៉ាងធ្ងន់ធ្ងរនៅក្នុងអំឡុងពេលនោះ ដែលនេះគឺជាមូលហេតុធ្វើឲ្យគាត់តែងតែស្អប់ខ្មែរក្រហម។ ប៉ុន្តែ នៅពេលស្តាប់ឮនូវរឿងរ៉ាវរបស់កម្មាភិបាលខ្មែរក្រហមថ្នាក់ទាប ដែលជានារីពេទ្យនៅក្នុងការសម្តែងនោះ បានធ្វើឲ្យគាត់គិតពិចារណាអំពីបញ្ហាទាំងនេះឡើងវិញ»។

សំ វិចិត្រ គ្រូបង្រៀនផ្នែកប្រវត្តិសាស្ត្រថ្នាក់ទី១២នៅខេត្តកណ្តាល បាននិយាយថា «នៅពេលដែលតួសម្តែងបានចាប់ផ្តើមដើរឡើងទៅលើឆាក ខ្ញុំចាប់ផ្តើមព្រឺសម្បុរខ្លាក។ ទាំងការសម្តែងសាច់រឿងនិងការរៀបចំគឺពិតជាល្អខ្លាំងណាស់ ជាពិសេសតួអង្គសត្វស្វា ដែលបង្ហាញពីរឿងរ៉ាវនីមួយៗ»។ គាត់បន្ថែមថា«សិស្សមួយចំនួនមិនជឿពីអ្វីដែលបាននិយាយអំពីការកើតឡើងនៃរបបខ្មែរក្រហមទេ។ ជំពូកខ្មៅងងឹតនៃប្រវត្តិសាស្ត្រអាចនឹងបង្រៀនដល់សិស្ស ដែលអាចឲ្យសិស្សទាំងអស់ចូលរួមការពារកុំឲ្យប្រវត្តិសាស្ត្រដ៏គ្រោតគ្រាតនេះកើតឡើងម្តងទៀត និងជំនួសឲ្យអ្វីដែលមានភាពវិជ្ជមានឡើងវិញ»។

លោក ដេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ា យល់ស្របអំពីសារសំខាន់នៃការអប់រំអំពីប្រវត្តិសាស្ត្រ ដើម្បីឲ្យប្រាកដថាអំពើប្រល័យពូជសាសន៍នឹងមិនកើតឡើងសារជាថ្មីម្តងទៀត។ «តុលាកាខ្មែរក្រហមស្ទើរតែបញ្ចប់ទាំងស្រុងទៅហើយ និងមិនអាចផ្តល់ឲ្យនូវយុត្តិធម៌បានគ្រប់គ្រាន់ដល់ប្រជាជនកម្ពុជាទាំងអស់នោះទេ»។

«ប្រសិនបើតុលាការខ្មែរក្រហម មិនអាចរកយុត្តិធម៌ឲ្យអ្នកបានគ្រប់គ្រាន់ទេ តើអ្នកអាចធ្វើអ្វីសម្រាប់សហគមន៍របស់អ្នក? ដូចច្នេះ ការអប់រំ គឺជាវិធីសាស្ត្រមួយដ៏ល្អបំផុត។ យើងលើកទឹកចិត្តឲ្យប្រជាជននិយាយអំពីបទពិសោធន៍ជីវិតនៅក្នុងរបបខ្មែរក្រហម ចំណែកឯក្មេងៗជំនាន់ក្រោយអាចស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈបទពិសោធន៍ទាំងនោះនិងបន្ទាប់មកធ្វើការចែករំលែកនិងសិក្សាស្រាវជ្រាវឲ្យបានស៊ីជម្រៅ។ ទាំងនេះ គឺជាផ្នែកមួយនៃយុត្តិធម៌ដែរ»។

ក្នុងចំណោមអ្នកទស្សនា មានការផ្តល់មតិផ្សេងៗគ្នាជាច្រើនថាតើខ្មែរក្រហមទាំងអស់គួរតែត្រូវអភ័យទោសឲ្យឬទេ។ ទីន មហាម៉ាត់ មានអាយុ៣០ឆ្នាំនៅសម័យខ្មែរក្រហមជឿជាក់ថាការសម្តែងល្ខោននេះ បាននាំយកនូវសារដ៏មានសារសំខាន់ទៅដល់យុវជនបច្ចុប្បន្ននេះ។ ចំពោះការលើកលែងទោសវិញ គឺគាត់មិនអាចលើកលែងទោសឲ្យមេដឹកនាំខ្មែរក្រហមថ្នាក់លើបានទេ។ គាត់បានបន្ថែមថា «ខ្ញុំចង់ឲ្យជនដៃដល់ ត្រូវបានសម្លាប់ដូចដែលប្រជាជនត្រូវបានពួកគេសម្លាប់ដែរ»។

អ៊ុង វណ្ណា ភេទស្រី មានអាយុ៣០ឆ្នាំក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ចាប់អារម្មណ៍ចំពោះការផ្សះផ្សា។ គាត់បាននិយាយអំពីការសម្តែងល្ខោននេះថា «ខ្ញុំចូលចិត្តបទចម្រៀងចុងក្រោយណាស់ៈ ប្តូរពីទន្លេឈាមទៅជាទន្លេនៃការផ្សះផ្សា។ ទន្លេនៃការទទួលខុសត្រូវ។ នេះគឺជាឃ្លាដែលខ្ញុំចូលចិត្ត។ ខ្ញុំចង់ឲ្យការសម្តែងនេះបន្តពង្រីកឲ្យបានទូលំទូលាយនៅក្នុងប្រទេសសម្រាប់ការផ្សះផ្សាជាតិ»។

គម្រោងនៃការសម្តែងល្ខោននិយាយ «ទម្ងាយភាពស្ងៀមស្ងាត់» ទទួលបានការឧបត្ថម្ភដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត និងគាំទ្រដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ និងសម្ព័ន្ធអន្តរជាតិនៃទីតាំងមនសិការ។

ការសម្តែងល្ខោននិយាយ «ទម្ងាយភាពស្ងៀមស្ងាត់» គឺដើម្បីសងគុណដល់ម្តាយទាំងអស់ដែលចិញ្ចឹមកូនរបស់ខ្លួនដោយបាតដៃទទេ,គ្មានស្បែកជើង, គ្មានការសិក្សា ហើយនឹងដែលជាអ្នកកសាងប្រទេសឡើងវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។

មជ្ឈមណ្ឌលឯកសារកម្ពុជា

(បកប្រែពីភាសាអង់គ្លេសមកជាភាសាខ្មែរដោយ ៖ អ៊ុន សុដាវី)

# កាលវិភាគបញ្ចាំងខ្សែភាពយន្តឯកសារ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា



បញ្ចាំងរៀងរាល់ថ្ងៃសុក្រ
វេលាម៉ោង១០:០០ ព្រឹក
ទីតាំងនៅវិចិត្រសាលសិល្បៈ
សហសម័យវិទ្យាស្ថានស្លឹករឹត
អគារ H នៃវិទ្យាស្ថានជាតិអប់រំ
(មហាវិថីព្រះសីហនុ
រាជធានីភ្នំពេញ)










វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងស្ថិតនៅក្នុងអគារ H នៃវិទ្យាស្ថានជាតិអប់រំ ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីស្នាដៃសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ ជារួម វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើកកម្ពស់និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់កសាងឡើងក្នុងរជ្ជកាលបារាំង សម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង ស៊ាង ចិន្តា ទូរសព្ទលេខ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល truthchenda.s@dccam.org

# ព័ត៌មានមិនច្បាស់លាស់អំពីឪពុកម្ដាយខ្ញុំ នៅតែធ្វើឲ្យខ្ញុំមិនអស់ចិត្ត

នាងខ្ញុំឈ្មោះ ចៅ ច័ន្ទសុវណ្ណាវិនិត្យ សព្វថ្ងៃនាងខ្ញុំរស់នៅក្នុងប្រទេសកាណាដា។ នាងខ្ញុំបានបាត់ដំណឹងឪពុកឈ្មោះ ចៅ ច័ន្ទ កើតនៅក្នុងឆ្នាំ១៩៤៥ ក្នុងភូមិពោធិ ឃុំត្រពាំងអណ្តូង ខេត្តមាត់ជ្រូក (កម្ពុជាក្រោម) និងម្តាយឈ្មោះ ដួន ច័ន្ទសុវណ្ណា កើតនៅក្នុងឆ្នាំ១៩៥៣ នៅភូមិទម្លាប់ ឃុំភ្នំដិន (ខ្ញុំចាំមិនច្បាស់) ស្រុកគិរីវង្ស ខេត្តតាកែវ។ នៅឆ្នាំ១៩៦៧ ឪពុករបស់ខ្ញុំបានចាកចេញពីស្រុកកំណើតនៅកម្ពុជាក្រោមឡើងមករៀននៅខេត្តតាកែវ។ ឪពុកខ្ញុំបានជួបម្តាយខ្ញុំ និងបានរៀបការជាមួយគ្នាមួយឆ្នាំក្រោយមក។ នៅឆ្នាំ១៩៦៩ ម្តាយខ្ញុំបានកើតបានកូនស្រីម្នាក់ គឺនាងខ្ញុំ។ ឪពុករបស់ខ្ញុំបានរៀនបន្តរហូតបានធ្វើការងារខាងសូរិយោដី។

នៅដើមឆ្នាំ១៩៧៥ ឪពុកម្តាយខ្ញុំបាននាំកូនៗមករស់នៅភ្នំពេញ ដោយពេលនោះឪពុករបស់ខ្ញុំបានចូលធ្វើការងារខាងត្រាវ៉ូ នៅក្រុមហ៊ុនមួយដែលមានស្នាក់ការនៅម្តុំចាក់អង្រែខាងត្បូងភ្នំពេញ។ ពេលសម្រាកពីការងារ ឪពុករបស់ខ្ញុំតែងតែមកជួយលក់ដូរម្តាយខ្ញុំ ព្រោះពេលនោះម្តាយខ្ញុំមានកូនពីរនាក់ទៀត គឺប្អូនប្រុសខ្ញុំម្នាក់អាយុ៥ឆ្នាំ (ប្អូនខ្ញុំមួយឆ្នាំ) និងប្អូនស្រីម្នាក់ទៀតអាយុ២ឆ្នាំ។

នៅពេលយោធាខ្មែរក្រហមចូលមកដល់ភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសារខ្ញុំត្រូវបានខ្មែរក្រហម



ចៅ ច័ន្ទ ថតនៅឆ្នាំ១៩៦៨



ដួន ច័ន្ទសុវណ្ណា ថតនៅឆ្នាំ១៩៦៨

ជម្លៀសទៅស្វាយស៊ីសូផុន ខេត្តបន្ទាយមានជ័យ។ ទីនោះ គ្រួសារខ្ញុំត្រូវបានខ្មែរក្រហមបែងចែកឲ្យទៅស្នាក់នៅ និងធ្វើការងារនៅតាមភូមិផ្សេងៗនៅក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ ប្អូនស្រីខ្ញុំម្នាក់បានស្លាប់ដោយសារជំងឺ និងខ្វះអាហារូបត្ថម្ភនៅពេលទៅដល់ទីតាំងមួយដែលប្រជាជននៅទីនោះហៅថា ព្រៃគាំ។ ក្រោយស្លាប់ប្អូនស្រីខ្ញុំបានមួយរយៈ ប្អូនប្រុសរបស់ខ្ញុំម្នាក់ទៀតក៏បានស្លាប់ដោយសារជំងឺនៅឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ នៅដើមឆ្នាំ១៩៧៨ ម្តាយខ្ញុំមានផ្ទៃពោះកូនម្នាក់ទៀត ដែលនាពេលនោះហើយដលែខ្មរែក្រហមបានហាឪពុករបស់ខ្ញុំពីភូមិប៉ោយសំរោង ឃុំព្រះនេត្រព្រះ យកទៅរៀនសូត្រ។ ម្តាយខ្ញុំកើតបានកូនស្រីម្នាក់ដោយមិនមានវត្តមានឪពុករបស់ខ្ញុំឡើយ។ រំលងបានប៉ុន្មានថ្ងៃ ប្អូនស្រីរបស់ខ្ញុំដែលទើបនឹងកើតបានស្លាប់ដោយសារជំងឺ។ នៅពេលសភាពការណ៍ច្របូលច្របល់ក្នុងអំឡុងចុងឆ្នាំ១៩៧៨ និងដើមឆ្នាំ១៩៧៩ ម្តាយខ្ញុំបានទទួលដំណឹងឪពុករបស់ខ្ញុំ ពីបុរសម្នាក់ដែលខ្មែរក្រហមបានហៅទៅរៀនសូត្រជាមួយគ្នា ប៉ុន្តែបុរសនោះមានសំណាងបានត្រឡប់មកភូមិវិញ។ បុរសនោះបានប្រាប់ម្តាយរបស់ខ្ញុំថា ឪពុករបស់ខ្ញុំនៅរស់រានមានជីវិតនៅឡើយ ដោយពេលនោះខ្មែរក្រហមចាត់តាំងគាត់ឲ្យធ្វើជាជាងកាត់សក់។ បុរសនោះបានហៅឪពុករបស់ខ្ញុំត្រឡប់មកភូមិវិញដែរ ប៉ុន្តែឪពុករបស់ខ្ញុំបានតបវិញថា នៅជាប់រវល់កាត់សក់។

ក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩ ម្តាយខ្ញុំបានធ្លាក់ខ្លួនឈឺ និងបានមកសម្រាកព្យាបាលនៅមន្ទីរពេទ្យស្វាយស៊ីសូផុន ដែលពេលនោះខ្ញុំក៏នៅជាមួយម្តាយខ្ញុំដែរ។ ខ្ញុំបានឃើញជនជាតិវៀតណាមជាច្រើននាក់នៅក្នុងមន្ទីរពេទ្យ។ ខ្ញុំក៏បានឃើញមិត្តភក្តិម្តាយរបស់ខ្ញុំម្នាក់ឈ្មោះ ស្រី (ស្រីមានម្តាយជាគ្រូចូលរូបជនជាតិវៀតណាម) បានចូលមកជួបម្តាយខ្ញុំ និងជួបខ្ញុំនៅមន្ទីរពេទ្យស្វាយស៊ីសូផុនជាញឹកញាប់។ នៅពេលមួយ មិត្តភក្តិម្តាយរបស់ខ្ញុំឈ្មោះ ស្រី បានយកខ្ញុំចេញពីមន្ទីរពេទ្យទៅនៅឃុំបន្ទាយនាង ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ដោយបានប្រាប់ខ្ញុំថា ម្តាយរបស់ខ្ញុំបានស្លាប់ហើយ។ ដោយសារខ្ញុំមានវ័យក្មេង និងទើបតែ១០ឆ្នាំ ទើបខ្ញុំជឿលើស្ត្រីនោះ និងមិនបានសួរនាំដំណឹងពីម្តាយតទៅទៀត។ ចាប់តាំងពីពេលនោះ ខ្ញុំបានបែកម្តាយខ្ញុំរហូត ដោយមិនដឹងថា ស្លាប់ ឬរស់ពិតប្រាកដឡើយ។

ខ្ញុំបានរស់នៅឃុំបន្ទាយនាងរយៈពេលមួយឆ្នាំ មិត្តភក្តិម្តាយរបស់ខ្ញុំឈ្មោះ ស្រី ក៏បាននាំខ្ញុំបន្តមកភ្នំពេញ។ សំណាងល្អ ខ្ញុំបានជួបយាយខាងម្តាយឈ្មោះ អ៊ុង គុយ និងបានមករស់នៅជួបជុំជាមួយគាត់វិញ។ បន្ទាប់មក ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាទួលទំពូងបានរយៈពេលប្រហែលបីខែ ទើបខ្ញុំ និងយាយធ្វើដំណើរទៅរស់នៅជំរំខៅអ៊ីដាង។ ខ្ញុំចាំបានថា ពេលនោះខ្ញុំស្នាក់នៅក្បែរវត្ត ជិតសង្កាត់ចិនមួយ។ នៅឆ្នាំ១៩៨២ ខ្ញុំបានទទួលសិទ្ធិទៅរស់នៅប្រទេសកាណាដារហូតមកដល់សព្វថ្ងៃ។

ថ្មីៗនេះ ខ្ញុំបានស្គាល់មនុស្សម្នាក់រស់នៅក្នុងប្រទេសកម្ពុជាដែលធ្លាប់ដឹកប្រជាជនភៀសខ្លួន ពីខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបងត្រឡប់មកភ្នំពេញវិញ ក្រោយពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។ ខ្ញុំបានសួរគាត់ពីដំណឹងឪពុករបស់ខ្ញុំ ហើយគាត់បានប្រាប់ខ្ញុំថា ធ្លាប់ជួបឪពុករបស់ខ្ញុំនៅស្វាយស៊ីសូផុន។ គាត់ថែមទាំងធ្លាប់បានដឹកឪពុករបស់ខ្ញុំ និងធ្លាប់ឲ្យឪពុករបស់ខ្ញុំកាត់សក់ឲ្យគាត់ទៀតផង។ ប៉ុន្តែសព្វថ្ងៃគាត់មិនដឹងថា ឪពុករបស់ខ្ញុំរស់នៅទីណាឡើយ។ ខ្ញុំសូមភ្ជាប់រូបថតឪពុកម្តាយខ្ញុំ និងក្រុមគ្រួសារជាមួយរឿងរ៉ាវដែលខ្ញុំបានចងចាំ។

អាស្រ័យដូចដែលបានរៀបរាប់ខាងលើ ប្រសិនបើបងប្អូនណាបានស្គាល់ ឬធ្លាប់ឮឈ្មោះ ចៅ ច័ន្ទ និង ជួន ច័ន្ទសុវណ្ណា សូមមេត្តាទំនាក់ទំនងមកនាងខ្ញុំតាមរយៈលេខទូរសព្ទ៖ ០១០ ៥១៥០១០ និង ០១២ ៩៩៦ ៧៥០ ឬតាមរយៈអាសយដ្ឋាន៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ។

ចៅ ច័ន្ទសុវណ្ណាវិនិត្យ



ថ្ងៃភ្ជាប់ពាក្យរបស់ ចៅ
ច័ន្ទសុវណ្ណារិនិត្យ
រូបខាងឆ្វេងទី១ ៖ លោកយាយ
អ៊ុង គុយ



រូបទី១ រាប់ពីស្តាំ ច័ន្ទសុវណ្ណារិនិត្យ
និងប្តីរបស់គាត់



ក្រុមគ្រួសាររបស់
ច័ន្ទសុវណ្ណារិនិត្យ



ថតនៅភ្នំពេញ ឆ្នាំ១៩៩៣
រូបខាងស្តាំទី២ ៖ កេង ចិត្រា
(ស្រ្តីពក្មេង) មកពីខេត្តតាកែវ
គឺជាបងប្អូនជីដូនមួយរបស់ ចៅ ច័ន្ទសុវណ្ណា
រូបខាងឆ្វេងទី២ ៖ បងស្រីធំរបស់ឪពុក ចៅ
ច័ន្ទសុវណ្ណា



ក្រុមគ្រួសាររបស់ច័ន្ទសុវណ្ណាវិនិត្យ



កែវ ម៉ីលី គឺជាកូនស្រីរបស់ច័ន្ទសុវណ្ណាវិនិត្យ

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

ឃឹន ផាត ហៅ ហាក់ កងហាក្នុងកងពល ៣១០ ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦ នៅកងពល៣១០។ ខ្មែរក្រហមបញ្ជូល ឃឹន ផាត មកគុកទួលស្លែងនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៣៨ថ្ងៃ។

យុត ឈឿន ហៅ គ្រាន មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់ពូ យុត ចិន និងមីង អាន យោធាវរៈសេនាតូចកងពល៣១០ មានប្រពន្ធឈ្មោះ លាប ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅកងពល៣១០ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ង បន្ទប់ធំ ០៣ បន្ទប់តូច ១០។ ខ្មែរក្រហមសម្លាប់ យុត ឈឿន នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៣១ថ្ងៃ។

យុត ធីន មានអាយុ១៧ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅទូកមាស ខេត្តកំពត ជាកូនរបស់ពូ សន និង មីងនីង សាទ ជាយុទ្ធជនមន្ទីរពិការ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦ នៅពេទ្យសេនាធិការ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ជ បន្ទប់ធំ ៣បន្ទប់តូច១៧នៅថ្ងៃបន្ទាប់។ ខ្មែរក្រហមសម្លាប់យុតធីននៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៣០ថ្ងៃ។

យុត រុន មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក ៥៥ តំបន់ ៣៣ (ស្រុកព្រៃកប្បាស ខេត្តតាកែវ) ជាកូនរបស់ពូ ចាន យន និងមីង ម៉ែន អ៊ុម យុទ្ធជន ១២៧ កងពល៧០៣ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៧ នៅកងពល៧០៣ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ជ បន្ទប់ធំ ៥ បន្ទប់តូច ៤។ ខ្មែរក្រហមសម្លាប់ យុត រុន នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៦៧ ថ្ងៃ។

យុត ឡុំ ហៅ រើម មានអាយុ២១ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅសូទ្រនិគម ខេត្តសៀមរាប ជាកូនរបស់ពូ យុត នែម និងមីង ជឹម វ៉ាត លេខាធនុសេនាធំកងពល៣១០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៥ខែមករា ឆ្នាំ១៩៧៧ នៅកងពល៣១០។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

យុន ចាន់ស៊ីថា ហៅ ឃៀង ហៅ យុន ចាន់ស៊ីថាត មានអាយុ២៦ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់ពូ យុន ហួត និងមីង ឆាយ ឃៀង យុទ្ធជនវរៈ៧៧២ ភូមិភាគឧត្តរ មានប្រពន្ធឈ្មោះ អ៊ុន គឹមសៀន ហៅ ជៀន មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧៦ នៅពាណិជ្ជកម្ម ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ ៥ បន្ទប់តូច ៤ នៅថ្ងៃដដែល។ ខ្មែរក្រហមសម្លាប់ យុន ចាន់ស៊ីថា នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៥២ ថ្ងៃ។

យុន គួយ មានអាយុ៣៥ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក១៨ តំបន់២៥ (ស្រុកកោះធំ ខេត្តកណ្ដាល) ជាកូនរបស់អ៊ុំ ហឹង យុន និងអ៊ុំស្រី ម៉ៅ អេង យុទ្ធជនកង២១ កងពល៧០៣ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅស-២១ យ។ ខ្មែរក្រហមសម្លាប់ យុន គួយ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧។

យុន ឌៀន ហៅ ដឿន សមាជិកដឹកជញ្ជូន ត្រូវបានខ្មែរ

ក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦ នៅពាណិជ្ជកម្ម។ ខ្មែរក្រហមចាប់ យុន ខៀន បញ្ជូលក្នុងគុកទួលស្លែងនៅថ្ងៃទី១៣ ឬ១៥ ខែតុលា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី១៨ មីនា ឆ្នាំ១៩៧៧។

យុន នរាយ មានអាយុ៤២ឆ្នាំក្នុងឆ្នាំ១៩៧៥ អតីតវិស្វករនៅក្រសួងខស្សរាហកម្ម មានស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់អ៊ំ យុន ស៊ាង និងអ៊ំស្រី ឈុន ឡាំង ហ៊ាង មានប្រពន្ធឈ្មោះ លឹម ឈុនទី ហៅ ទូច មានកូនប្រុស២នាក់និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧៥ នៅទួលទ្រា ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៧ បន្ទប់ធំ៦។ ខ្មែរក្រហមចាប់ យុន នរាយ បញ្ជូលគុកទួលស្លែងនៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៦។

យុត ម៉ារីន ហៅ សម្បត្តិ មានអាយុ២១ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុក៥២ (ស្រុកសំរោងទង) ខេត្តកំពង់ស្ពឺ ជាកូនរបស់ពូ ខាត់ និងមីង ហៀង ជាកម្មកររទេះភ្លើង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២០ ខែមករា ឆ្នាំ១៩៧៦ នៅរទេះភ្លើង ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ដ បន្ទប់ធំ ៣ បន្ទប់តូច ១៣ នៅថ្ងៃបន្ទាប់។ ខ្មែរក្រហមសម្លាប់ យុត ម៉ារីន នៅថ្ងទី២៨ ខែមករា ឆ្នាំ១៩៧៧។

យុន យន ហៅ វុធ អាយុ២៤ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅពញាក្រែក ខេត្តកំពង់ចាម ជាកូនរបស់ពូ យុន យេន និងមីង ឈឹម សឹម ត្រូវបានខ្មែរករហមចាប់ខ្លួននៅថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៧៦ នៅទំនប់ទទឹងពូន ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៥ បន្ទប់តូច ៣។ ខ្មែរក្រហមបញ្ជូល យុន យន ក្នុងគុកទួលស្លែងនៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៧៦។

យុន វ៉ា ហៅ វ៉ា មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្ទឹងត្រង់ ខេត្តកំពង់ចាម ជាកូនរបស់ពូ យុន ស៊ុន និងមីង យ៉ុង ប៉ិល ជាយុទ្ធជនកងពល៤៥០ ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅកងពល ៤៥០។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

យុន អ៊ិន ហៅ អាន មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្ទោង ខេត្តកំពង់ធំ ជាកូនរបស់ពូ យុន ជិត និងមីង អ៊ូ ស៊ុយ ជាយុទ្ធជនរទេះភ្លើង ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៦ នៅរទេះភ្លើង ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ខ បន្ទប់ធំ ៣ បន្ទប់តូច ៩។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

យុន អិត ហៅ អាត ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦ នៅរទេះភ្លើង។ ខ្មែរក្រហមបញ្ជូល យុន អិត ក្នុងគុកទួលស្លែង នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ជាប់ឃុំឃាំងអស់រយៈ ៤៩ ថ្ងៃ។

យុយ ង៉ិចសែ ហៅ សៀក លឹម មានអាយុ ២៥ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុក២០ (ស្រុកស្អាង) ខេត្តកណ្តាល មានប្តីឈ្មោះ ឡេង ប៉ាវ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៦ នៅស្រុក១៨ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងបន្ទប់ធំ ០៧ បន្ទប់តូច ២០។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ខ្មែរក្រហមបញ្ជូល យុយ ង៉ិកសែ មកដល់គុកទួលស្លែង នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៦, ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៦ និងថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ យុយ ង៉ិចសែ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦។ (តទៅលេខក្រោយ)

*វ៉ាន់ ថាន់ពៅដារ៉ា, មជ្ឈមណ្ឌលឯកសារកម្ពុជា*

# អដ្ឋិធាតុ៖ គ្មានអ្វីជាអមតៈ

## បញ្ជីអដ្ឋិធាតុដែលរកឃើញនៅក្រោមបល្ល័ង្កព្រះពុទ្ធរូបក្នុងវត្តលង្កា, ទីក្រុងភ្នំពេញ

*រៀបរៀងដោយ៖ ចាន ប្រាថ្នា, សា ហ្វាទីលី, សុភ័ក្ត្រ ភាណា និង អ៊ុន សុដាវី*
*វិទ្យាស្ថានស្ទីករីត, ខែកុម្ភៈ ឆ្នាំ២០១៥*

(តពីលេខមុន)

| ល.រ | លេខកូដ | ឈ្មោះ ជាភាសាអង់គ្លេស | ឈ្មោះ | ភេទ | អាយុ | ថ្ងៃមរណភាព | ទំព័រក្នុងសៀវភៅ |
|---|---|---|---|---|---|---|---|
| ២៧១ | ៨៤៤៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៦០ |
| ២៧២ | ៨៤៥០ | Chhin Pevseu | ឈិន ប៉ែវសឺ (陈表世) | ? | ? | ? | ១៦០ |
| ២៧៣ | ៨៤៥៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៦០ |
| ២៧៤ | ៨៤៥៦ | Peou Chanthy | ពៅ ចាន្ទី | ? | ២៧ ឆ្នាំ | ១២/១២/១៩៩២ | ១៦៣ |
| ២៧៥ | ៨៤៥៧ | Kann Channeary | កាន់ ចាន់នារី | ? | ៣៥ ឆ្នាំ | ២០/០៣/១៩៩២ | ១៦៣ |
| ២៧៦ | ៨៤៦១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៦៣ |
| ២៧៧ | ៨៤៦៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៦៣ |
| ២៧៨ | ៨៤៦៦ | Saom Yoeun (Female child) | សោម យឿន (កុមារី) | ស្រី | ? | ? | ១៦៥ |
| ២៧៩ | ៨៤៦៨ | Unknown (Female child) | មិនដឹងឈ្មោះ (កុមារី) | ស្រី | ? | ? | ១៧១ |
| ២៨០ | ៨៤៧១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៧៧ |
| ២៨១ | ៨៤៧៨ | Da Ran | ដា រ៉ន | ? | ? | ? | ១៦៣ |
| ២៨២ | ៨៤៨២ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៦៦ |
| ២៨៣ | ៨៥៦៣ | Khou Hong? | ឃូ ហុង? | ? | ? | ២៤/០៧/១៩៨២ | ១៧៥ |
| ២៨៤ | ៨៤៨៨ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៦៦ |
| ២៨៥ | ៨៤៨៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៧៨ |
| ២៨៦ | ៨៤៩១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៦៦ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២៨៧ | ៨៤៩៣ | Miech Ros | មៀច រស់ | ស្រី | ៩៥ ឆ្នាំ | ០១/០៧/១៩៨៨ | ១៦៦ |
| ២៨៨ | ៨៤៨១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៦៦ |
| ២៨៩ | ៨៤៩៨ | Him Thann | ហ៊ឹម ថាន់ | ? | ? | ? | ១៦៩ |
| ២៩០ | ៨៥០១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៧៨ |
| ២៩១ | ៨៥០៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៦៩ |
| ២៩២ | ៨៥០៨ | Sao Heng | សៅ ហេង | ? | ? | ២០/០៧/១៩៨៣ | ១៦៩ |
| ២៩៣ | ៨៥១០ | Nit Savoeun | និត សាវឿន | ប្រុស | ២៨ ឆ្នាំ | ០៨/០១/១៩៩១ | ១៦៩ |
| ២៩៤ | ៨៥១៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៧៩ |
| ២៩៥ | ៨៥១៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៧៩ |
| ២៩៦ | ៨៥២៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៦៩ |
| ២៩៧ | ៨៥២៥ | Lao Sokprachea | ឡៅ សុខប្រជា | ? | ? | ១៣/០៨/១៩៨៧ | ១៧២ |
| ២៩៨ | ៨៥២៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៨០ |
| ២៩៩ | ៨៥២៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៧២ |
| ៣០០ | ៨៥៣១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៧២ |
| ៣០១ | ៨៥៣៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៧២ |
| ៣០២ | ៨៥៣៦ | Seng Ting (Father) | សេង ទីង (លោកឪពុក) | ប្រុស | ? | ?/០៥/១៩៨១ | ១៧៥ |
| ៣០៣ | ៨៥៣៨ | Bun Soklay | ប៊ុន សុខឡាយ | ស្រី | ? | ២០/១០/១៩៨៤ | |
| ៣០៤ | ៨៥៤១ | Im Phin | អ៊ឹម ភិន | ? | ២៣ឆ្នាំ | ២២/០២/១៩៩០ | ១៧២ |
| ៣០៥ | ៨៥៤៧ | Unknown (have photo) | មិនដឹងឈ្មោះ (មានរូបថត) | ? | ? | ? | |
| ៣០៦ | ៨៥៤៨ | Choung Song | ជួង សុង | ? | ? | ? | ១៨០ |
| ៣០៧ | ៨៥៥៣ | Chhay Leng | ឆៃ ឡេង | ? | ? | ? | ១៧៥ |
| ៣០៨ | ៨៥៥៥ | Nhen Tara | ញ៉ៀន តារា | ? | ? | ១០/១២/១៩៨៤ | ១៧៥ |
| ៣០៩ | ៨៥៥៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៨១ |

(នៅមានត)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 230, February 2019 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M BRK, 30 Ocotber 2018.